# មូលសិក្ខា - ដីកា

ព.ស. ២៥៥៨

ផ្សាយចេញពីពុទ្ធិកសមាគមសមណនិស្សិតកម្ពុជា-ស្រីលង្កា

# មូលសិក្ខា - ដីកា

ប្រែ និងរៀបរៀង

ដោយ

ភិក្ខុ ធម្មសិរី

ព.ស. ២៥៥៨

# អារម្ភកថា

គម្ពីរមូលសិក្ខា គឺជាគម្ពីរសម្ដែងអំពីព្រះវិន័យដោយសង្ខេប សិក្សាក្នុងរយះពេលខ្លី សម្រាប់ភិក្ខុ-សាមណេរបួសថ្មី ។ រចនាដោយព្រះមហាសាមិត្ថេរ ជនជាតិស្រីលង្កា នា ព.ស.៩០០

ចំណែកគម្ពីរមូលសិក្ខា-ដីកា គឺជាគម្ពីរអធិប្បាយពន្យល់ន័យគម្ពីរមូលសិក្ខាឱ្យបានទូលំទូលាយ ។

អ្នករចនាគម្ពីរនេះមានមតិពីរផ្សេងគ្នា គឺៈ

១. តាមគម្ពីរគន្ថវង្ស ប្រាប់ថា រចនាដោយព្រះវាចិស្សរត្ថេរ

២. តាមគម្ពីរបិដកត្ថម៉ៃ ថា រចនាដោយព្រះវិមលសារត្ថេរ នៅអនុរាធបុរីស្រីលង្កា ។

ទាំងពីរអង្គនេះ មិនប្រាកដថាអង្គណាមួយទេ ។

ដោយសារធ្លាប់បានអានគម្ពីរនេះរឿយៗមកឃើញថាជាប្រយោជន៍ច្រើនសម្រាប់អ្នកសិក្សាព្រះវិន័យ ទើបកាលពី ព.ស.២៥៤៨ ខ្ញុំឆ្លៀតឱកាសអំពីការសិក្សានៅពុទ្ធិកវិទ្យាល័យ **ព្រះសុរាម្រឹត** ជាសាលាបាលីជាន់ខ្ពស់នាទីក្រុងភ្នំពេញ ប្រែគម្ពីរនេះពីបាលិភាសាមកជាខេមរភាសាតែម្ដង ដើម្បីងាយស្រួលក្នុងការសិក្សារបស់ភិក្ខុ-សាមណេរអ្នកមិនចេះភាសាបាលី ។

តែការធ្វើរបស់ខ្ញុំពេលនោះ មិនបានម៉ត់ចត់ស្រួលបួលទេ ហើយក៏មិនបាននិមន្តលោកអ្នកចេះដឹងឱ្យជួយពិនិត្យដែរ

ព្រោះចុងឆ្នាំនោះ ខ្ញុំត្រូវទៅបន្តការសិក្សានៅប្រទេសស្រីលង្កា តែដោយតម្រូវការចាំបាច់ ទើបខ្ញុំខំវាយអត្ថបទ និងរៀបរៀងបានប៉ុណ្ណោះ ប្រគល់ទៅសព្រហ្មចារីភិក្ខុ **អគ្គជីវោ** គង់ សុមិត្តវត្ត និគ្រោធវ័ន ឱ្យលោកជួយចាត់ចែងផង ។ លោកក៏បានគ្រាន់តែធ្វើជាកូនសៀវភៅថតចម្លងចែកគ្នារៀនប៉ុណ្ណោះ មិនទាន់បានបោះពុម្ពជាផ្លូវការទេ ។

ពេលវេលា១០ ឆ្នាំកន្លងទៅយ៉ាងឆាប់រហ័សសឹងតែមួយប៉ប្រិចភ្នែកប៉ុណ្ណោះ ខ្ញុំបានឃើញការសន្ទនាគ្នាអំពីព្រះវិន័យ ក្នុងបណ្ដាញសង្គមទំនើប Facebook រវៀងធម្មវាទី និងអធម្មវាទីភិក្ខុអំពីភិក្ខុសំពះគ្រហស្ថដូចដែលអ្នកបួសមួយចំនួនធ្វើសព្វថ្ងៃ។ អធម្មវាទីពោលថា ការសំពះនេះជាសុជីវធម៌ល្អមួយ ដូច្នេះមិនត្រូវអាបត្តិទេ មិនឃើញមានក្នុងវិន័យទេ ។ ឯធម្មវាទី ពោលថា មិនសមគួរនឹងសំពះគ្រហស្ថដូច្នេះទេព្រោះមានព្រះពុទ្ធដីកាទ្រង់ហាមក្នុងព្រះវិន័យបិដក តែមិនដឹងក្នុងភាគណាមួយទេ ។

ដោយឃើញធម្មវាទីភិក្ខុមិនមានគោលអាងយ៉ាងនេះ ទើបធ្វើឱ្យខ្ញុំនឹកឃើញដល់គម្ពីរមូលសិក្ខា របស់ខ្ញុំនេះតែម្ដង ថា បើលោកបានអានគម្ពីរនេះ លោកនឹងមានគោលអាងច្បាស់លាស់ ទោះបីមិនបានអានព្រះវិន័យបិដកក៏ដោយចុះ ។

អាស្រ័យហេតុមានប្រមាណប៉ុណ្ណោះ ទើបខ្ញុំព្យាយាមសរសេរ និងពិនិត្យសៀវភៅនេះម្ដងទៀត ដែលឃើញថា នៅ

មានកំហុសដោយអចេតនាជាច្រើនអន្លើហើយខ្ញុំបានស្រាវជ្រាវដាក់បន្ថែមគ្រប់ទំព័រប្រាប់លេខយោងព្រះត្រៃបិដក ដែលមានសម្ដែងដល់សិក្ខាបទនោះ ៗ ទៀតផង ដើម្បីងាយស្រួលដល់សិក្ខាកាមទៅប៉ើងមើលដល់ព្រះពុទ្ធដីកា ។

គម្ពីរនេះ ខ្ញុំចំណាយពេលតែ ១៥ ថ្ងៃប៉ុណ្ណោះ ក្នុងការបកប្រែ តែចំណាយពេលច្រើនក្នុងការស្រាវជ្រាវរកសេចក្ដីក្នុងព្រះបាលីព្រះពុទ្ធដីកា ។ ហេតុនេះ បុណ្យណាដែលកើតចេញពីវិរិយភាព និងការស្រឡាញ់ព្រះសាសនារបស់ខ្ញុំឯណា សូមឱ្យសព្វសត្វទាំងពួង បាននូវចំណែកបុណ្យនោះ របស់ខ្ញុំនោះផងចុះ! សូមបានក្រេបនូវរសនៃអមតៈក្នុងកាលដ៏ឆាប់ខាងមុខកុំខាន!

ខ្ញុំសូមទទួលដោយរីករាយនូវរាល់ការរិះគន់ស្ថាបនា ពីសំណាក់វេយ្យាករណបណ្ឌិតទាំងឡាយ !!!

សូមឱ្យព្រះពុទ្ធសាសនាឋិតថេរអស់កាលដ៏យូរចុះ!

មណ្ឌលវប្បធម៌ខ្មែរនៅស្វីស វត្ត សង្ឃារាម ប្រទេសស្វីស

ថ្ងៃចន្ទ ១៣ កើត ខែបុស្ស ព.ស.២៥៥៧ 13.01.2014

ភិក្ខុ **ធម្មសិរី** សែម ចន្ទធីរ៍

## នាមលោកអ្នកជួយពិនិត្យ

១. ព្រះភិក្ខុ **វិមលពុទ្ធិ** ទី ប៊ុនថា ចៅអធិការវត្តស្វីសខេមរារាម

២. ព្រះភិក្ខុ **ធម្មបញ្ញោ** ស៊ឹម សំអួន ប្រធានពុទ្ធិកសមាគមសមណៈនិស្សិតកម្ពុជា-ស្រីលង្កា និងជានិស្សិតថ្នាក់បណ្ឌិតនៅសាកលវិទ្យាល័យ កល្យាណី ប្រទេសស្រីលង្កា

៣. ភិក្ខុ **អគ្គវង្សោ** ឃឹម ជីមី អនុបណ្ឌិតទស្សនវិជ្ជាពុទ្ធសាសនា

៤.ឧបាសិកា ម៉ម នរម កែសេចក្តីផ្ទៀងនឹងបាលី

៥. ឧបាសក មាស សុខ ជួយកែអក្ខរាវិរុទ្ធ

## សៀវភៅដែលខ្ញុំធ្លាប់ចេញផ្សាយ

១. សីលមយញ្ញាណកថា ២០០២

២. កង្ខាវិតរណី ភាគ ១ ភាគ ២ ២០០៣

៣. សរណកថា និងប្រវត្តិពោធិព្រឹក្សស្រីលង្កា ២០០៤

៤. មូលសិក្ខា មូលសិក្ខា -ដីកា ២០០៤

៥. ឯកសារបង្រៀនអំពីកម្មបទ ១០ ២០០៤

៦. បូជនីយដ្ឋានដែនកោះលង្កា ២០០៩

៧. អានុភាពត្រៃរតន៍ បទព្រហ្មគីតិ ២០១៣

## សៀវភៅដែលនឹងចេញផ្សាយ

១. សក្កទេវរាជ ក្នុងបុព្វហេតុ ស្វែងរកទីពឹងដ៏ប្រសើរ កំណាព្យ

២. ប្រជុំរឿងផ្សេងៗ ភាគ ១ ដល់ ភាគ ៣

៣. កិន្នរីភក្តីស្នេហ៍ ពាក្យកាព្យចំរុះ

សមាសភាពគណកម្មការនិពន្ធ

នៃ

ពុទ្ធិកសមាគមសមណនិស្សិត កម្ពុជា–ស្រីលង្កា

១. ព្រះមហា ធម្មប្បញ្ញោ ស៊ីម សំអួន ប្រធាន
២. ព្រះមហា ធម្មសិរី សែម ចន្ទធីរ៍ ប្រធានអប់រំ នៅស្វីស
៣. ព្រះមហា អ៊ឹម ហុង សមាជិក
៤. ព្រះមហា យ៉ាង ឃួត សមាជិក
៥. ព្រះមហា តបរតោ ដៀង ស៊ីថុល សមាជិក
៦. ព្រះមហា ឧបតិស្សោ គង់ ច័ន្ទសុភ័ក្ត្រ សមាជិក
៧. ព្រះមហា ធម្មកោវិទូ ធី ចាន់ណា សមាជិក

# សន្លឹកចន្ទុលប្រាប់មាតិកា

# មូលសិក្ខា


| | |
|---|---|
| ១. គន្ថារម្ភកថា | ១ |
| ២. បារាជិកនិទ្ទេស | ២ |
| ៣. គរុកាបត្តិនិទ្ទេស | ៥ |
| ៤. និស្សគ្គិយនិទ្ទេស | ៧ |
| ៥. បាចិត្តិយនិទ្ទេស | ១១ |
| ៦. បកិណ្ណកនិទ្ទេស | ១៩ |
| ៧. វត្តាទិកណ្ឌនិទ្ទេស | ៣៣ |


# មូលសិក្ខា ដីកា


| | |
|---|---|
| ១. គន្ថារម្ភកថាវណ្ណនា | ៤៨ |
| ២. បារាជិកនិទ្ទេសវណ្ណនា | ៥៥ |
| ៣. គរុកាបត្តិនិទ្ទេសវណ្ណនា | ៧២ |
| ៤. និស្សគ្គិយនិទ្ទេសវណ្ណនា | ៨៩ |
| ៥. បាចិត្តិយនិទ្ទេសវណ្ណនា | ១១៣ |
| ៦. បកិណ្ណកនិទ្ទេសវណ្ណនា | ១៤១ |
| ៧. វត្តាទិកណ្ឌនិទ្ទេសវណ្ណនា | ១៧១ |
| និគមនកថា | ១៧៨ |

## ។ នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

# មូលសិក្ខា

## គន្ថារម្ភកថា

នត្វា នាថំ បវក្ខាមិ មូលសិក្ខំ សមាសតោ
ភិក្ខុនា នវកេនាទោ មូលភាសាយ សិក្ខិតុំ ។

### ១. បារាជិកនិទ្ទេសោ

១. សំ និមិត្តំ បវេសន្តោ ភិក្ខុ មគ្គត្តយេ ចុតោ
បវេសនដ្ឋិតុទ្ធារ- បវិដ្ឋេ ចេបិ សាទិយំ ។
២. អទិន្នំ មានុសំ ភណ្ឌំ ថេយ្យាយេកេន អាទិយំ
បញ្ចវីសាវហារេសុ គរុកំ ចេ ចុតោ ភវេ ។
៣. អាទិយន្តោ ហរន្តោវ- ហរន្តោបិរិយាបថំ
វិកោបេន្តោ តថា ឋានា ចាវេន្តោបិ បរាជិកោ ។
៤. តត្ថ នានេកភណ្ឌានំ បញ្ចកានំ វសា បន
អវហារា ទសញ្ចេតិ វិញ្ញាតព្វា វិភាវិនា ។

# មូលសិក្ខា
# គន្ថារម្ភកថា

ខ្ញុំព្រះករុណា ឈ្មោះ **មហាសាមិត្តេរ** សូមលំឱនកាយថ្វាយបង្គំ ចំពោះព្រះលោកនាថ ហើយសូមពោលនូវគម្ពីរ **មូលសិក្ខា** ដោយបំព្រួញ ដើម្បីភិក្ខុខ្លី បានសិក្សា ក្នុងគ្រាដំបូងដោយមូលភាសា ។

## ១. បារាជិកនិទ្ទេស

១. ភិក្ខុកាលបញ្ចូលនូវនិមិត្តនោះ ឲ្យពាល់ត្រូវនូវប្រជុំ ៣ នៃមគ្គ ថាបើ មានសេចក្តីត្រេកអរ ក្នុងកាលដែលបញ្ចូលទៅ តាំងនៅ ដកមកវិញ និងការចូលទៅស៊ប់ហើយ (នៃអង្គជាត) ។

២. ប្រសិនបើ ភិក្ខុកាន់យកនូវភណ្ឌៈជារបស់មនុស្ស ដែលគេមិនបានឲ្យ ដោយចំណែកមួយនៃចិត្តលួច ក្នុងអវហារទាំង ២៥ រមែងជាអ្នកពាល់ត្រូវគរុកាបត្តិ (អាបត្តិបារាជិក) ។

៣. ភិក្ខុសូម្បីកាលកាន់យក ឬនាំយកទៅ លួចយកទៅ ញុំាងឥរិយាបថឲ្យកម្រើក ញុំាងវត្ថុឲ្យឃ្លាតចាកទី ដោយប្រការដូច្នោះ ក៏ជាបារាជិកដែរ ។

៤. បណ្តាប្រយោគនៃការលួចទាំង ៥ យ៉ាងនោះ អវហារ គឺបណ្ឌិតគប្បីដឹងច្បាស់ថា មាន ១០ ព្រោះនានាភណ្ឌបញ្ចកៈ និងឯកភណ្ឌបញ្ចកៈ ។

៥. សាហត្ថាណត្តិកោ ចេវ និស្សគ្គោ ហត្ថសាធកោ
ធុរនិក្ខេបនញ្ចេវ ឥទំ សាហត្ថបញ្ចកំ ។

៦. បុព្វសហប្បយោគោ ច សំវិធាហរណម្បិ ច
សង្កេតកម្មំ និមិត្តំ បុព្វប្បយោគបញ្ចកំ ។

៧. ថេយ្យបសយ្ហបរិកប្ប-ប្បដិច្ឆន្នកុសាទិកា
អវហារា ឥមេ បញ្ច វិញ្ញាតព្វា វិភាវិនា ។

៨. មនុស្សបាណំ បាណោតិ ជានំ វធកចេតសា
ជីវិតា យោ វិយោជេតិ សាសនា សោ បរាជិតោ។

៩. ឈានាទិភេទំ ហទយេ អសន្តំ
អញ្ញាបទេសញ្ច វិនាធិមានំ
មនុស្សជាតិស្ស វទេយ្យ ភិក្ខុ
ញាតក្ខណេ តេន បរាជិកោ ភវេតិ ៕

៥. សាហត្ថិកបញ្ចកៈ(មាន ៥ )នេះ គឺ សាហត្ថិកៈ ១ អាណត្តិកៈ ១ និស្សគ្គិយៈ ១ អត្ថសាធកៈ ១ ធុរនិក្ខេបៈ ១ ។

៦. បុព្វប្បយោគបញ្ចកៈ មាន ៥ គឺ បុព្វប្បយោគ ១ សហប្បយោគ ១ សំវិធាហរណៈ ១ សង្កេតកម្ម ១ និមិត្តកម្ម ១ ។

៧. អវហារទាំងឡាយ ៥ មានថេយ្យាវហារ ១ បសយ្ហាវហារ ១ បរិកប្បាវហារ ១ បដិច្ឆន្នាវហារ ១ និងកុសាវហារ ១ ជាដើមនេះ គឺបណ្ឌិតគប្បីសម្តែងបំភ្លឺ ។

៨. ភិក្ខុឯណា កាលដឹងសត្វមានជាតិជាមនុស្សថា ជាសត្វ ហើយមានវធកចិត្ត តែងផ្តាច់ចាកជីវិត ភិក្ខុនោះ ឈ្មោះថា ចាលចាញ់ចាកព្រះសាសនា ។

៩. ភិក្ខុពោលនូវគុណធម៌ ផ្សេងដោយគុណមានឈានជាដើម ដែលមិនមានពិតនៅក្នុងចិត្ត (ខ្លួន) វៀរលែងតែមានគ្រឿងអាងដទៃ និងវៀរលែងតែមានពិត ចំពោះមនុស្សជាតិ ភិក្ខុនោះជាបរាជិក ក្នុងខណៈដែលដឹងតែម្តង ដូច្នេះឯង ៕

## ២. គរុកាបត្តិនិទ្ទេសោ

១០. មោចេតុកាមចិត្តេន ឧបក្កម្ម វិមោចយំ
សុក្កមញ្ញត្រ សុបិនា សមណោ គរុកំ ផុសេ ។

១១. កាយសំសគ្គរាគេន មនុស្សិត្ថឹ បរាមសំ
ឥត្ថិសញ្ញី ឧបក្កម្ម សមណោ គរុកំ ផុសេ ។

១២. ទុដ្ឋុល្លវាចស្សាទេន មគ្គំ វារព្ភ មេថុនំ
ឱភាសន្តោ មនុស្សិត្ថឹ សុណមានំ គរុំ ផុសេ ។

១៣. វណ្ណំ វត្វាត្តនោកាម- បារិចរិយាយ មេថុនំ
ឥត្ថឹ មេថុនរាគេន យាចមានោ គរុំ ផុសេ ។

១៤. សន្ទេសំ បដិគ្គណ្ហិត្វា បុរិសស្សិត្ថិយាបិ វា
វីមំសិត្វា ហរំ បច្ចា សមណោ គរុកំ ផុសេ ។

១៥. ចាវេតុកាមោ ចោទេន្តោ អមូលន្តិមវត្ថុនា
ចោទាបយំ វា សមណោ សុណមានំ គរុំ ផុសេ ។

១៦. លេសមត្តំ ឧបាទាយ អមូលន្តិមវត្ថុនា
ចាវេតុកាមោ ចោទេន្តោ សុណមានំ គរុំ ផុសេតិ ៕

## ២. គរុកាបត្តិនិទ្ទេស

១០. សមណៈមានចិត្តចង់បញ្ចេញ ព្យាយាមបញ្ចេញនូវទឹកសុក្កៈ វៀរលែងតែយល់សប្តិ រមែងត្រូវនូវគរុកាបត្តិ (សង្ឃាទិសេស)។

១១. សមណៈមានចិត្តត្រេកអរក្នុងការស្ទាបអង្អែលកាយ (ស្ត្រី) សម្គាល់ថា ស្ត្រី ព្យាយាមប៉ះពាល់នូវមនុស្សស្រី ត្រូវគរុកាបត្តិ ។

១២. សមណៈមានតម្រេកក្នុងការពោលពាក្យអាក្រក់ បានប្រារព្ធនូវមគ្គ ហើយពោលបង្កាប់នូវមេថុនចំពោះមនុស្សស្រី ដែលគួរស្តាប់បាន ត្រូវគរុកាបត្តិ ។

១៣. សមណៈកាលពោលនូវគុណនៃការបម្រើខ្លួនដោយកាម ហើយសុំនូវមេថុន ចំពោះស្ត្រី ដោយមេថុនរាគ ត្រូវគរុកាបត្តិ ។

១៤. សមណៈទទួលនូវពាក្យបណ្តាំ របស់បុរសក្តី ឬស្ត្រីក្តី ហើយទៅនិយាយល្បួងមើល រួចត្រឡប់មកប្រាប់វិញ ត្រូវគរុកាបត្តិ ។

១៥. សមណៈមានបំណងចង់ឲ្យឃ្លាត (ចាកសាសនា) ក៏ចោទដោយខ្លួនឯងក្តី ប្រើគេឲ្យចោទក្តី ដោយអន្តិមវត្ថុ ដែលមិនមានមូលចំពោះសមណៈផងគ្នា ដែលកំពុងស្តាប់បាន ត្រូវគរុកាបត្តិ ។

១៦. សមណៈមានបំណងចង់ឲ្យឃ្លាត (ចាកសាសនា) ក៏កាន់យកលេសបន្តិចបន្តួច ចោទសមណៈផងគ្នា ដែលកំពុងស្តាប់បាន ដោយអន្តិមវត្ថុដែលមិនមានមូល ត្រូវគរុកាបត្តិ ដូច្នោះឯង ៕

## ៣. និស្សគ្គិយនិទ្ទេសោ

១៧. វិកប្បនមធិដ្ឋាន- មកត្វា កាលចីវរំ
ទសាហមតិមាបេតិ តស្ស និស្សគ្គិយំ សិយា ។

១៨. ភិក្ខុសម្មុតិយាញ្ញត្រ តិចីវរមធិដ្ឋិតំ
ឯកាហមតិមាបេតិ និស្សគ្គិ សមយំ វិនា ។

១៩. អញ្ញាតិកា ភិក្ខុនិយា បុរាណចីវរំ បន
ធោវាបេតិ រជាបេតិ អាកោដាបេតិ តំ សិយា ។

២០. អញ្ញាតិកា ភិក្ខុនិយា ហត្ថតោ កិញ្ចិ មូលកំ
អទត្វា ចីវរាទានេ និស្សគ្គិយមុទីរិតំ ។

២១. អប្បវារិតមញ្ញាតិំ វិញ្ញាបេន្តស្ស ចីវរំ
អញ្ញត្រ សមយា តស្ស និស្សគ្គិយមុទីរិតំ ។

២២. រជតំ ជាតរូបំ វា មាសកំ វា កហាបណំ
គណ្ហេយ្យ វា គណ្ហាបេយ្យ និស្សគ្គិ សាទិយេយ្យ វា ។

២៣. បរិវត្តេយ្យ និស្សគ្គិ រជតាទិ ចតុព្វិធំ
កប្បិយំ កប្បិយេនាបិ ឋបេត្វា សហធម្មិកេ ។

# ៣. និស្សគ្គិយនិទ្ទេស

១៧. ភិក្ខុមិនធ្វើការវិកប្ប ឬអធិដ្ឋាន ហើយញុំាំងអកាលចីវរឲ្យកន្លងហួស ១០ ថ្ងៃទៅ ត្រូវនិស្សគ្គិយបាចិត្តិយ ។

១៨. ភិក្ខុញុំាំងត្រៃចីវរដែលបានអធិដ្ឋានឲ្យកន្លង ១ រាត្រីទៅ លើកលែងតែភិក្ខុដែលសង្ឃសម្មតិ ត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងតែមានសម័យ ។

១៩. ក៏ឯភិក្ខុណា ប្រើនាងភិក្ខុនីមិនមែនជាញាតិ ឲ្យលាង ឲ្យជ្រលក់ ឲ្យបោកនូវចីវរចាស់ ចីវរនោះ ជានិស្សគ្គិយ ។

២០. ភិក្ខុមិនបានឲ្យវត្ថុអ្វីមួយជាថ្នូរ ហើយកាន់យកចីវរ អំពីដៃនាងភិក្ខុនីមិនមែនជាញាតិ បណ្ឌិតហៅចីវរនោះថា ជានិស្សគ្គិយ

២១. ភិក្ខុកាលសុំចីវរចំពោះជនដែលមិនបានបវារណា និងមិនមែនជាញាតិ វៀរលែងតែមានសម័យ បណ្ឌិតហៅចីវរនោះថា ជានិស្សគ្គិយ ។

២២. ភិក្ខុទទួលខ្លួនឯងក្តី ប្រើគេឲ្យទទួលក្តី នូវមាសក្តី ប្រាក់ក្តី មាសកៈក្តី កហាបណៈក្តី ឬមួយត្រេកអរចំពោះមាសនិងប្រាក់ មាសកៈនិងកហាបណៈ ដែលគេទុកដាក់សម្រាប់ខ្លួនក្តី រមែងជានិស្សគ្គិយ ។

២៣. ភិក្ខុផ្លាស់ប្តូរនូវអកប្បិយវត្ថុ ៤ យ៉ាង មានមាសជាដើមក្តី នូវកប្បិយវត្ថុដោយកប្បិយវត្ថុ លើកទុកតែសហធម្មិកទាំង ៥ ក្តី រមែងជានិស្សគ្គិយ ។

២៤. វិកប្បនមធិដ្ឋាន- មកត្វាន បមាណិកំ
ទសាហមតិមាបេតិ បត្តំ និស្សគ្គិយំ សិយា ។

២៥. បញ្ចពន្ធនតោ ឩន- បត្តេ សតិ បរំ បន
វិញ្ញាបេតិ នវំ បត្តំ តស្ស និស្សគ្គិយំ សិយា ។

២៦. បដិគ្គហេត្វា ភុញ្ជន្តោ សប្បិតេលាទិកំ បន
សត្តាហមតិមាបេតិ តស្ស និស្សគ្គិយំ សិយា ។

២៧. ភិក្ខុស្ស ចីវរំ ទត្វា អច្ឆិន្ទន្តស្ស តំ បុន
សកសញ្ញាយ និស្សគ្គិ អច្ឆិន្ទាបយតោបិ វា ។

២៨. អប្បវារិតមញ្ញាតិំ សុត្តំ យាចិយ ចីវរំ
វាយាបេន្តស្ស និស្សគ្គិ វិនា ញាតិប្បវារិតេ ។

២៩. ជានន្តោ ភិក្ខុ សង្ឃស្ស លាភំ បរិណតំ បន
អត្តនោ បរិណាមេតិ តស្ស និស្សគ្គិយំ សិយាតិ៕

២៤. ភិក្ខុមិនធ្វើការវិកប្ប ឬអធិដ្ឋានហើយញ៉ាំងបាត្រប្រកប ដោយប្រមាណឲ្យកន្លងហួស ១០ ថ្ងៃទៅ ត្រូវអាបត្តិនិស្សគ្គិយ បាចិត្តិយ ។

២៥. ភិក្ខុមានបាត្រមានចំណាងមិនទាន់គ្រប់ ៥ អន្លើទេ តែទៅ សុំបាត្រថ្មីដទៃទៀត បាត្ររបស់ភិក្ខុនោះ ជានិស្សគ្គិយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

២៦. ក៏ភិក្ខុកាលទទួលហើយបរិភោគនូវភេសជ្ជៈមានទឹកដោះថ្លា និងប្រេងជាដើម ឲ្យកន្លងហួស ៧ ថ្ងៃទៅ ភេសជ្ជៈរបស់ភិក្ខុ នោះ ជានិស្សគ្គិយបាចិត្តិយ ។

២៧. ភិក្ខុកាលឲ្យចីវរដល់ភិក្ខុដទៃ ហើយដណ្ដើមយកដោយខ្លួន ឯងក្ដី ឲ្យគេដណ្ដើមយកក្ដី នូវចីវរនោះមកវិញ ដោយសម្គាល់ថា ជារបស់ខ្លួន រមែងជានិស្សគ្គិយបាចិត្តិយ ។

២៨. ភិក្ខុកាលសុំនូវអំបោះអំពីជនដែលមិនបានបវារណា និងជន ដែលមិនមែនជាញាតិ ហើយឲ្យជាងតម្បាញត្បាញចីវរ ត្រូវ និស្សគ្គិយបាចិត្តិយ លើកទុកតែសុំអំពីជនដែលបានបវារណា ឬជនដែលជាញាតិ ។

២៩. ក៏ភិក្ខុកាលដឹង តែងបង្អោននូវលាភដែលគេបង្អោនទៅ ចំពោះសង្ឃហើយ ឲ្យមកជារបស់ខ្លួនវិញ លាភរបស់ភិក្ខុនោះ ជានិស្សគ្គិយបាចិត្តិយ ដោយប្រការដូច្នោះឯង ៕

## ៤. បាចិត្តិយនិទ្ទេសោ

៣០. សម្បជានមុសាវាទេ បាចិត្តិយមុទីរិតំ
ភិក្ខុញ្ច ឱមសន្តស្ស បេសុញ្ញហរណេបិ ច ។

៣១. បវេត្វា ភិក្ខុនី ភិក្ខុំ អញ្ញេន បិដកត្តយំ
បទសោធម្មំ ភណន្តស្ស បាចិត្តិយមុទីរិតំ ។

៣២. អនុបសម្បន្នេនេវ សយិត្វាន តិរត្តិយំ
បាចិត្តិ សហសេយ្យាយ ចតុត្ថត្ថង្គតេ បុន ។

៣៣. ឥត្ថិយា ឯករត្តម្បិ សេយ្យំ កប្បយតោបិ វា
ទេសេន្តស្ស វិនា វិញ្ញុំ ធម្មញ្ច ឆប្បទុត្តរិំ ។

៣៤. ទុដ្ឋុល្លំ ភិក្ខុនោ វជ្ជំ ភិក្ខុសម្មុតិយា វិនា
អភិក្ខុនោ វទន្តស្ស បាចិត្តិយមុទីរិតំ ។

៣៥. ខណេយ្យ វា ខណាបេយ្យ បថវិញ្ច អកប្បិយំ
ភូតគាមំ វិកោបេយ្យ តស្ស បាចិត្តិយំ សិយា ។

៣៦. អញ្ញោកាសេ តុ មញ្ចាទឹ កត្វា សន្ថរណាទិកំ
សង្ឃិកំ យាតិ បាចិត្តិ អកត្វាបុច្ឆនាទិកំ ។

## ៤. បាចិត្តិយនិទ្ទេស

៣០. ភិក្ខុពោលកុហកទាំងដឹងខ្លួនក្តី ជេរប្រទេចភិក្ខុផងគ្នាក្តី ញាំនាំពាក្យញុះញង់ក្តី បណ្ឌិតពោលថា ត្រូវអាបត្តិបាចិត្តិយ ។

៣១. ភិក្ខុពោលនូវព្រះត្រៃបិដកជាធម៌បទ ជាមួយបុគ្គលដទៃ វៀរតែភិក្ខុនិងភិក្ខុនីចេញ បណ្ឌិតពោលថា ត្រូវអាបត្តិបាចិត្តិយ ។

៣២. ភិក្ខុដេកជាមួយអនុបសម្បន្នតែមួយ (នាក់ ឬមួយកន្លែង) អស់ ៣ រាត្រី កាលសុរិយាថ្ងៃទី ៤ អស្តង្គតទៅទៀត ត្រូវអាបត្តិបាចិត្តិយ ព្រោះដេករួមគ្នា ។

៣៣. ម្យ៉ាងវិញទៀត ភិក្ខុកាលសម្រេចការដេក សូម្បីអស់រាត្រីមួយជាមួយស្ត្រីក្តី សម្តែងធម៌លើសពី ៦ ម៉ាត់ឡើងទៅជាមួយស្ត្រី វៀរតែមានបុរសដឹងក្តីនៅជាមួយក្តី ។

៣៤. ភិក្ខុកាលប្រាប់ទោសដ៏អាក្រក់របស់ភិក្ខុផងគ្នា ដល់បុគ្គលដែលមិនមែនជាភិក្ខុ វៀរទុកតែភិក្ខុដែលបានសម្មតិចេញ បណ្ឌិតពោលថា ត្រូវអាបត្តិបាចិត្តិយ ។

៣៥. ភិក្ខុជីកខ្លួនឯងក្តី ប្រើគេឲ្យជីកក្តី កំទេចក្តី នូវបឋវីក្តី ភូតគាមក្តី ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

៣៦. ចំណែកឯភិក្ខុធ្វើកិច្ចមានកិរិយាក្រាលដោយខ្លួនឯងជាដើម នូវសេនាសនៈមានគ្រែជាដើម ដែលជារបស់សង្ឃ ក្នុងទីកណ្តាលវាល ហើយមិនបានធ្វើនូវកិច្ចមានកិរិយាប្រាប់គេជាដើមសោះ ស្រាប់តែដើរចេញទៅ ត្រូវអាបត្តិបាចិត្តិយ ។

៣៧. សង្ឃិកាវាសេ សេយ្យំ កត្វា សន្ថរណាទិកំ
អកត្វាបុច្ឆនាទិំ យោ យាតិ បាចិត្តិ តស្សបិ ។

៣៨. ជានំ សប្បាណកំ តោយំ បាចិត្តិ បរិភុញ្ជតោ
អញ្ញាតិកា ភិក្ខុនិយា ឋបេត្វា បារិវត្តកំ ។

៣៩. ចីវរំ ទេតិ បាចិត្តិ ចីវរំ សិព្វតោបិ ច
អតិរិត្តំ អការេត្វា បវារេត្វាន ភុញ្ជតោ ។

៤០. ភិក្ខុំ អាសាទនាបេក្ខោ បវារេតិ បវារិតំ
អនតិរិត្តេន ភុត្តេ តុ បាចិត្តិយមុទីរិតំ ។

៤១. សន្និធិភោជនំ ភុញ្ជេ វិកាលេ យាវកាលិកំ
ភុញ្ជតោ វាបិ បាចិត្តិ អគិលានោ បណីតកំ ។

៤២. វិញ្ញាបេត្វាន ភុញ្ជេយ្យ សប្បិភត្តាទិកម្បិ ច
អប្បដិគ្គហិតំ ភុញ្ជេ ទន្តកដ្ឋោទកំ វិនា ។

៤៣. តិត្ថិយស្ស ទទេ កិញ្ចិ ភុញ្ជិតព្វំ សហត្ថតោ
និសជ្ជំ វារហោ កប្បេ មាតុគាមេន ឯកតោ ។

៣៧. ភិក្ខុណា ធ្វើនូវកិច្ចមានការក្រាលដោយខ្លួនឯងជាដើម នូវកម្រាលសម្រាប់ដេក ក្នុងអាវាសជាទីនៅរបស់សង្ឃ ហើយមិនធ្វើកិច្ចមានការប្រាប់គេជាដើម ហើយដើរចេញទៅ ភិក្ខុនោះក៏ត្រូវអាបត្តិបាចិត្តិយដែរ ។

៣៨. ភិក្ខុកាលដឹងហើយ បរិភោគទឹកដែលមានសត្វក្តី ភិក្ខុតាំងទុកវត្ថុសម្រាប់ផ្លាស់ប្តូរហើយ (ឲ្យចីវរ) ដល់នាងភិក្ខុនីមិនមែនជាញាតិ(ក្តី) ត្រូវអាបត្តិបាចិត្តិយ ។

៣៩. ភិក្ខុឲ្យចីវរ (ដល់ភិក្ខុនីមិនមែនជាញាតិ)ក្តី ដេរចីវរ (ឲ្យភិក្ខុនីមិនមែនជាញាតិ)ក្តី ហាមភត្តហើយមិនឲ្យគេធ្វើឲ្យជារបស់សមគួរហើយបរិភោគ(អនតិរិត្តភោជន)ក្តី ត្រូវអាបត្តិបាចិត្តិយ ។

៤០. ចំណែកឯភិក្ខុរំពៃរកទោស ក៏បវារណាបង្ខំភិក្ខុដែល(ឆាន់ហើយ) ហាមភត្តហើយ ដោយអនតិរិត្តភោជន និមិត្តតែភិក្ខុនោះឆាន់ហើយ លោកពោលថា ត្រូវអាបត្តិបាចិត្តិយ ។

៤១. ភិក្ខុបរិភោគភោជនដែលធ្វើការសន្សំ ឬបរិភោគវត្ថុជាយាវកាលិកក្នុងពេលខុស ឬក៏គ្មានជម្ងឺសុំភោជនដ៏ប្រណីតមានសប្បិជាដើម ហើយឆាន់ ។

៤២. មួយទៀត ភិក្ខុបរិភោគភោជនដែលខ្លួនមិនបានទទួលប្រគេន វៀរលែងតែទឹក និងឈើស្ទន់ ត្រូវអាបត្តិបាចិត្តិយ ។

៤៣. ភិក្ខុឲ្យវត្ថុតិចតួច ដែលគួរបរិភោគដល់ពួកតិរ្ថិយ ដោយខ្លួនឯង ឬសម្រេចការអង្គុយក្នុងទីស្ងាត់តែមួយជាមួយមាតុគ្រាម ។

៤៤. សុរាមេរយបានេបិ បាចិត្តិយមុទីរិតំ
អង្គុលិបតោទកេ ចាបិ ហាសធម្មេបិ ចោទកេ ។

៤៥. អនាទរេបិ បាចិត្តិ ភិក្ខុំ ភីសយតោបិ វា
ភយានកំ កថំ កត្វា ទស្សេត្វា វា ភយានកំ ។

៤៦. ឋបេត្វា បច្ចយំ កិញ្ចិ អគិលានោ ជលេយ្យ វា
ជោតឹ ជលាបយេយ្យាបិ តស្ស បាចិត្តិយំ សិយា ។

៤៧. កប្បពិន្ទុមនាទាយ នវចីវរភោគិនោ
ហសាបេក្ខស្ស បាចិត្តិ ភិក្ខុនោ ចីវរាទិកំ ។

៤៨. អបនេត្វា និធេន្តស្ស និធាបេន្តស្ស វា បន
ជានំ បាណំ មារេន្តស្ស តិរច្ឆានគតម្បិ ច ។

៤៩. ឆាទេតុកាមោ ឆាទេតិ ទុដ្ឋុល្លំ ភិក្ខុនោបិ ច
គាមន្តរគតស្សាបិ សំវិធាយិត្ថិយា សហ ។

៥០. ភិក្ខុំ បហរតោ វាបិ តលសត្តិកមុគ្គិរេ
ចោទេតិ វា ចោទាបេតិ គរុកាមូលកេនបិ ។

៤៤. និងព្រោះភិក្ខុផឹកទឹកស្រវឹង គឺសុរានិងមេរ័យ ១ ចាក់ក្រឡេកគ្នាដោយប្រើជន្លួញ គឺម្រាមដៃ ១ លេងទឹក ១ បណ្ឌិតពោលថា ត្រូវអាបត្តិបាចិត្តិយ ។

៤៥. ព្រោះភិក្ខុមិនអើពើក្តី ព្រោះពោលកថានាំឲ្យភ័យខ្លាច ឬយករូបដែលគួរឲ្យភ័យខ្លាច មកបន្លាចភិក្ខុផងគ្នាឲ្យភ័យខ្លាចក្តី ត្រូវអាបត្តិបាចិត្តិយ ។

៤៦. ភិក្ខុគ្មានជម្ងឺបង្កាត់ភ្លើងអាំងដោយខ្លួនឯងក្តី ប្រើគេឲ្យបង្កាត់ក្តី ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានហេតុណាមួយ ។

៤៧. ភិក្ខុកាលប្រើប្រាស់នូវចីវរថ្មី មិនបានធ្វើពិន្ទុកប្បក្តី ប្រាថ្នាដើម្បីលេងសើច លួចយកបរិក្ខារមានចីវរជាដើម (របស់សហធម្មិកណាមួយ) លាក់ទុកខ្លួនឯង ឬប្រើគេឲ្យលាក់ទុកក្តី ។

៤៨. មួយទៀត ភិក្ខុកាលដឹងហើយ ញុំាំងសត្វមានជីវិត គឺពួកសត្វតិរច្ឆានឲ្យស្លាប់ក្តី ត្រូវអាបត្តិបាចិត្តិយ ។

៤៩. ភិក្ខុប្រាថ្នាដើម្បីបិទបាំងទុដ្ឋុល្លាបត្តិរបស់ភិក្ខុផងគ្នាក្តី ភិក្ខុបបួលគ្នាធ្វើដំណើរតាមផ្លូវតែមួយជាមួយស្ត្រី ដោយហោចទៅសូម្បីអស់ចន្លោះស្រុកមួយក្តី ។

៥០. ម្យ៉ាងទៀត ព្រោះវាយភិក្ខុផងគ្នាក្តី ងាឡើងនូវលំពែង គឺបាតដៃ (ចំពោះភិក្ខុ) ក្តី ចោទដោយខ្លួនឯង ឬប្រើឲ្យគេចោទដោយគរុកាបត្តិមិនមានមូលក្តី ។

៤១. កុក្កុច្ចុប្បាទនេ ចាបិ ភណ្ឌនត្ថាយុបស្សុតឹ

សោតុំ ភណ្ឌនជាតានំ យាតិ បាចិត្តិយំ សិយា ។

៤២. សង្ឃស្ស លាភំ បរិណាមិតំ តុ

នាមេតិ យោ តំ បរបុគ្គលស្ស

បុប្ផំ អកត្វាបិ ច សន្តកិច្ចំ

បាចិត្តិ តាមស្ស គតេ វិកាលេតិ ៕

៥១. ព្រោះភិក្ខុញ៉ាំងសេចក្ដីសង្ស័យឲ្យកើតឡើងក្ដី កាលភិក្ខុ-ទាំងឡាយកំពុងមានសេចក្ដីប្រកួតប្រកាន់គ្នា ទៅឈរអែបចាំស្ដាប់ដោយបំណងចង់បង្កសេចក្ដីប្រកួតប្រកាន់ក្ដី ត្រូវអាបត្តិ-បាចិត្តិយ ។

៥២. ចំណែកខាងលាភដែលគេបង្អោនទៅចំពោះសង្ឃហើយ ភិក្ខុណាមួយ បង្អោនលាភនោះ ដល់បុគ្គលដទៃវិញក្ដី (ភិក្ខុណា) កាលនឹងចូលទៅកាន់ស្រុកក្នុងវេលាវិកាល មិនបានប្រាប់ភិក្ខុដែលមាននៅក្ដី (ភិក្ខុទាំងនោះ) ត្រូវអាបត្តិបាចិត្តិយ ៕

# ៥. បកិណ្ណកនិទ្ទេសោ

៤៣. សង្ឃិកំ គរុភណ្ឌំ យោ ទេតិ អញ្ញស្ស នស្សរោ
ថុល្លច្ចយំ យថាវត្ថុំ ថេយ្យា បារាជិកាទិបិ ។

៤៤. កុសាទិមយចីរានិ កម្ពលំ កេសវាលជំ
សមយំ វិនា ធារយតោ លូកបក្ខាជិនក្ខិបំ ។

៤៥. សត្ថកម្មេ វត្ថិកម្មេ សំ និមិត្តញ្ច ឆិន្ទតោ
ថុល្លច្ចយំ មនុស្សានំ មំសាទិភោជនេបិ វា ។

៤៦. កទលេរកទុស្សានិ បោត្ថកំ សព្វនីលកំ
សព្វបីតាទិកញ្ចាបិ ធារយន្តស្ស ទុក្កដំ ។

៤៧. ហត្ថិស្សុរគសោណានំ សីហព្យគ្ឃច្ឆទីបិនំ
តរច្ឆស្ស ច មំសាទឹ ឧទ្ទិស្សកតកម្បិ ច ។

៤៨. អនាបុច្ឆិតមំសញ្ច ភុញ្ជតោ ទុក្កដំ សិយា
យាតានុបុព្វំ ហិត្វាន ទកតិត្ថាទិកំ វជេ ។

# ៥. បកិណ្ណកនិទ្ទេស

៥៣. ភិក្ខុណាមួយ ជាឥស្សរៈ ឱ្យរបស់ជាគរុភ័ណ្ឌ ដែលជារបស់នៃសង្ឃ ដល់បុគ្គលដទៃ ភិក្ខុនោះ ត្រូវអាបត្តិថុល្លច្ច័យ ។ បើឱ្យដោយចិត្តលួច វិន័យធរគប្បីពិន័យអាបត្តិ មានបារាជិកជាដើម តាមវត្ថុ។

៥៤. វៀរលែងតែមានសម័យ ភិក្ខុទ្រទ្រង់សំពត់ សម្រេចដោយវត្ថុមានស្បូវភ្លាំងជាដើម សម្ពត់កម្ពលត្បាញអំពីសក់ និងរោមកន្ទុយសត្វ សម្ពត់ដែលត្បាញដោយស្លាបមៀមនិងស្បែកខ្លាក្តី។

៥៥. ព្រោះភិក្ខុធ្វើសត្ថកម្មក្តី វត្ថិកម្មក្តី កាលកាត់នូវនិមិត្តនោះក្តីសូម្បីព្រោះបរិភោគនូវសរីរាង្គមានសាច់ជាដើមរបស់មនុស្សទាំងឡាយក្តី ត្រូវអាបត្តិថុល្លច្ច័យ ។

៥៦. ភិក្ខុប្រើសម្ពត់ដែលគេត្បាញដោយដើមចេក ដើមរៃទឹក និងដើមរាក់ក្តី សម្ពត់សំបកក្រចៅក្តី សម្ពត់មានពណ៌ខៀវសុទ្ធក្តី សម្ពត់មានពណ៌លឿងសុទ្ធជាដើមក្តី ត្រូវអាបត្តិទុក្កដ ។

៥៧.ភិក្ខុឆាន់នូវសរីរាង្គមានសាច់ជាដើមរបស់សត្វដំរី សេះ ពស់ ឆ្កែស្រុក សីហៈ ខ្លាធំ ខ្លាឃ្មុំ ខ្លាដំបង និងខ្លារខិនក្តី ឆាន់សាច់ដែលគេឧទ្ទិសចំពោះក្តី ។

៥៨. ឆាន់សាច់ដែលខ្លួនមិនបានសួរគេក្តី ឬមួយវៀរបង់នូវកិច្ចមានកិច្ចចំពោះកំពង់ទឹកជាដើម ដែលមានមកជាលំដាប់ក្តី ត្រូវអាបត្តិទុក្កដ ។

៥៩. សហសា វុត្ថជិត្វាន បរិសេ និក្ខមេយ្យ វា
វច្ចបស្សាវកុដិកំ វិនា ឧក្កាសិកំ វិសេ ។

៦០. និត្ថុនន្តោ ករេ វច្ចំ ទន្តកដ្ឋញ្ច ខាទយំ
វច្ចបស្សាវទោណីនំ ពហិ វច្ចាទិកំ ករេ ។

៦១. ខរេន ចាវលេខេយ្យ កដ្ឋំ បាតេយ្យ កូបកេ
ឩហតញ្ច ន ធោវេយ្យ ឧក្លាបញ្ច ន សោធយេ ។

៦២. ទកកិច្ចំ ករោន្តស្ស កត្វា ចបុចបូតិ ច
អនជ្ឈិដ្ឋោវ ថេរេន បាតិមោក្ខម្បិ ឧទ្ទិសេ ។

៦៣. អនាបុច្ឆាយ បញ្ហស្ស កថនេ វិស្សជ្ជនេបិ ច
សជ្ឈាយករណេ ទីប- ជាលនេ វិជ្ឈាបនេបិ ច ។

៦៤. ភាតបានកភាជានិ វិវរេយ្យ ថកេយ្យ វា
វន្ទនាទឹ ករេ នគ្គោ គមនំ ភោជនាទិកំ ។

៦៥. បរិកម្មំ ករេ ការេ តិបដិច្ឆន្នកំ វិនា
កាយំ នហាយំ ឃំសេយ្យ កុដ្ដេ ថម្ភេ តរុម្ហិ វា ។

៥៩. ភិក្ខុបោះទៅហើយ (នូវស្បង់) ដោយរហ័ស ហើយចូលទៅក្ដី ចេញមកក្ដី (ម្យ៉ាងទៀត) មិនបានក្អកគ្រហែម ចូលទៅវច្ចកុដិនិងបស្សាវកុដិក្ដី ។

៦០. ភិក្ខុកាលប្រឹងរមាត់ធ្វើវច្ចៈក្ដី កំពុងទំពាឈើស្ទន់(ធ្វើវច្ចៈ)ក្ដី ធ្វើនូវកិច្ចមានបន្ទោបង់វច្ចៈជាដើមខាងក្រៅស្នូកវច្ចៈឬបស្សាវក្ដី

៦១. ភិក្ខុកិតដោយវត្ថុដ៏មុតក្ដី ទំលាក់ឈើកិតទៅក្នុងរណ្ដៅលាមកក្ដី មិនលាងជម្រះនូវវច្ចកុដិដែលប្រឡាក់ហើយក្ដី មិនបានសំអាតសំបុកពីងពាងក្ដី ។

៦២. ភិក្ខុកាលធ្វើនូវកិច្ច គឺការលាងជម្រះឲ្យឮសំលេងផ្លាច់ ៗ ដូច្នេះក្ដី ព្រះថេរៈមិនបានបង្គាប់សោះ ក៏សម្ដែងសូម្បីបាតិមោក្ខក្ដី ។

៦៣. ភិក្ខុកាលមិនសុំឱកាស ក៏ពោល ឬដោះស្រាយបញ្ហាក្ដី ធ្វើការស្វាធ្យាយក្ដី អុជប្រទីប ឬពន្លត់ប្រទីបក្ដី ។

៦៤. បើកឬបិទនូវទ្វារនិងបង្អួចក្ដី ជាអ្នកអាក្រាតធ្វើនូវកិច្ចមានការថ្វាយបង្គំជាដើមក្ដី ធ្វើការដើរចូលទៅកាន់ស្រុកក្ដី ធ្វើកិច្ចមានការបរិភោគភោជនជាដើមក្ដី ។

៦៥. ធ្វើបរិកម្មដោយខ្លួនឯងក្ដី ឬឲ្យគេធ្វើឲ្យ វៀរលែងតែមានទីបិទបាំង ៣ យ៉ាងក្ដី កាលងូតទឹកត្រដុសកាយនឹងជញ្ជាំង សសរ ឬដើមឈើក្ដី ។

៦៦. កុរុវិន្ទកសុត្តេន អញ្ញមញ្ញស្ស កាយតោ
អគិលានោ ពហារាមេ ចរេយ្យ សឧបាហនោ ។

៦៧. ឧបាហនំ យោ ធារេតិ សព្វនីលាទិកម្បិ ច
និមិត្តំ ឥត្ថិយា រត្តោ មុខំ វា ភិក្ខុទាយិយា ។

៦៨. ឧជ្ឈានសញ្ញី អញ្ញស្ស បត្តំ វា អត្តនោ មុខំ
អាទាសាទិម្ហិ បស្សេយ្យ ឧច្ចាសនមហាសនេ ។

៦៩. និសជ្ជាទឹ ករោន្តស្ស ទុក្កដំ វន្ទនេបិ ច
ឧក្ខិត្តានុបសម្បន្ន- នានាសំវាសកាទិនំ ។

៧០. ឯកតោ បណ្ឌកិត្ថីហិ ឧភតោព្យញ្ជនេន វា
ទីឃាសនេ និសីទេយ្យ អទីឃេ អាសនេ បន ។

៧១. អសមានាសនិកេន មញ្ចបីឋេ សយេយ្យ វា
កុលសង្គហត្ថំ ទទតោ ផលបុប្ផាទិកម្បិ ច ។

៧២. គន្ធិមាទឹ ករេ ការេ ជិនវារិតបច្ចយេ
បរិភុញ្ជេយ្យ អព្យត្តោ អនិស្សាយ វសេយ្យ វា ។

៧៣. អនុញ្ញាតេហិ អញ្ញស្ស ភេសជ្ជំ វា ករេ វទេ
ករេ សាបត្តិកោ ភិក្ខុ ឧបោសថប្បវារណំ ។

៦៦. ដោយឈើកុរុវិន្ទកៈ និងដុំអំបោះក្តី (ត្រដុស)កាយគ្នាទៅវិញទៅមកក្តី គ្មានជម្ងឺពាក់ស្បែកជើងដើរទៅខាងក្រៅអារាមក្តី ។
៦៧. ភិក្ខុណា ពាក់ស្បែកជើងពណ៌ខៀវសុទ្ធជាដើមក្តី មានចិត្តតម្រេកមើលនិមិត្តរបស់ស្ត្រីក្តី មើលមុខស្ត្រីដែលប្រគេនភិក្ខាក្តី
៦៨. ភិក្ខុប្រុងលើកទោស ហើយសម្លឹងមើលបាត្ររបស់ភិក្ខុដទៃក្តី ឆ្លុះមើលមុខរបស់ខ្លួន ក្នុងកញ្ចក់ក្តី ធ្វើកិច្ចអង្គុយជាដើមលើអាសនៈដ៏ខ្ពស់ និងអាសនៈដ៏ប្រសើរក្តី ។
៦៩. សំពះអវន្ទិយបុគ្គល គឺភិក្ខុដែលសង្ឃលើកវត្ត អនុបសម្បន្ននិងភិក្ខុដែលមានសង្វាសផ្សេងគ្នាក្តី ត្រូវអាបត្តិទុក្កដ ។
៧០. ភិក្ខុអង្គុយលើអាសនៈវែង ឬក៏អាសនៈខ្លីតែមួយ ជាមួយនឹងមនុស្សខ្ទើយ ស្ត្រី និងឧភតោព្យញ្ជនៈក្តី ។
៧១. ដេកលើគ្រែ និងតាំងជាមួយនឹងភិក្ខុមានអាសនៈមិនស្មើគ្នាក្តី ឱ្យនូវវត្ថុមានផ្កានិងផ្លែឈើជាដើម ដើម្បីសង្គ្រោះត្រកូលក្តី ។
៧២. ភិក្ខុក្រងដោយខ្លួនឯង ឬប្រើឱ្យគេក្រងនូវកម្រងផ្កាជាដើមក្តី បរិភោគបច្ច័យដែលព្រះជិនស្រីទ្រង់ហាមហើយក្តី ជាអ្នកមិនឈ្លាសរស់នៅដោយគ្មាននិស្ស័យក្តី ។
៧៣. ភិក្ខុធ្វើ ឬប្រាប់នូវថ្នាំសម្រាប់កែរោគ ដល់បុគ្គលដទៃ ក្រៅពីបុគ្គលដែលព្រះដ៏មានព្រះភាគអនុញ្ញាតហើយក្តី ជាអ្នកមានអាបត្តិចូលធ្វើឧបោសថ និងបវារណាក្តី ។

៧៤. ទ្វារពន្ធាទិកេ ឋានេ បរិវត្តកភាជកំ
អបិធាយ វិនាភោគំ និយោគំ វា សយេ ទិវា ។

៧៥. ធញ្ញិត្ថិរូបរតនំ អាវុធិត្ថិបសាធនំ
តូរិយភណ្ឌំ ផលំ រុក្ខេ បុព្វណ្ណាទិញ្ច អាមសេ ។

៧៦. សសិត្ថោទកតេលេហិ ផណាហត្ថផណេហិ វា
កេសមោសណ្ឋានេកស្មឹ ភាជនេ ភោជនេបិ ច ។

៧៧. ឯកត្ថរណាបាវុរណា សយេយ្យុំ ទ្វេកមញ្ចកេ
ទន្តកដ្ឋញ្ច ខាទេយ្យ អធិកូនំ បមាណតោ ។

៧៨. យោជេតិ វា យោជាបេតិ នច្ចំ គីតញ្ច វាទិតំ
ទស្សនំ សវនំ តេសំ ករោន្តស្ស ច ទុក្កដំ ។

៧៩. វីហាទិរោបិមេ ចាបិ ពហិបាការកុដ្ដកេ
វច្ចាទិឆឌ្ឌនាទិម្ហិ ទីឃកេសាទិធារណេ ។

៨០. នខមដ្ឋករណាទិម្ហិ សម្ពាធេ លោមហារណេ
បរិកម្មកតំ ភូមឹ អក្កមេ សឧបាហនោ ។

៧៤. ភិក្ខុមិនបានបិទនូវសន្ទុះទ្វារដែលគួរបង្ខិលបាន ក្នុងទីមានទីប្រកបទ្វារ មានទ្វារពន្ធជាដើម ឬទីមិនមែនជាទីនៅហើយដេកក្នុងវេលាថ្ងៃ ដោយប្រាសចាកអាភោគចិត្ត ។

៧៥. ភិក្ខុប៉ះពាល់នូវអនាមាសវត្ថុ គឺ ធញ្ញជាតិ រូបនៃស្រ្តី រតនវត្ថុ អាវុធ គ្រឿងស្អិតស្អាងរបស់ស្រ្តី គ្រឿងតូរ្យតន្ត្រី ដើមឈើមានផ្លែ និងបុព្វណ្ណជាតិជាដើម ។

៧៦. ព្រោះកិរិយាសិតនូវសក់ដោយប្រេងនៃផ្លែស្រគំ និងប្រេងលាយទឹក ឬដោយក្រាស និងក្រាសគឺដៃក្តី ព្រោះកិរិយាបរិភោគក្នុងភាជនៈតែមួយក្តី ។

៧៧. ភិក្ខុពីរអង្គដេកលើកម្រាលតែមួយ និងដណ្តប់តែមួយ ឬលើគ្រែតែមួយក្តី ទំពាឈើស្ទន់ដែលលើស ឬខ្វះប្រមាណក្តី ។

៧៨. ភិក្ខុប្រកបខ្លួនឯងក្តី ប្រើគេឲ្យប្រកបក្តី នូវការរាំ ច្រៀង និងប្រគំក្តី ធ្វើការមើល ឬស្តាប់ការរាំ ច្រៀង ប្រគំទាំងឡាយនោះក្តី (ទាំងអស់នេះ) ត្រូវអាបត្តិទុក្កដ (ដូចគ្នា) ។

៧៩. និមិត្តតែកិច្ចមានកិរិយាបោះចោលជាដើម នូវកាកសំណល់មានវច្ចៈជាដើម ក្នុងទីខាងក្រៅរបង ឬជញ្ជាំង ដែលគេដាំវត្ថុមានពណ៌ខៀវមានស្រូវជាដើមក្តី ទុកសក់វែងជាដើមក្តី ។

៨០. និមិត្តកិច្ចមានការខាត់ក្រចកឱ្យរលោងជាដើមក្តី ការកោររោមក្នុងទីចង្អៀតក្តី ភិក្ខុពាក់ស្បែកជើងដើរជាន់ទីស្ថានដែលគេធ្វើបរិកម្មហើយក្តី ។

៨១. អធោតអល្លបាទេហិ សង្ឃិកំ មញ្ចបីឋកំ
បរិកម្មកតំ ភិត្តឹ អាមសន្តស្ស ទុក្កដំ ។

៨២. សង្ឃាដិយាបិ បល្លត្ថេ ទុប្បរិភុញ្ជេយ្យ ចីវរំ
អកាយពន្ធនោ គាមំ វជេ កត្វាន វច្ចកំ ។

៨៣. នាចមេយ្យ ទកេ សន្តេ សមាទេយ្យ អកប្បិយេ
ទេសនារោចនាទិម្ហិ សភាគាបត្តិយាបិ ច ។

៨៤. ន វសេ វស្សំ វិសំវាទេ សុទ្ធចិត្តេ បដិស្សវំ
វស្សំ វសិត្វា គមនេ អននុញ្ញាតកិច្ចតោ ។

៨៥. វិនាបទំ តរុស្សុទ្ធំ បោរិសម្ហាភិរូហណេ
អបរិស្សាវនោទ្ធានំ វជេ តំ យាចតោ ន ទេ ។

៨៦. អត្តនោ ឃាតនេ ឥត្តិ- រូបាទឹ ការយេយ្យ វា
ហិត្វា មាលាទិកំ ចិត្តំ ជាតកាទឹ សយំ ករេ ។

៨៧. ភុញ្ជន្តមុដ្ឋបេ តស្ស សាលាទីសុ និសីទតោ
វុឌ្ឍានំ បន ឱកាសំ អទត្វា វាបិ ទុក្កដំ ។

៨១. ភិក្ខុកាលជាន់គ្រែ និងតាំងជារបស់សង្ឃដោយជើងដែល មិនបានលាង និងជើងដែលសើមក្តី ផ្អែកនូវជញ្ជាំងដែលគេធ្វើ បរិកម្មហើយក្តី ត្រូវអាបត្តិទុក្កដ ។

៨២. ព្រោះត្របោមក្បាលជង្គង់ ដោយសំពត់សង្ឃាដិ ១ ភិក្ខុប្រើ ប្រាស់ចីវរមិនបានល្អ ១ មិនក្រវាត់កាយពន្ធ ដើរទៅកាន់ស្រុក១។

៨៣. កាលទឹកក៏មាន ធ្វើនូវវច្ចកិច្ចហើយមិនលាងជម្រះ ១ សមាទាន (កាន់យក) នូវពួកអកប្បិយបុគ្គល ព្រោះតែកិច្ច មានកិរិយាប្រាប់នូវការសំដែងជាដើម ដោយសភាគាបត្តិ ១ ។

៨៤. ភិក្ខុមិននៅចាំវស្សា ១ មានចិត្តបរិសុទ្ធទទួលបេ្តជ្ញាចាំវស្សា ១ នៅចាំវស្សាដើរទៅដោយគ្មានកិច្ចដែលទ្រង់អនុញ្ញាត ១ ។

៨៥. ភិក្ខុគ្មានអន្តរាយឡើងដើមឈើប្រមាណមួយជួរបុរស ១ ភិក្ខុគ្មានសំពត់តម្រងទឹក ដើរទៅកាន់ផ្លូវឆ្ងាយ ១ កាលភិក្ខុផង គ្នាសុំខ្ចីសំពត់តម្រងទឹកនោះមិនឱ្យ ១ ។

៨៦. ភិក្ខុសម្លាប់ខ្លួនឯង ១ គូរខ្លួនឯង ឬឲ្យគេគូររូបស្រ្តីជាដើម ១ គូរនូវរឿងជាតកជាដើមដោយខ្លួនឯង រៀរតែក្បូរក្បាច់វិចិត្រ មានផ្កាភ្ញីជាដើម ១ ។

៨៧. ភិក្ខុបណ្តេញភិក្ខុដែលកំពុងឆាន់ឲ្យក្រោកឡើង១ មិនតែ ប៉ុណ្ណោះ មិនសុំឱកាសពួកភិក្ខុចាស់ហើយអង្គុយក្នុងទីទាំងឡាយ មានសាលាឆាន់ជាដើម ១ (ភិក្ខុទាំងនោះ) ត្រូវអាបត្តិទុក្កដ។

៨៨. យានាទិមភិរូហេយ្យ កល្លកោ រតនត្តយំ
អារព្ភ វទេ ទវញ្ញ- បរិសាយោបលាលនេ ។

៨៩. កាយាទឹ វិវរិត្វាន ភិក្ខុនីនំ ន ទស្សយេ
វាចេ លោកាយតំ បលិតំ គណ្ហេយ្យ គណ្ហាបេយ្យ វា ។

៩០. យត្ថ កត្ថចិ បេឡាយំ ភុញ្ជតោ បត្តហត្ថកោ
វាតបានកវាដំ វា បណាមេ សោទកម្បិ ច ។

៩១. ឧណ្ហេយ្យ បដិសាមេយ្យ អតិឧណ្ហេយ្យ ភាជនំ
ឋបេយ្យ ភូមិយំ បត្តំ អង្កេ វា មញ្ចបីឋកេ ។

៩២. មិឌ្ឍន្តេ បរិភណ្ឌន្តេ បាទេ ឆត្តេ ឋបេតិ វា
ចលកាទឹ ឋបេ បត្តំ បត្តេ វា ហត្ថធោវនេ ។

៩៣. បត្តេន នីហរន្តស្ស ឧច្ឆិដ្ឋមុទកម្បិ ច
អកប្បិយម្បិ បត្តំ វា បរិភុញ្ជេយ្យ ទុក្កដំ ។

៩៤. វទេ ជីវាតិ ខិបិតេ ន សិក្ខតិ អនាទរោ
បរិមណ្ឌលកាទិម្ហិ សេខិយេ ទុក្កដំ សិយា ។

៨៨. ភិក្ខុគ្មានជម្ងឺឡើងជិះយានជាដើម ១ និយាយលេងប្រារព្ធព្រះរតនត្រ័យ ១ និយាយលួងលោមកៀរគរបរិស័ទអ្នកដទៃ១ ។
៨៩. ភិក្ខុមិនត្រូវបើកនូវអវយវៈមានកាយជាដើម បង្ហាញដល់ភិក្ខុនីទេ មិនត្រូវបង្រៀនគម្ពីរលោកាយតៈទេ មិនត្រូវដកខ្លួនឯងឬប្រើឲ្យគេដកសក់ស្កូវទេ ។
៩០. ភិក្ខុកាលឆាន់ក្នុងវត្ថុដ៏លំបាកណាមួយដូចជាហិប ១ ភិក្ខុមានបាត្រនៅក្នុងដៃច្រានសន្ទះទ្វារ និងបង្អួច ១ ។
៩១. ភិក្ខុហាល ឬសាទុកនូវបាត្រដែលមានទឹក ១ ហាលបាត្រដែលស្ងួតហើយឲ្យក្តៅពេក ១ ដាក់បាត្រលើផែនដី លើភ្លៅទាំងភ្អែន ឬលើគ្រែ ឬក៏តាំង ១ ។
៩២. ភិក្ខុដាក់បាត្រលើទីបំផុតនៃផែនក្តារតាំង លើទីបំផុតនៃថ្នាក់លើជើង ឬក្នុងឆ័ត្រ ១ ដាក់នូវកាកសំណល់មានសម្រាមជាដើមក្នុងបាត្រ ១ ប្រើបាត្រសម្រាប់ដាក់ទឹកលាងដៃ ១ ។
៩៣. ភិក្ខុដាក់ទឹកជាដែល (ទឹកមិនល្អ) ក្នុងបាត្រយកទៅចោល ១ ភិក្ខុប្រើប្រាស់បាត្រ ដែលជាអកប្បិយ ១ ភិក្ខុទាំងអស់នោះត្រូវអាបត្តិទុក្កដ ។
៩៤. កាលព្រះមានព្រះភាគទ្រង់ព្រះកណ្តាស់ហើយ ភិក្ខុពោលថា សូមទ្រង់គង់ព្រះជន្មនៅ (ស្បើយទៅ) ដូច្នេះ ១ ភិក្ខុមិនអើពើមិនសិក្សាក្នុងសេក្ខិយវត្តមានការស្លៀកឲ្យជាបរិមណ្ឌលជាដើម ១ ត្រូវអាបត្តិទុក្កដ ។

៩៥. យោ ភណ្ឌាគារេ បយុតោវ ភណ្ឌកំ
មាតូន បាចិត្តិយមស្ស គោបយេ
ទវាយ ហីនេនបិ ជាតិអាទិនា
វទេយ្យ ទុក្កាសិតមុត្តមម្បិ យោតិ ៕

៩៥. ភិក្ខុណា ជាអ្នកខ្វល់ខ្វាយឃ្លាំង (របស់សង្ឃ) សោះ បែរទៅរក្សាទ្រព្យរបស់មាតាបិតាទៅវិញ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ភិក្ខុណា ពោលបង្អាប់ភិក្ខុផងគ្នា ដោយអក្កោសវត្ថុមានជាតិដ៏ថោកទាបជាដើម ដោយការចំអកលេង ភិក្ខុនោះ ត្រូវអាបត្តិ-ទុក្កដាសិត ដូច្នេះឯង ៕

# ៦. វត្តាទិកណ្ឌនិទ្ទេសោ

៩៦. ឧបជ្ឈាចរិយវត្តញ្ច    គមិកាគន្តុកម្បិ ច
សេនាសនាទិវត្តញ្ច    កាតព្វំ បិយសីលិនា ។

៩៧. ហត្ថបាសេ ឋិតោ កិញ្ចិ    គហិតព្វំ ទទេ តិធា
គហេតុកាមោ គណ្ហេយ្យ ទ្វិធាយំ សម្បដិគ្គហោ ។

៩៨. សង្ឃាដិមុត្តរាសង្គំ    តថា អន្តរវាសកំ
ឯតំ ឥមំ អធិដ្ឋាមិ    តថា បច្ចុទ្ធរាមីតិ ។

៩៩. ឥមំ ឥមានិ ឯតានិ    ឯតម្បិ ចីវរន្តិ វា
បរិក្ខារចោឡានីតិ    តថា បច្ចុទ្ធរាមីតិ ។

១០០. ឯតំ ឥមំ អធិដ្ឋាមិ    បត្តំ បច្ចុទ្ធរាមីតិ
ឯវំ បច្ចុទ្ធរេធិដ្ឋេ    ចីវរាទឹ យថាវិធិ ។

១០១. សញ្ចរិត្តំ វិនា សេសា    សចិត្តា គរុកន្តិមា
អចិន្តំ បរិណតំ ហិត្វា    និស្សគ្គិយមចិត្តកំ ។

# ៦. វត្តាទិកណ្ឌនិទ្ទេស

៩៦. ភិក្ខុមានសីលជាទីស្រឡាញ់ គប្បីធ្វើនូវឧបជ្ឈាយវត្ត អាចរិយវត្ត គមិកវត្ត អាគន្តុកវត្ត និងសេនាសនវត្តជាដើម ។

៩៧. ទាយកឋិតនៅក្នុងហត្ថបាស ១ ទេយ្យវត្ថុណាមួយដែលមជ្ឈិមបុរសលើករួច ១ ទាយកបង្អោនចូលមកប្រគេនដោយអាការៈបីយ៉ាងណាមួយ ១ ភិក្ខុប្រាថ្នានឹងទទួល ១ ទទួលដោយអាការៈពីរយ៉ាងណាមួយ ១ ។

៩៨. ភិក្ខុគប្បីអធិដ្ឋាននូវសង្ឃាដិ ឧត្តរាសង្គៈ និងអន្តរវាសកៈ ថា ខ្ញុំអធិដ្ឋាននូវសង្ឃាដិ ឧត្តរាសង្គៈ និងអន្តរាវាសកៈនុ៎ះ ឬនេះដូច្នេះ និងគប្បីដកថា ខ្ញុំដក ដោយប្រការដូច្នោះដែរ ។

៩៩. ភិក្ខុគប្បីអធិដ្ឋានថា ចីវរនេះ ចីវរទាំងឡាយនេះ ចីវរទាំងឡាយនុ៎ះ ចីវរនុ៎ះ ដូច្នេះ ឬថា សំពត់បរិក្ខារទាំងឡាយ ដូច្នេះ គប្បីដកថា ខ្ញុំដក ដូច្នេះ ដោយប្រការដូចគ្នានោះចុះ ។

១០០. ភិក្ខុគប្បីដក ឬអធិដ្ឋាននូវបរិក្ខារមានចីវរជាដើម តាមសមគួរដល់វិធីយ៉ាងនេះ គឺខ្ញុំអធិដ្ឋាននូវចីវរនុ៎ះ ចីវរនេះ ខ្ញុំដកនូវបាត្រនុ៎ះ បាត្រនេះ ដូច្នេះ ។

១០១. វៀរទុកតែសញ្ចរិត្តសិក្ខាបទចេញ គរុកសិក្ខាបទ (សង្ឃាទិសេស) និងបារាជិកដ៏សេស ជាសចិត្តកៈ វៀរអច្ឆិន្នសិក្ខាបទ និងបរិណតសិក្ខាបទចេញ សិក្ខាបទក្នុងនិស្សគ្គិយដ៏សេស ជាអចិត្តកៈ ។

១០២. បទសោធម្មំ ទុវេ សេយ្យា ឥត្ថិយា ធម្មទេសនា
ទុវេ សេនាសនានីបិ សិព្វនំ ចីវរស្សបិ ។

១០៣. បវារិតំ សុរាបានំ បញ្ចសន្និធិអាទិកំ
ជោតិនុជ្ជាលនញ្ចេវ កប្បពិន្ទុមនាទិកំ
គាមប្បវេសនន្តេតេ បាចិត្តីសុ អចិត្តកា ។

១០៤. បកិណ្ណកេសុ ឧទ្ទិស្ស- កតំ ហិត្វាញ្ញមំសកំ
ឯកត្ថរណបាវុរណំ ឯកមញ្ចេ តុវដ្ដនំ
ឯកតោ ភុញ្ជនញ្ចាបិ នច្ចគីតាទិសត្តបិ ។

១០៥. អកាយពន្ធនញ្ចាបិ បត្តហត្ថកវាដកំ
អចិត្តកមិទំ សព្វំ សេសមេត្ថ សចិត្តកំ ។

១០៦. វីតិក្កមនចិត្តេន សចិត្តកមចិត្តកំ
បញ្ញត្តិជាននេនាបិ វិទន្តាចរិយា តថា ។

១០៧. បុព្វករណាទិកំ កត្វា ឧបោសថប្បវារណំ
នវធា ទីបិតំ សព្វំ កាតព្វំ បិយសីលិនា ។

១០២. ក្នុងបាចិត្តិយទាំងឡាយ សិក្ខាបទទាំងឡាយនេះ គឺ បទសោធម្មសិក្ខាបទ ១ សហសេយ្យសិក្ខាបទ ២ សិក្ខាបទពោលពីការសំដែងធម៌ដល់ស្ត្រី ១ សេនាសនសិក្ខាបទ ២ ចីវរសិព្វនសិក្ខាបទ ១ ។

១០៣. បវារិតសិក្ខាបទ ១ សុរាបានសិក្ខាបទ ១ សិក្ខាបទទាំង ៥ មានសន្និធិសិក្ខាបទជាដើម ជោតិនុដ្ឋាលនសិក្ខាបទ ១ កប្បពិន្ទុសិក្ខាបទជាដើម ១ គាមប្បវេសនសិក្ខាបទ ១ ជាអចិត្តកៈ ។

១០៤. ក្នុងបកិណ្ណកទាំងឡាយ វៀរតែឧទ្ទិស្សកតមំសសិក្ខាបទចេញ មំសសិក្ខាបទ និងសិក្ខាបទដទៃទៀត ឯកត្ថរណសិក្ខាបទ បាវុរណសិក្ខាបទ សិក្ខាបទដេកលើគ្រែតែមួយ បរិភោគក្នុងភាជន៍តែមួយ និងសិក្ខាបទ ៧ មាននច្ចគីតសិក្ខាបទជាដើម ។

១០៥. អកាយពន្ធនៈ និងបត្តហត្ថកវាជកសិក្ខាបទ ទាំងអស់នេះ ជាអចិត្តកៈ សិក្ខាបទដ៏សេសក្នុងបកិណ្ណកៈនេះ ជាសចិត្តកៈ ។

១០៦. អាចារ្យទាំងឡាយ ពោលថា សចិត្តកៈ និងអចិត្តក-សិក្ខាបទ ជាសិក្ខាបទដែលភិក្ខុមានចិត្តប្រព្រឹត្ត និងពោលដោយប្រការដូច្នេះថា ជាសិក្ខាបទសូម្បីដែលភិក្ខុដឹងបញ្ញត្តិ ។

១០៧. ភិក្ខុអ្នកមានសីលជាទីស្រឡាញ់ គប្បីធ្វើនូវកិច្ចទាំងអស់ មានបុព្វករណៈជាដើម ដែលទ្រង់សម្តែងហើយដោយប្រការ ៩ យ៉ាង ហើយសឹមធ្វើឧបោសថ ឬបវារណាចុះ ។

១០៨. សម្មជ្ជនី បទីបោ ច  ឧទកំ អាសនេន ច
ឧបោសថស្ស ឯតានិ  បុព្វករណន្តិ វុច្ចតិ ។

១០៩. ឆន្ទបារិសុទ្ធិឧតុក្ខានំ  ភិក្ខុគណនា ច ឱវាទោ
ឧបោសថស្ស ឯតានិ  បុព្វកិច្ចន្តិ វុច្ចតិ ។

១១០. ឧបោសថោ យាវតិកា  ច ភិក្ខូ កម្មប្បត្តា
សភាគាបត្តិយោ ច ន វិជ្ជន្តិ
វជ្ជនីយា ច បុគ្គលា តស្មឹ ន ហោន្តិ បត្តកល្លន្តិ វុច្ចតិ ។

១១១. បុព្វករណបុព្វកិច្ចានិ សមាបេត្វា ទេសិតាបត្តិកស្ស សមគ្គស្ស ភិក្ខុសង្ឃស្ស អនុមតិយា បាតិមោក្ខំ ឧទ្ទិសិតុំ អារាធនំ ករោម ។

១១២. បារិសុទ្ធិអធិដ្ឋាន-  សុត្តុទ្ទេសវសា តិធា
គណបុគ្គលសង្ឃា ច  តំ ករេយ្យុំ យថាក្កមំ ។

១១៣. ចាតុទ្ទសោ បណ្ណរសោ  សាមគ្គី ទិនតោ តិធា
ទិនបុគ្គលកត្តព្វ-  ការតោ តេ នវេរិតា ។

១១៤. តយោ តយោតិ កត្វាន  ទិនបុគ្គលភេទតោ

១០៨. កិរិយាបោសរោងឧបោសថ ១ អុជប្រទីប ១ តម្កល់ទឹក ១ ក្រាលអាសនៈ ១ កិច្ចនៃឧបោសថទាំងនេះ លោកពោលថា បុព្វករណៈ ។

១០៩. ការនាំឆន្ទៈ១ នាំបារិសុទ្ធិ១ ប្រាប់រដូវ១ រាប់ភិក្ខុ១ ឲ្យឱវាទដល់ភិក្ខុនី ១ កិច្ចនៃឧបោសថទាំងនេះ លោកហៅថា បុព្វកិច្ច ។

១១០. ថ្ងៃឧបោសថ ១ ភិក្ខុមានប្រមាណប៉ុណ្ណោគួរដល់កម្ម ១ សភាគាបត្តិមិនមាន ១ វជ្ជនីយបុគ្គលទាំងឡាយមិនមានក្នុងពួកភិក្ខុទាំងនោះ ១ លោកហៅថា ឧបោសថមានកាលដ៏សមគួរ ។

១១១. យើងទាំងឡាយ សំអាតបុព្វករណៈ និងបុព្វកិច្ចទាំងឡាយ ហើយធ្វើនូវការអារាធនាដើម្បីសម្ដែងបាតិមោក្ខ តាមអនុមតិនៃសង្ឃដែលព្រមព្រៀងគ្នា មានអាបត្តិសម្ដែងចេញហើយ ។

១១២. មួយទៀត គណៈ បុគ្គល និងសង្ឃ គប្បីធ្វើនូវបាតិមោក្ខនោះ តាមសមគួរដល់កម្មដោយប្រការ ៣ យ៉ាង ព្រោះអំណាចនៃបារិសុទ្ធិឧបោសថ អធិដ្ឋានុបោសថ និង សុត្តុទ្ទេសុបោសថ ។

១១៣. ឧបោសថមាន ៣ ដោយថ្ងៃ គឺ ឧបោសថមានក្នុងថ្ងៃទី ១៤ ឧបោសថមានក្នុងថ្ងៃទី ១៥ និងឧបោសថមានក្នុងថ្ងៃដែលសង្ឃព្រមព្រៀងគ្នា ឧបោសថទាំងឡាយនោះ មាន ៩ ដទៃទៀត ព្រោះថ្ងៃ បុគ្គល និងព្រោះអាការៈដែលគប្បីធ្វើ ។

១១៤. បវារណាលោកពោលហើយ មាន ៩ យ៉ាង ព្រោះធ្វើ ឲ្យជា ៣ ៗ ដូច្នេះ នូវបវារណា គឺ តេវាចិកាបវារណា ទ្វេវាចិកាបវារណា

តេវាចីទ្វេកវាចីតិ ឥវំ វុត្តា បវារណា ។

១១៥. កត្តិកន្តិមបក្ខម្ហា ហេមំ ផគ្គុនបុណ្ណមា
តស្ស អន្តិមបក្ខម្ហា គិម្ហំ អាសាឡ្ហិបុណ្ណមា
វស្សកាលំ តតោ សេសំ ចតុវីសតុបោសថា ។

១១៦. ចាតុទ្ទសា ច ឯតេសុ បក្ខា តតិយសត្តមា
ញេយ្យា បណ្ណរសា សេសា អដ្ឋារស ឧបោសថា ។

១១៧. ឆន្ទំ ទម្មិ, ឆន្ទំ មេ ហរ, ឆន្ទំ មេ អារោចេហីតិ ឆន្ទំ ទាតព្វំ។

១១៨. បារិសុទ្ធឹ ទម្មិ, បារិសុទ្ធឹ មេ ហរ, បារិសុទ្ធឹ មេ អារោចេហីតិ បារិសុទ្ធិ ទាតព្វា ។

១១៩. បវារណំ ទម្មិ, បវារណំ មេ ហរ, បវារណំ មេ អារោចេហិ, មមត្ថាយ បវារេហីតិ បវារណា ទាតព្វា ។

១២០. អាបត្តិទេសកេន, **អហំ ភន្តេ សម្ពហុលា នានាវត្ថុកា អាបត្តិយោ អាបជ្ជឹ, តា តុម្ហមូលេ បដិទេសេមី**តិ វត្វា បដិគ្គណ្ហន្តេន, **បស្សសិ អាវុសោ តា អាបត្តិយោ**តិ វុត្តេ **អាម ភន្តេ បស្សាមី**តិ វត្វា

និងឯកវាចិកាបវារណា ដោយប្រភេទនៃថ្ងៃ និងបុគ្គល ។
១១៥. ឧបោសថទាំងឡាយ ២៤ គឺ ហេមន្តរដូវចាប់ពីបក្ខខាងចុងនៃខែកត្តិក រហូតដល់ថ្ងៃពេញបូណ៌មីខែផល្គុន, គិម្ហរដូវ ចាប់ពីបក្ខខាងចុងនៃខែផល្គុន រហូតដល់ថ្ងៃពេញបូណ៌មីខែអាសាឍ្ហ, វស្សកាលរដូវ គឺសល់ពីរដូវទាំងនោះ ។
១១៦. ចាតុទ្ទសឧបោសថមាន ៦ គឺ បណ្តារដូវទាំង ៣ នោះ ឧបោសថក្នុងបក្ខទី ៣ និងបក្ខទី ៧ (ក្នុងរដូវនីមួយៗ) ឧបោសថ ១៨ ដ៏សេស ជាបណ្ណរសីឧបោសថ អ្នកសិក្សាគប្បីជ្រាប ។
១១៧. ឆន្ទៈ គឺភិក្ខុគប្បីឲ្យថា ខ្ញុំឲ្យឆន្ទៈ, លោកចូរនាំឆន្ទៈរបស់ខ្ញុំទៅ, លោកចូរប្រាប់ឆន្ទៈរបស់ខ្ញុំផង ដូច្នេះ ។
១១៨. បារិសុទ្ធិ គឺភិក្ខុគប្បីឲ្យថា ខ្ញុំឲ្យបារិសុទ្ធិ, លោកចូរនាំបារិសុទ្ធិរបស់ខ្ញុំទៅ, លោកចូរប្រាប់បារិសុទ្ធិរបស់ខ្ញុំផង ដូច្នេះ ។
១១៩. បវារណា គឺភិក្ខុគប្បីឲ្យថា ខ្ញុំឲ្យបវារណា, លោកចូរនាំបវារណារបស់ខ្ញុំទៅ, លោកចូរប្រាប់បវារណារបស់ខ្ញុំផង ដូច្នេះ លោកចូរបវារណាដើម្បីខ្ញុំផង ។
១២០. ភិក្ខុអ្នកសម្តែងអាបត្តិគប្បីពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាត្រូវហើយ នូវអាបត្តិទាំងឡាយដ៏ច្រើនមានវត្ថុផ្សេងៗគ្នា ខ្ញុំសូមសម្តែងនូវអាបត្តិទាំងនោះ ក្នុងសំណាក់លោកម្ចាស់ ដូច្នេះ កាលភិក្ខុអ្នកទទួលពោលថា ម្នាលលោកដ៏មានអាយុ លោកឃើញអាបត្តិទាំងនោះឬ ? គប្បីពោលថា បពិត្រលោកដ៏ចម្រើន ករុណា ខ្ញុំឃើញ ។

បុន បដិគ្គណ្ហន្តេន **អាយតឹ អាវុសោ សំវរេយ្យាសីតិ** វុត្តេ **សាធុ សុដ្ឋុ ភន្តេ សំវរិស្សាមីតិ** តិក្ខត្តុំ វត្វា ទេសេតព្វំ។

១២១. វេមតឹ អារោចេន្តេន **អហំ ភន្តេ សម្ពហុលាសុ នានាវត្ថុកាសុ អាបត្តីសុ វេមតិកោ យទា និព្វេមតិកោ ភវិស្សាមិ តទា តា អាបត្តិយោ បដិករិស្សាមីតិ** តិក្ខត្តុំ វត្វា អារោចេតព្វំ ។

១២២. **អជ្ជ មេ ឧបោសថោ បណ្ណរសោ ចាតុទ្ទសោតិ វា អធិដ្ឋាមីតិ** តិក្ខត្តុំ វត្វា បុគ្គលេន អធិដ្ឋានុបោសថោ កាតព្វោ។

១២៣. ទ្វីសុ បន ថេរេន បរិសុទ្ធោ **អហំ អាវុសោ បរិសុទ្ធោតិ មំ ធារេហីតិ** តិក្ខត្តុំ វត្តព្វំ ។ នវកេនបិ តថេវ វត្តព្វំ ។ ភន្តេ ធារេថាតិ វចនំ វិសេសោ។

១២៤. តីសុ បន **សុណន្តុ មេ អាយស្មន្តា អជ្ជុបោសថោ បណ្ណរសោ យទាយស្មន្តានំ បត្តកល្លំ មយំ អញ្ញមញ្ញំ បារិសុទ្ធិឧបោសថំ ករេយ្យាមាតិ** ញត្តឹ ឋបេត្វា បដិបាដិយា វុត្តនយេន បារិសុទ្ធិឧបោសថោ កាតព្វោ ។

កាលភិក្ខុអ្នកទទួលពោលទៀតថា នែលោកដ៏មានអាយុ លោកចូរសង្រួមតទៅ គប្បីសម្តែងអស់វារៈបីដងថា បពិត្រលោកដ៏ចម្រើន ប្រពៃហើយ ល្អហើយ ខ្ញុំព្រះករុណានឹងសង្រួមតទៅ ។

១២១. ភិក្ខុកាលប្រាប់អាបត្តិដែលសង្ស័យ គប្បីពោលប្រាប់អស់វារៈ ៣ ដងថា បពិត្រលោកដ៏ចម្រើន ខ្ញុំព្រះករុណាមានសេចក្តីសង្ស័យក្នុងអាបត្តិទាំងឡាយមានវត្ថុផ្សេង ៗ គ្នា ក្នុងកាលណា ខ្ញុំអស់សេចក្តីសង្ស័យខ្ញុំនឹងសម្តែងចេញនូវអាបត្តិក្នុងកាលនោះ។

១២២. អធិដ្ឋានុបោសថ គឺបុគ្គលគប្បីពោលអស់វារៈ ៣ ដងកំណត់ថា ថ្ងៃនេះ ជាថ្ងៃឧបោសថរបស់អញ ថ្ងៃទី ១៥ ឬទី ១៤, ខ្ញុំសូមអធិដ្ឋាន ដូច្នេះ ។

១២៣. បើបណ្តាភិក្ខុពីររូប ព្រះថេរៈគប្បីពោលអស់វារៈបីដងថា ម្នាលលោកដ៏មានអាយុ ខ្ញុំជាបុគ្គលបរិសុទ្ធ លោកចូរចាំទុកនូវខ្ញុំថា ជាបុគ្គលបរិសុទ្ធ ដូច្នេះ ។ សូម្បីភិក្ខុខ្ចីក៏គប្បីពោលដោយប្រការដូច្នោះដែរ ។ ពាក្យដែលផ្សេងគ្នាគ្រាន់តែថា បពិត្រលោកដ៏ចម្រើន លោកម្ចាស់ចូរចាំទុក ដូច្នេះប៉ុណ្ណោះ ។

១២៤. តែចំពោះភិក្ខុបីរូប គប្បីតាំងញត្តិថា ម្នាលលោកដ៏មាន-អាយុទាំងឡាយ សូមលោកទាំងឡាយ ស្តាប់ពាក្យខ្ញុំ បើកម្មមានកាលដ៏សមគួរ ដល់លោកដ៏មានអាយុទាំងឡាយហើយ យើងគប្បីធ្វើបារិសុទ្ធិឧបោសថដល់គ្នានិងគ្នាដូច្នេះ ហើយគប្បីធ្វើបារិសុទ្ធិឧបាសថ តាមន័យដែលពោលហើយ តាមលំដាប់ចុះ ។

១២៥. **អជ្ជ មេ បវារណា ចាតុទ្ទសី បណ្ណរសីតិ វា អធិដ្ឋាមីតិ** តិក្ខត្តុំ វត្វា ឯកេន បវារេតព្វំ ។

១២៦. ទ្វីសុ បន ថេរេន **អហំ អាវុសោ អាយស្មន្តំ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា វទតុ មំ អាយស្មា អនុកម្បំ ឧបាទាយ បស្សន្តោ បដិករិស្សាមីតិ** តិក្ខត្តុំ វត្វា បវារេតព្វំ។ នវកេនាបិ តថេវ វត្តព្វំ ។ ភន្តេតិ វចនំ វិសេសោ ។

១២៧. តីសុ វា ចតូសុ វា បន **សុណន្តុ មេ អាយស្មន្តា អជ្ជ បវារណា បណ្ណរសី យទាយស្មន្តានំ បត្តកល្លំ មយំ អញ្ញមញ្ញំ បវារេយ្យាមាតិ** ញត្តិំ ឋបេត្វា ថេរេន **អហំ អាវុសោ អាយស្មន្តេ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា វទន្តុ មំ អាយស្មន្តា អនុកម្បំ ឧបាទាយ បស្សន្តោ បដិករិស្សាមីតិ** តិក្ខត្តុំ វត្វា បវារេតព្វំ ។ នវកេហិបិ តថេវ បដិបាដិយា បវារេតព្វំ។ ភន្តេតិ វចនំ វិសេសោ ។

១២៥. ភិក្ខុមួយរូបពោលបវារណាអស់វារៈបីដងថា ថ្ងៃនេះ ជាថ្ងៃបវារណារបស់អញ ថ្ងៃទី ១៤ ឬថ្ងៃទី ១៥ ខ្ញុំសូមបវារណា ។

១២៦. តែបើភិក្ខុពីររូប ភិក្ខុជាថេរៈគប្បីពោលអស់វារៈបីដងថា ម្នាលលោកដ៏មានអាយុ ខ្ញុំសូមបវារណាចំពោះអ្នកដ៏មានអាយុ ដោយការឃើញ ឮ និងការរង្កៀស សូមលោកដ៏មានអាយុ អាស្រ័យនូវសេចក្ដីអនុគ្រោះពោលចំពោះខ្ញុំ ខ្ញុំឃើញហើយ នឹងសម្ដែងចេញ ។ សូម្បីភិក្ខុខ្ចី ក៏គប្បីពោលដូច្នោះ ដូចគ្នា ។ ពាក្យដែលប្លែកគ្នាគ្រាន់តែថា បពិត្រលោកដ៏ចម្រើន ។

១២៧. តែបើភិក្ខុបីរូប ឬបួនរូប ត្រូវភិក្ខុជាថេរៈតាំងញត្តិថា ម្នាលលោកដ៏មានអាយុទាំងឡាយ សូមលោកដ៏មានអាយុទាំង-ឡាយ ស្ដាប់ពាក្យខ្ញុំ ដ្បិតថ្ងៃនេះ ជាថ្ងៃបវារណាទី ១៥, បើកម្មមានកាលដ៏សមគួរ ដល់លោកដ៏មានអាយុទាំងឡាយហើយ យើងទាំងឡាយ គប្បីបវារណាដល់គ្នានិងគ្នា ហើយគប្បីបវារណាអស់វារៈបីដងថា ម្នាលលោកដ៏មានអាយុទាំងឡាយ ខ្ញុំសូមបវារណាចំពោះលោកមានអាយុទាំងឡាយ ដោយការឃើញ ការឮ និងការរង្កៀស, សូមលោកដ៏មានអាយុទាំងឡាយ អាស្រ័យនូវសេចក្ដីអនុគ្រោះពោលចំពោះខ្ញុំ ខ្ញុំឃើញហើយ នឹងធ្វើឲ្យជាក់ច្បាស់ ។ សូម្បីភិក្ខុខ្ចីទាំងឡាយ ក៏គប្បីបវារណាតាមលំដាប់ដូចគ្នាដែរចុះ ។ ពាក្យដែលប្លែកគ្នាគ្រាន់តែថា បពិត្រលោកដ៏ចម្រើន ។

១២៨. បត្តហិ អធិកេសុ បន **សុណាតុ មេ អាវុសោ សង្ឃោ អជ្ជ បវារណា បណ្ណរសី យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ បវារេយ្យា**តិ ញត្តឹ ឋបេត្វា វុឌ្ឍតរេន **សង្ឃំ អាវុសោ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា វទន្តុ មំ អាយស្មន្តោ អនុកម្បំ ឧបាទាយ បស្សន្តោ បដិករិស្សាមី**តិ តិក្ខត្តុំ វត្វា បវារេតព្វំ ។ នវកេហិបិ តថេវ បដិបាដិយា **សង្ឃំ ភន្តេ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា វទន្តុ មំ អាយស្មន្តោ អនុកម្បំ ឧបាទាយ បស្សន្តោ បដិករិស្សាមី**តិ តិក្ខត្តុំ វត្វា បវារេតព្វំ ៕

## មូលសិក្ខា និដ្ឋិតា ។

១២៨. បើភិក្ខុច្រើនលើសពីបួនរូបឡើងទៅ ត្រូវភិក្ខុដែលចាស់ជាងតាំងញត្តិថា ម្នាលលោកដ៏មានអាយុទាំងឡាយ សង្ឃសូមស្តាប់ពាក្យខ្ញុំ ថ្ងៃនេះ ជាថ្ងៃបវារណាទី ១៥, បើកម្មមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីបវារណា ហើយពោលបវារណាអស់វារៈបីដងថា ម្នាលលោកដ៏មានអាយុទាំងឡាយ ខ្ញុំសូមបវារណានឹងសង្ឃដោយការឃើញ ការឮ និងការរង្កៀស, សូមលោកដ៏មានអាយុទាំងឡាយ អាស្រ័យនូវសេចក្តីអនុគ្រោះពោលចំពោះខ្ញុំ ខ្ញុំឃើញហើយនឹងធ្វើឲ្យជាក់ច្បាស់ ។ សូម្បីភិក្ខុខ្ទីទាំងឡាយ ក៏គប្បីបវារណាអស់វារៈបីដង តាមលំដាប់ដូចគ្នាដែរថា បពិត្រលោកដ៏ចម្រើន ខ្ញុំសូមបវារណានឹងសង្ឃ ដោយការឃើញ ការឮ និងការរង្កៀស, សូមលោកដ៏មានអាយុទាំងឡាយ អាស្រ័យនូវសេចក្តីអនុគ្រោះពោលចំពោះខ្ញុំ ខ្ញុំឃើញហើយនឹងសម្តែងចេញ ៕

## មូលសិក្ខា ចប់ ។

។ នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

# មូលសិក្ខា ដីកា

## គន្ថារម្ភកថា

សព្វកាមទទំ សព្វរតនេ រតនត្តយំ
ឧត្តមំ ឧត្តមតរំ វន្ទិត្វា វន្ទនារហំ ។

បណ្ដារតនៈគ្រប់យ៉ាង ខ្ញុំព្រះករុណាសូមថ្វាយបង្គំចំពោះព្រះរតនត្រ័យ ជារតនៈដ៏ឧត្ដមខ្ពង់ខ្ពស់ជាងរតនៈទាំងពួង ដែលឱ្យនូវសេចក្ដីប្រាថ្នាគ្រប់យ៉ាង គួរដល់ការថ្វាយបង្គំ ។

បរណោ ព្រហ្មចារីនំ អាចរិយានំ សិរំ មម
បបេត្វាន ករិស្សាមិ មូលសិក្ខត្ថវណ្ណនំ ។

បណ្ដាបុគ្គលអ្នកប្រព្រឹត្តល្អទាំងឡាយ ខ្ញុំសូមតម្កល់នូវសិរសារបស់ខ្ញុំចំពោះ ព្រះអាចារ្យទាំងឡាយ អ្នកមានប្រក្រតីប្រព្រឹត្តនូវព្រហ្មចរិយធម៌ ហើយធ្វើនូវការពណ៌នាសេចក្ដីនៃ **មូលសិក្ខា** តទៅ ៖

# គន្ថារម្ភកថាវណ្ណនា

នត្វា នាថំ បវក្ខាមិ    មូលសិក្ខំ សមាសតោ
ភិក្ខុនា នវកេនាទោ    មូលភាសាយ សិក្ខិតុំ ។

បណ្ដាពាក្យក្នុងគន្ថារម្ភកថានោះ សេចក្ដីបំព្រួញដូចម្ដេច? ព្រះ**មហាសាមិត្ថេរ** កាលសម្ដែងនូវសេចក្ដីឱនលំទោនចំពោះព្រះសាស្ដា ទ្រង់ជាអ្នកអាចក្នុងហេតុគ្រប់យ៉ាង ទ្រង់ឧត្ដមជាងសត្វទាំងពួងខាងដើមសិន ទើបពោលថា **នត្វា នាថំ** ដូច្នេះជាដើម ។ **នត្វា** គឺថ្វាយបង្គំចំពោះព្រះមានព្រះភាគទ្រង់ជានាថៈព្រះអង្គដល់ព្រមដោយអង្គនៃទីពឹង ៤ យ៉ាង ។ ពាក្យថា **អាទោ** គឺ ក្នុងកាលជាខាងដើមតាំងអំពីឧបសម្បទាមក ។ ពីរបទថា **នវកេន ភិក្ខុនា** គឺ ភិក្ខុ សាមណេរ ដែលបានបព្វជ្ជាឧបសម្បទាថ្មី ៗ ។ ពាក្យថា **មូលភាសាយ** គឺដើម្បីសិក្សាដោយភាសារបស់អ្នកស្រុកមគធៈ ។ ពាក្យថា **សមាសតោ** គឺ ខ្ញុំសូមពោលនូវគម្ពីរ **មូលសិក្ខា** ដោយសង្ខេបដូច្នេះឯង ។

**សេចក្ដីពិស្ដារនៃមូលសិក្ខា** មានដូចតទៅនេះ ៖

ពាក្យថា **នត្វា** គឺ ជាអ្នកមានកាយបន្ទាបចុះហើយអធិប្បាយថា ថ្វាយបង្គំ ដោយទ្វារទាំង ៣ គឺ កាយទ្វារ វចីទ្វារ និងមនោទ្វារ ។ **នាថតីតិ នាថោ** បុគ្គលណា តែងជាទីពឹង

បុគ្គលនោះ ឈ្មោះថា **នាថៈ** អធិប្បាយថា តែងមានបំណង គឺប្រាថ្នានូវប្រយោជន៍ និងសេចក្ដីសុខដល់វេនេយ្យសត្វទាំងឡាយ ដោយអំណាចនៃការប្រកាន់ខ្ជាប់នូវមេត្តា ។ មយ៉ាងទៀត សេចក្ដីថា ទ្រង់តែងជាទីពឹង គឺទ្រង់តែងចូលទៅដុតបំផ្លាញកិលេសទាំងឡាយក្នុងសន្ដានចិត្តនៃវេនេយ្យសត្វទាំងឡាយ ឱ្យអស់ទៅ ឬថា ទ្រង់ជាទីពឹង គឺទ្រង់តែងទទូចសុំ ។ ពិតណាស់ ព្រះដ៏មាន-ព្រះភាគទ្រង់មានសេចក្ដីឧស្សាហ៍ ដល់ព្រមដោយសេចក្ដីករុណា តែងទទូចសុំឱ្យសត្វទាំងឡាយប្រតិបត្តិជាប្រយោជន៍ពិត ៗ ដោយមានព្រះពុទ្ធដីកាជាដើមថា សាធុ ភិក្ខវេ ភិក្ខុ កាលេន កាលំ អត្តសម្បត្តិំ បច្ចវេក្ខេយ្យ **ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកពិចារណាសម្បត្តិនៃខ្លួនសព្វ ៗ កាលជាការប្រពៃ**[១] ដូច្នេះ ហើយទ្រង់នាំសត្វទាំងនោះឱ្យដើរមក ក្នុងសេចក្ដីប្រតិបត្តិដែលជាប្រយោជន៍នោះ ។ ព្រះដ៏មានព្រះភាគទ្រង់ជាកំពូល និងជាធំ ព្រោះទ្រង់ដល់ព្រមហើយដោយភាពជាកំពូល និងភាពជាធំលើចិត្ត តែងស្វែងរក គឺគ្របដណ្ដប់លើសត្វទាំងពួង ព្រោះដូច្នោះ ទើបលោកពោលថា **នាថៈ** ដូច្នេះ ។ ក៏សេចក្ដីទាំងអស់នេះ អ្នកសិក្សាគប្បីប្រកបដោយលំអាននៃសព្ទថា **សត្ថា** ប្រែថា ព្រះលោកនាថ ទ្រង់ជាគ្រូ ។ បទថា

---

[១] សុត្តន្តបិដក អង្គុត្តរនិកាយ អដ្ឋកនិបាត នវមភាគ ៤៨ ទំព័រ ២០

**បរិក្ខាមិ** សេចក្តីថា នឹងសម្តែងដោយប្រការ ។ ពាក្យថា **មូលសិក្ខា** សំដៅដល់សិក្ខាសូម្បីទាំង ៣ គឺ អធិសីលសិក្ខា អធិចិត្តសិក្ខា និងអធិបញ្ញាសិក្ខាផង ព្រោះជាមូល គឺឫសគល់ដោយអត្ថនៃភាវសាធនៈ ដែលឧបសម្បន្នភិក្ខុតម្កល់ទុកស៊ប់ហើយផង ព្រោះភិក្ខុ សាមណេរគប្បីសិក្សាផង ទើបឈ្មោះថា **មូលសិក្ខា** ។ គម្ពីរដែលបំភ្លឺនូវសេចក្តីនៃសិក្ខានោះ លោកឱ្យឈ្មោះថា **មូលសិក្ខា** ដូច្នេះ ព្រោះលោកពោលទុកជាគម្ពីរយ៉ាងសង្ខេបក្នុងទីនុ៎ះ ។

បណ្តាសិក្ខាទាំងឡាយនោះ សីលដូចម្តេច ? អធិសីលដូចម្តេច ? ចិត្តដូចម្តេច ? អធិចិត្ត ដូចម្តេច ? បញ្ញា ដូចម្តេច ? អធិបញ្ញា ដូចម្តេច ? ខ្ញុំនឹងពោលដូចតទៅ ៖

សីលដែលមានអង្គ ៥ អង្គ ៨ និងអង្គ ១០ ឈ្មោះថា សីល តែម្យ៉ាងប៉ុណ្ណោះ ។ តែបាតិមោក្ខសំវរសីល លោកហៅថា អធិសីល ។ ពិតណាស់ សីលនោះប្រសើរលើស និងឧត្តមជាងលោកិយសីលទាំងពួង ដូចជាព្រះអាទិត្យប្រសើរឧត្តមជាងពន្លឺទាំងឡាយ ដូចជាភ្នំព្រះសុនេរុប្រសើរឧត្តមជាងភ្នំទាំងឡាយយ៉ាងនោះឯង ។ ម្យ៉ាងទៀត ក្រៅអំពីបាតិមោក្ខសំវរសីល សីលដែលសម្បយុត្តដោយមគ្គនិងផល ក៏ឈ្មោះថា អធិសីលដែរ តែសីលនោះ លោកមិនប្រាថ្នាបកស្រាយក្នុងទីនេះទេ ។ ពិតមែនភិក្ខុកាលសិក្សានូវសីលនោះរមែងមិនសេពនូវមេថុនធម្ម ។ ក៏ឯ

កុសលចិត្តជាកាមាវចរៈ ៨ ដួង និងលោកិយសមាបត្តិទាំង ៨ ឈ្មោះថា ចិត្ត ប៉ុណ្ណោះ ព្រោះធ្វើឱ្យជាចំណែកមួយ ។ រីឯសមាបត្តិ ៨ ដែលជាបាទនៃវិបស្សនា ទើប ហៅថា អធិចិត្ត ។ ពិតមែន ចិត្តនោះ ក្រៃលែង និងឧត្តមជាង លោកិយចិត្តទាំងអស់ ។ ម្យ៉ាងទៀត ក្រៅពីចិត្តទាំងនោះ មគ្គចិត្ត និងផលចិត្តក៏ជាអធិចិត្តដែរ តែចិត្តនោះ លោកមិនប្រាថ្នាយកក្នុងទីនេះទេ ។ ពិតមែន ភិក្ខុកាលរក្សានូវចិត្តនោះ រមែងមិនសេពមេថុនធម្ម ។ កម្មស្សកតាញាណដែលប្រព្រឹត្តទៅដោយ ន័យជាដើមថា ការឱ្យទានមានផល ការបូជាតូចមានផល ឈ្មោះថា បញ្ញា តែវិបស្សនាញាណដែលកំណត់នូវអាការៈនៃត្រៃលក្ខណ៍ ឈ្មោះថា អធិបញ្ញា ។ ពិតណាស់ បញ្ញានោះ ក្រៃលែង និងឧត្តមជាង លោកិយបញ្ញាទាំងពួង ។ ក៏ក្រៅពីបញ្ញានោះ មគ្គផលបញ្ញាក៏ឈ្មោះថា អធិបញ្ញា ដែរ តែបញ្ញានោះ លោកមិនប្រាថ្នាយកក្នុងទីនេះទេ ។ ពិតមែន ភិក្ខុកាលសិក្សាបញ្ញានោះ រមែងមិនសេពមេថុនធម្មទេ ។

បណ្ដាសិក្ខាទាំង ៣ នោះ ភិក្ខុកាលបដិបត្តិនូវសីលសូម្បីមានប្រការពីរយ៉ាង ដោយអំណាចចារិត្តសីល និងវារិតសីលតាមសមគួរដល់ពាក្យប្រៀនប្រដៅ (និង) កាលលះបង់នូវកិលេសទាំងឡាយដែលជាបដិបក្ខនឹងសីលនោះ ដោយអំណាចនៃតទង្គប្បហានៈ គប្បីសិក្សាអធិសីលសិក្ខា ។ ភិក្ខុកាលធ្វើនូវ

វិក្ខម្ភនប្បហានៈចំពោះពួកនីវរណៈទាំងឡាយ ដែលជាបដិបក្ខចំពោះឈាន ដោយអំណាចអភិឈាន ក្នុងអារម្មណ៍ទាំងឡាយតាមដែលពោលហើយ គប្បីសិក្សាអធិចិត្តសិក្ខា ។ តែថាភិក្ខុកាលកាត់ផ្ដាច់នូវកិលេសទាំងឡាយ ព្រមទាំងអនុស័យដោយតទង្គប្បហានៈ និងសមុច្ឆេទប្បហានៈ តាមសភាពដ៏សមគួរ គប្បីសិក្សាអធិបញ្ញាសិក្ខា ។ ព្រោះហេតុនោះ **មូលា** ដោយអត្ថថា ជាភាវសាធនៈដែលតម្កល់ស៊ប់ហើយផង សិក្ខានោះព្រោះជាធម៌ដែលភិក្ខុសាមណេរគប្បីសិក្សាផង ព្រោះហេតុដូច្នោះ ទើបឈ្មោះថា **មូលសិក្ខា** ។ មូលសិក្ខា (នេះ) លោកពោលហើយព្រោះសេចក្ដីប្រាថ្នាកិរិយាពោលនូវកម្ម ។

គឺគេតែងរួបរួម គឺថាតែងបំព្រួញចូលគ្នា ព្រោះហេតុនោះ ទើបឈ្មោះថា **សមាសោ ឬសមាសតោ** ដោយសេចក្ដីបំព្រួញនោះ ។ បុគ្គលដែលសង្ឃព្រមព្រៀងគ្នា (ឱ្យ)ឧបសម្បទាដោយញត្តិចតុត្ថកម្មមិនកម្រើកគួរដល់ហេតុ ដូច្នោះ ទើបឈ្មោះថា **ភិក្ខុ** ។ ក្នុងឧបសម្បទានោះ ក្នុងកម្មដែលគប្បីធ្វើដោយសង្ឃបញ្ចវគ្គ ភិក្ខុទាំងឡាយមានប្រមាណប៉ុណ្ណា គួរដល់កម្មដោយបរិយាយយ៉ាងទាបបំផុត ភិក្ខុទាំងនោះមកហើយ, ឆន្ទៈនៃពួកភិក្ខុដែលគួរដល់ឆន្ទៈ បាននាំមកហើយ, ភាពនៃកម្មមិនគប្បីកម្រើក ព្រោះមានវត្ថុសម្បត្តិ ញត្តិសម្បត្តិ អនុស្សាវនាសម្បត្តិ សីមាសម្បត្តិ និងបរិសសម្បត្តិ ដល់ព្រមហើយដោយវិន័យកម្ម

ប្រកបដោយធម៌ មានញត្តិជាគម្រប់ ៤ ពោលគឺ កម្មដែលសង្ឃចូលទៅកាន់ភាពព្រមព្រៀងគ្នាក្នុងកម្មតែមួយ ព្រោះមិនហាមនូវពួកភិក្ខុដែលមានចំពោះមុខ គប្បីធ្វើដោយអនុស្សាវនា ៣ ញត្តិ ១, បុគ្គលនោះ ឈ្មោះថា **ឧបសម្បន្ន** តាមសមគួរដល់ឋានតាមសមគួរដល់ហេតុ តាមសមគួរដល់សត្ថុសាសនា ដែលចូលទៅកាន់ភាពនៃកម្មដែលមិនគប្បីហាមឃាត់ដល់ព្រមហើយ គឺថា ដល់ហើយនូវភាពដ៏ខ្ពស់ ។ ពិតមែន ភិក្ខុភាវៈ គឺភាវៈដ៏ខ្ពស់ ។ ក៏ភិក្ខុភាវៈនោះ លោកហៅថា **ឧបសម្បន្ន** ព្រោះភាពនៃភាវៈនោះ ប្រកបដោយកម្មតាមដែលពោលទុកហើយ **តេន ភិក្ខុនា** គឺភិក្ខុនោះ ។ ឈ្មោះថា **ភិក្ខុខ្ចី** ព្រោះភាពនៃវស្សា ៥ មិនគ្រប់, ភិក្ខុខ្ចីនោះ គឺភិក្ខុបួសថ្មី អធិប្បាយថា បួសមិនទាន់បានយូរនៅឡើយ ។ ពាក្យថា អាទោ **គ្រាដំបូង** សេចក្ដីថា ក្នុងខាងដើមនោះឯង ឬថា តាំងពីដំបូងនោះឯង ។ ម្យ៉ាងទៀត ព្រះថេរៈញ៉ាំងសេចក្ដីសង្វេគឱ្យកើតឡើងដល់កុលបុត្រទាំងឡាយ ដែលបួសដោយសទ្ធា ដោយទោស គឺ ភាពជាអ្នកខ្ជិលច្រអូស ជាអ្នកមិនបដិបត្តិ ដោយទោស គឺការមិនដឹង និងអ្នកបដិបត្តិ ដោយប្រការដទៃ ដោយពាក្យថា **អាទោ** (ខាងដើម, ដំបូង) ។

សួរថា ព្រោះហេតុអ្វី?

ឆ្លើយថា ខណៈដែលគេបានដោយកម្រ ភិក្ខុមិនត្រូវបានមកប្រជុំគ្នា(ធ្វើទេ) ញុំាងខណៈនោះឱ្យកន្លងទៅដោយការខ្ជិល ឬការខ្វល់ខ្វាយដោយពាក្យគ្មានប្រយោជន៍ទៅវិញ ។

សួរថា គប្បីធ្វើនូវអ្វី?

ឆ្លើយថា គប្បីញុំាងសេចក្ដីអើពើឱ្យកើតជាប់មិនដាច់តែម្ដង ក្នុងសិក្ខាទាំង ៣ តាំងតែពីដើម ដូច្នេះឯង ។

ពាក្យថា **មូលភាសាយ** គឺ ដោយភាសាដើមរបស់អ្នកស្រុកមគធៈ អធិប្បាយថា ដោយភាសាជាភាវនិរុត្តិ ព្រោះពាក្យថា ៖

សា មាគធី មូលភាសា  នរា យាយាទិកប្បិកា
ព្រហ្មាနော ចស្សុតាលាបា  សម្ពុទ្ធា ចាបិ ភាសរេតិ

មូលភាសានោះ មានក្នុងដែនមគធៈ នរជនទាំងឡាយសម្រេចកិច្ច មានទៅជាដើម គប្បីបរិយាយគ្នា ព្រហ្មក្ដីសូម្បីព្រះសម្ពុទ្ធក្ដី ទ្រង់តែងពោល(ដោយភាសានោះ) ។ ពាក្យថា **សិក្ខិតុំ** គឺ ដើម្បីរៀនយក ៕

# ១. បារាជិកនិទ្ទេសវណ្ណនា

## មេថុនធម្មសិក្ខាបទ [២]

១. ក្នុងពេលនេះ អធិសីលសិក្ខាតែម្យ៉ាង ដែលលោកពោលទុកមុន ព្រោះជាឫសគល់នៃសិក្ខាទាំងពួង ។ ក៏ក្នុងអធិសីលសិក្ខានោះ លោកអាចារ្យកាលសម្ដែងថា អ្នកសិក្សាគប្បីស្គាល់អាបត្តិបារាជិកមុនគេបង្អស់ ព្រោះជាអាបត្តិធំ និងព្រោះប្រព្រឹត្តទៅដោយអំណាចការកាត់ផ្ដាច់នូវឫសគល់ ទើបពោលនូវពាក្យថា **សំ និមិត្តំ** ដូច្នេះ ជាដើម ។

ក្នុងអធិការនោះ មានអធិប្បាយថា ភិក្ខុកាលបញ្ចូល **នូវនិមិត្តនោះ** ក្នុងប្រជុំ ៣ នៃមគ្គ ជាអ្នកច្យុតហើយ (ត្រូវអាបត្តិបារាជិក) ។ ពីរបទថា **សំ និមិត្តំ** បានដល់ អង្គជាតរបស់ខ្លួន សូម្បីមានប្រមាណប៉ុនមួយគ្រាប់ល្ង ដោយកំណត់យ៉ាងទាបបំផុត ។ ពាក្យថា **ភិក្ខុ** គឺ បុគ្គលអ្នកមានសិក្ខាមិនដាច់ហើយ ។

វិនិច្ឆ័យក្នុងពាក្យថា **មគ្គត្តយេ ប្រជុំបីនៃមគ្គ** នេះ គប្បីជ្រាបដូច្នេះ ៖

[២] វិ. មហាវិ. ភាគ ១ ទំព័រ ៣៥ ដល់ ១៣៤

មានសត្វ ១២ ពួក ដែលអាស្រ័យនិមិត្តជាវត្ថុនៃអាបត្តិបារាជិក ដោយអំណាចនៃមនុស្ស អមនុស្ស និងសត្វតិរច្ឆាន គឺ ស្ត្រី ៣ ពួក ឧភតោព្យញ្ជនៈ ៣ ពួក បណ្ឌកៈ ៣ ពួក បុរស ៣ ពួក ។ សត្វទាំងនោះ មានមគ្គ ៣ ដោយអំណាចនៃវច្ចមគ្គ បស្សាវមគ្គ និងមុខមគ្គ ។ ក្នុងអធិការនោះ មានមគ្គ ៣០ ដោយអំណាចនៃសត្វទាំងអស់ គឺ មគ្គរបស់ពួកមនុស្សស្រី និងមនុស្សមានភេទពីរជាដើម មាន ៩ ដូចគ្នា គឺ មនុស្សស្រី មានមគ្គ ៣ អមនុស្សស្រីមានមគ្គ ៣ សត្វតិរច្ឆានញីមានមគ្គ ៣ ។ ឯមគ្គរបស់ពួកមនុស្សប្រុស និងខ្ទើយជាដើមមាន ៦ គឺ (រាប់មគ្គ) ពីរៗ ដោយអំណាចវច្ចមគ្គ និងមុខមគ្គ ។ មគ្គរបស់អមនុស្សប្រុសជាដើម ក៏ដូចគ្នា ។ លោកអាចារ្យសង្គ្រោះយកមគ្គទាំងពួងនោះ ហើយពោលក្នុងទីនេះថា **មគ្គត្តយេ** ដូច្នេះ ។ ក្នុងប្រជុំបីនៃមគ្គនោះ អធិប្បាយថា ក្នុងមគ្គណាមួយ បណ្តាមគ្គទាំង ៣ របស់សត្វទាំង ១២ ។ ពាក្យថា **ចុតោ** គឺ ជាអ្នកច្យុតហើយ ចាកព្រះសាសនា ដូចជាសត្វច្យុតហើយចាកភាពជា(សក្កៈ) អ្នកអង់អាច ឬភាពជា(ព្រហ្ម) អ្នកប្រសើរ អធិប្បាយថា **បារាជិកោ ហោតិ** គឺ ជាអ្នកចាលចាញ់ហើយ ។

ឥឡូវនេះ សេចក្តីព្យាយាមរបស់ខ្លួនតែម្យ៉ាង ឈ្មោះថា បញ្ចូលក៏ទេដែរ សូម្បីការព្យាយាមរបស់អ្នកដទៃ (ក៏ឈ្មោះថា

ការបញ្ចូលដែរ) ។ មែន! ក្នុងសេចក្ដីនោះ លោកអាចារ្យពោល ពាក្យថា **បវេសនា** (បញ្ចូល) ជាដើម ដើម្បីសម្ដែងថា កាលមាន ចិត្តគិតនឹងសេព ត្រូវអាបត្តិបារាជិក ។

សេចក្ដីនៃពាក្យនោះ គឺ ភិក្ខុណា កាលត្រេកអរ ចំពោះ ខណៈណាមួយ បណ្ដាខណៈកំពុងចូល ស្ថិតនៅ ដកចេញ និង ចូលទៅស៊ប់ហើយ **បេបិ សាទិយំ** ថាបើ ញុំាងសេវនចិត្តឱ្យតាំង ឡើងក្នុងខណៈនោះ **បុគ្គោ** ពាល់ត្រូវហើយ គឺជាអ្នកត្រូវអាបត្តិ បារាជិក ។ តែភិក្ខុណា កាលមិនត្រេកអរដោយប្រការទាំងពួង តែងសំគាល់ដូចជាបញ្ចូលទៅកាន់មាត់អាសីវិ្តស ឬទៅកាន់ រណ្ដៅរងើកភ្លើង ភិក្ខុនោះ រមែងជាអ្នកមិនមានទោសទេ។ ក៏ឯ អង្គជាតដល់ហើយនូវសម័យនៃសុក្កវិស្សដ្ឋិ ឈ្មោះថា **ឋិតំ** ស្ថិត នៅ ក្នុងទីនេះ។

## បឋមបារាជិកសិក្ខាបទ ចប់

# អទិន្នាទានសិក្ខាបទ[៧]

២-៧. ឥឡូវនេះ ដើម្បីសម្តែងនូវសិក្ខាបទទី ២ លោកអាចារ្យទើបពោលពាក្យថា **អទិន្នំ មានុសំ ភណ្ឌំ ទ្រព្យជារបស់មនុស្សដែលគេមិនបានឱ្យ** ដូច្នេះ ជាដើម ។

ក្នុងគាថានោះ អ្នកសិក្សាគប្បីសម្ពន្ធថាៈ

យោ ភិក្ខុ អទិន្នំ មានុសំ គរុកំ ភណ្ឌំ បញ្ចវីសាវហារេសុ យេន កេនចិ អវហារេន អាទិយន្តោ ចុតោ ភវេ ភិក្ខុណាមួយកាលកាន់យកនូវភណ្ឌៈដ៏ធ្ងន់ ជារបស់មនុស្សដែលគេមិនបានឱ្យ ដោយបណ្តាអវហារ ២៥ ណាមួយ គប្បីជាអ្នកពាល់ត្រូវនូវគរុកាបត្តិ (អាបត្តិបារាជិក) ។

ពាក្យថា **អទិន្នំ** គឺ ភណ្ឌៈណាមួយដែលមានម្ចាស់គេហួងហែងថែរក្សា, ទ្រព្យនោះ ដែលម្ចាស់ទាំងឡាយនោះ មិនបានឱ្យដោយកាយ ឬវាចា ដូច្នោះ ទើបឈ្មោះថា **អទិន្នំ** គឺមិនបានឱ្យ សេចក្តីថា គេមិនបានបោះបង់ មិនបានលះបង់ គឺគេនៅរក្សាគ្រប់គ្រង នៅប្រកាន់យកថា ជារបស់អញ គឺថាអ្នកដទៃនៅហួងហែងថែរក្សា, ទ្រព្យនេះ ជារបស់នៃមនុស្ស ទើបឈ្មោះថា **មានុសំ** ប្រែថា ជារបស់នៃមនុស្ស ។

[៧] វិ. មហាវិ. ភាគ ១ ទំព័រ ១៣៥ ដល់ ២២១

លោកអាចារ្យធ្វើឱ្យស្មើគ្នាដោយពាក្យនេះថា **ភណ្ឌំ** (ទ្រព្យ) ។ បទថា **ថេយ្យាយេកេន** កាត់បទជា **ថេយ្យាយ+ឯកេន** ប្រែថា ដោយអវហារមួយ ។ លោកអាចារ្យធ្វើនូវលិង្គភេទ ពោលទុកហើយ ។ មួយទៀតបាលីថា **ថេយ្យា កេនចិ** ដូច្នេះវិញក៏មាន ។ ក្នុងគាថានោះ បទថា **ថេនោ** ប្រែថា ចោរ, ភាវៈនៃចោរ ឈ្មោះថា **ថេយ្យា**, ក៏ពាក្យនេះ ជាបឋមាវិភត្តិ ចុះក្នុងអត្ថនៃតតិយាវិភត្តិ ព្រោះហេតុនោះ ត្រូវសរសេរថា **កេនចិ ថេយ្យេន** ដោយភាពជាចោរណាមួយ គឺថា **អវហារេន** ដោយវិធីលួចណាមួយ ។ បទថា **អាទិយំ** ប្រែថា ចាប់កាន់យក ។ ពាក្យថា **បញ្ចវីសាវហារេសុ** បានដល់ អវហារ ២៥ ព្រោះប្រមូលនូវពួក ៥ ៗ (នៃបញ្ចកៈមួយៗ) ។ ជំនុំអវហារទាំង ២៥ នោះ គឺរាប់នានាភណ្ឌបញ្ចកៈ ១ ឯកភណ្ឌបញ្ចកៈ ១ សាហត្ថិកបញ្ចកៈ ១ បុព្វប្បយោគបញ្ចកៈ ១ ថេយ្យាវហារបញ្ចកៈ ១ ឈ្មោះថា **បញ្ចបញ្ចកានិ** អវហារ ៥ ៗ នៃបញ្ចកៈនីមួយៗ ដូច្នេះ ។

បណ្ដាបញ្ចកៈទាំង ៥ នោះ អ្នកសិក្សាគប្បីជ្រាបសេចក្ដីអធិប្បាយដូចតទៅនេះ ៖

នានាភណ្ឌបញ្ចកៈ (បាន) ដោយអំណាចភណ្ឌៈដែលលាយដោយទ្រព្យមានវិញ្ញាណ និងទ្រព្យឥតវិញ្ញាណ ឯកភណ្ឌ-

បញ្ចកៈ (បាន) ដោយអំណាចទ្រព្យមានវិញ្ញាណ ។ បណ្ដាបញ្ចកៈពីរនោះ គប្បីជ្រាបយ៉ាងនេះសិន ដោយអំណាចភណ្ឌៈផ្សេងៗគ្នា ៖

ភិក្ខុណាមួយ បន្លំយកសួន ត្រូវអាបត្តិទុក្កដ ។ ញុំាងសេចក្ដីសង្ស័យឱ្យកើតឡើងដល់ម្ចាស់របស់ត្រូវអាបត្តិថុល្លច្ច័យ ម្ចាស់របស់ដាក់ធុរៈចុះថា សួននឹងមិនជារបស់យើងទៀតទេ ត្រូវអាបត្តិបារាជិក ។

ភិក្ខុកាលនាំទៅនូវភណ្ឌៈរបស់អ្នកដទៃ មានថេយ្យចិត្តស្ទាបអង្អែលភារៈលើក្បាល ត្រូវអាបត្តិទុក្កដ ញុំាងភណ្ឌៈនោះឱ្យកំរើកត្រូវអាបត្តិថុល្លច្ច័យ ដាក់ភារៈមកដល់ក ត្រូវអាបត្តិបារាជិក កាលម្ចាស់ទ្រព្យទារយកភណ្ឌៈដែលគេផ្ញើទុកថា លោកចូរឱ្យភណ្ឌៈមកខ្ញុំវិញ ភិក្ខុក៏ពោលថា អាត្មាមិនបានកាន់យកទេ ត្រូវអាបត្តិទុក្កដ ញុំាងសេចក្ដីសង្ស័យឱ្យកើតឡើងដល់ម្ចាស់ទ្រព្យត្រូវអាបត្តិថុល្លច្ច័យ ម្ចាស់ទ្រព្យដាក់ធុរៈថា លោកនឹងមិនឱ្យដល់អញវិញទេ ត្រូវអាបត្តិបារាជិក ។ ភិក្ខុគិតថា អញនឹងនាំយកទៅនូវភណ្ឌៈព្រមទាំងអ្នកទូល ឬកាន់ទៅ ញុំាងជំហានទី ១ ឱ្យឈានទៅ ត្រូវអាបត្តិថុល្លច្ច័យ ឱ្យជំហានទី ២ ឈានទៅ ត្រូវអាបត្តិបារាជិក ។ ភិក្ខុមានថេយ្យចិត្តចាប់ពាល់ភណ្ឌៈលើគោក ត្រូវអាបត្តិទុក្កដ ។ ញុំាងភណ្ឌៈឱ្យកម្រើក ត្រូវអាបត្តិថុល្លច្ច័យ ឱ្យ

ឃ្លាតចាកឋាន ត្រូវអាបត្តិបារាជិក ។ នេះជាយោជនាដោយអំណាចនៃភណ្ឌៈផ្សេង ៗ គ្នាក្នុងទីនេះ ។

ក៏សេចក្តីវិនិច្ឆ័យដោយអំណាចនៃភណ្ឌៈតែមួយគប្បីជ្រាបដូចនេះ ៖

ភិក្ខុកាន់យក នាំយក លួចយក ញ៉ាំងឥរិយាបថឱ្យកំរើក ឬញ៉ាំងឱ្យឃ្លាតចាកទី នូវទាសៈ ឬសត្វតិរច្ឆានដែលមានម្ចាស់ តាមន័យមានការបន្លំយកជាដើម តាមដែលពោលហើយយ៉ាងណា ។ នេះជាយោជនាដោយអំណាចនៃភណ្ឌៈតែមួយក្នុងទីនេះ

អវហារ ៥ គឺ សាហត្ថិកៈ អាណត្តិកៈ និស្សគ្គិយៈ អត្ថសាធកៈ ធុរៈនិក្ខេបៈ។ បណ្តាអវហារទាំង ៥ នោះ ភិក្ខុលួចភណ្ឌៈរបស់អ្នកដទៃដោយដៃរបស់ខ្លួន ឈ្មោះថា **សាហត្ថិកៈ** ។ ភិក្ខុបង្គាប់អ្នកដទៃថា អ្នកចូរលួចភណ្ឌៈរបស់មនុស្សឈ្មោះឯណោះ ឈ្មោះថា **អាណត្តិកៈ** ។ ភិក្ខុឈរនៅត្រង់គយខាងក្នុង ហើយឱ្យភណ្ឌៈធ្លាក់រំលងទៅខាងក្រៅដែនគយត្រូវអាបត្តិបារាជិក ឈ្មោះថា **និស្សគ្គិយៈ** ។ ភិក្ខុបង្គាប់អ្នកដទៃថា លោកចូរលួចយកភណ្ឌៈ(របស់ជន)ឈ្មោះឯណោះ តាមពេលណាដែលលោកអាចយកបានឈ្មោះថា **អត្ថសាធកៈ**, ក្នុងសេចក្តីថា បើភិក្ខុជាអ្នកលួចគ្មានអន្តរាយលួចយកភណ្ឌៈបានមក ភិក្ខុអ្នកបង្គាប់ ត្រូវអាបត្តិបារាជិក ក្នុងខណៈបង្គាប់នោះតែម្តង តែជាអវហារ ក្នុងកាលដែលលួចបានមកហើយ នេះឈ្មោះថា **អត្ថសាធកៈ** ។ ក៏ឯ

ចំពោះ**ធុរនិក្ខេបះ** គប្បីជ្រាបដោយអំណាចភណ្ឌៈដែលគេផ្ញើទុក ។ នេះជា**សាហត្ថិកបញ្ចកៈ** ។

អវហារ ៥ ទៀត គឺ បុព្វប្បយោគ សហប្បយោគ សំវិធាវហារ សង្កេតកម្ម និមិត្តកម្ម ។ បណ្ដាអវហារទាំង ៥ នោះ **បុព្វប្បយោគ** គប្បីជ្រាបដោយអំណាចការបង្គាប់ **សហប្ប-យោគ** គប្បីជ្រាបដោយអំណាចការឱ្យឃ្លាតចាកទី ។ ពួកភិក្ខុច្រើនរូបបបួលគ្នាដើរទៅថា យើងទៅកាន់ផ្ទះឈ្មោះឯណោះ ហើយទម្លុះដំបូល ឬទំលាយជញ្ជាំង ហើយលួចយកទ្រព្យ បណ្ដាភិក្ខុទាំងនោះ ភិក្ខុមួយរូបលួចយកទ្រព្យ, កាលទ្រព្យដែលភិក្ខុនោះ លើកឡើងហើយ ជាអាបត្តិបារាជិក ដល់ភិក្ខុទាំងអស់ ឈ្មោះថា **សំវិធាវហារ** ។

ដែលឈ្មោះថា **សង្កេតកម្ម** គឺ កម្ម គឺថា កិរិយាដឹងច្បាស់ បានដល់ ការធ្វើសេចក្ដីសម្គាល់ដោយអំណាចកាលបរិច្ឆេទ ។ ក្នុងសេចក្ដីនេះ អាណាបកភិក្ខុពោលបង្គាប់ថា លោកចូរលួចក្នុងបុរេភត្ត ភិក្ខុលួចក្នុងបុរេភត្តនាថ្ងៃនុ៎ះ បុរេភត្តថ្ងៃស្អែក ឬបុរេភត្តឆ្នាំក្រោយក៏ដោយ រមែងមិនខុសសង្កេតឡើយ, ក្នុងខណៈដែលធ្វើការកំណត់បង្គាប់ភិក្ខុក្រៅពីនេះ តែធ្វើឱ្យឃ្លាតចាកទីដោយប្រការយ៉ាងនេះ ភិក្ខុពីររូប រមែងត្រូវអាបត្តិបារាជិកដូចគ្នា ។

ការធ្វើនូវនិមិត្តណាមួយ ដើម្បីឱ្យជាគ្រឿងសម្គាល់ បានឈ្មោះថា **និមិត្តកម្ម** បានដល់ ប្រការមិនតែមួយ ដោយន័យមាន

ការប៉ប្រិចភ្នែក បក់ដៃ ទះដៃ ផ្ទាត់ម្រាមដៃ ងក់ក្បាល ឬក្អក គ្រហែមជាដើម ។ អវហារកភិក្ខុ (អ្នកលួច)ដែលអាណាបកភិក្ខុ (អ្នកប្រើ)បង្គាប់ហើយ កាលសម្គាល់នូវទ្រព្យតាមដែលធ្វើនិមិត្ត សញ្ញាប្រាប់ទុកនោះថា នុ៎ះ ក៏លួចយកទ្រព្យនោះឯង ជាអាបត្តិទាំងពីររូប, កាលសម្គាល់នូវទ្រព្យដែលគេពោលថា ចូរលួចនោះថា នុ៎ះ តែលួចយកទ្រព្យដទៃដែលស្ថិតនៅក្នុងទីនោះដែរទៅវិញ រមែងមិនជាអាបត្តិដល់ភិក្ខុអ្នកបង្គាប់ទេ ។ នេះ ជា **បុព្វប្បយោគបញ្ចកៈ** ។

អវហារ ៥ ដទៃទៀត គឺ ថេយ្យាវហារ បសយ្ហាវហារ បរិកប្បាវហារ បដិច្ឆន្នាវហារ កុសាវហារ ។ បណ្ដាអវហារទាំង ៥ នោះ ភិក្ខុណា បញ្ឆោតគេកាន់យកដោយវត្ថុក្លែងក្លាយ ដោយគ្រឿងរង្វាស់កោង និងកហាបណៈបន្លំក្លែងក្លាយជាដើម ភិក្ខុនោះ កាលកាន់យកយ៉ាងនេះ អវហារ ឈ្មោះថា **ថេយ្យាវហារ** ។ ភិក្ខុណា សម្លុតគម្រាមកំហែងឱ្យខ្លាច ហើយកាន់យកទ្រព្យជារបស់អ្នកទាំងនោះក្ដី ឬភិក្ខុណា កាន់យកនូវទ្រព្យដ៏លើសជាងសួយអាករដែលត្រូវបានដល់ខ្លួនដោយពលក្ការ ដូចពួកឥស្សរជនមានស្ដេចនិងមហាមាត្យរបស់ស្ដេចក្ដី ភិក្ខុនោះ កាលកាន់យកយ៉ាងនេះ អវហារ ឈ្មោះថា **បសយ្ហាវហារ** ។ តែភិក្ខុកាលកំណត់ហើយទើបកាន់យក អវហារ ឈ្មោះថា **បរិកប្បាវហារ** ។ បរិកប្បាវហារនោះ មាន ២ យ៉ាង ដោយអំណាចភណ្ឌបរិកប្ប

និងឱកាសបរិកប្ប ។ ក្នុងភណ្ឌបរិកប្ប និងឱកាសបរិកប្ប ២ យ៉ាងនោះ ភិក្ខុកំណត់ថា បើជាសំពត់សាដក យើងនឹងកាន់យក បើជាអំបោះយើងនឹងមិនកាន់យកទេ ហើយក៏ចាប់យកការុង ក្នុងទីងងឹត បើវត្ថុក្នុងការុងនោះ ជាសំពត់សាដក ភិក្ខុត្រូវអាបត្តិបារាជិក ក្នុងពេលលើកឡើងតែម្តង។ បើជាអំបោះ នៅរក្សាសិន នេះ ឈ្មោះថា ភណ្ឌបរិកប្ប ។

ភិក្ខុកំណត់ទីកន្លែងហើយលួចយកទ្រព្យ ត្រឹមតែភិក្ខុនោះឈានកន្លងទីកំណត់ ដែលខ្លួនកំណត់ហើយនោះប៉ុណ្ណោះ ត្រូវអាបត្តិបារាជិក ។ នេះឈ្មោះថា ឱកាសបរិកប្ប ។ ភិក្ខុកាលកំណត់ហើយលួចយកដោយអំណាចបរិកប្បទាំង ២ នេះ យ៉ាងនេះ អវហារ ឈ្មោះថា **បរិកប្បាវហារ** ។

ភិក្ខុបិទបាំងហើយលួចយកទ្រព្យរបស់អ្នកដទៃ អវហារឈ្មោះថា **បដិច្ឆន្នាវហារ** ។ ប្តូរស្លាកលួចយកទៅ ឈ្មោះថា **កុសាវហារ** ។ ភិក្ខុណា ដាក់ស្លាកចុះហើយ កាលសង្ឃកំពុងចែកចីវរ ឃើញចំណែករបស់ភិក្ខុដទៃមានតម្លៃតិចជាង ឬមានតម្លៃច្រើនជាង ឬស្មើគ្នាដែលស្ថិតនៅជិតចំណែករបស់ខ្លួន ប្រសិនបើលើកស្លាកឡើងអំពីចំណែកភិក្ខុដទៃមុន ក្នុងខណៈលើកឡើងមិនទាន់ត្រូវអាបត្តិទេ ព្រោះមានប្រាថ្នានឹងដាក់ចុះក្នុងចំណែករបស់ខ្លួន សូម្បីក្នុងខណៈដាក់ចុះ ក៏មិនទាន់ត្រូវអាបត្តិដែរ ។ បើទោះបីពេលលើកស្លាក អំពីចំណែករបស់ខ្លួនឡើង ក្នុងខណៈ

លើកឡើង មិនទាន់ត្រូវអាបត្តិឡើយ ។ តែកាលភិក្ខុលើកស្លាករបស់ខ្លួនឡើងហើយទំលាក់ចុះទៅក្នុងចំណែកភិក្ខុដទៃ គ្រាន់តែផុតអំពីដៃ ត្រូវអាបត្តិបារាជិក ។ នេះ ឈ្មោះថា **កុសាវហារ** ។ ដូច្នេះ ភិក្ខុកាលលួចយកដោយអវហារ ២៥ នេះ អវហារ ណាមួយ ត្រូវអាបត្តិបារាជិក ។

ពាក្យថា **គរុកំ ដ៏ធ្ងន់** គឺ ៥ មាសកៈ ។ ពិតមែន មាសកៈ ២០ ត្រូវជាមួយកហាបណៈ, មួយភាគបួននៃកហាបណៈ ឈ្មោះថា ១ បាទ ។ ព្រោះហេតុនោះ មាសកៈ ៥ ក្តី មួយបាទក្តី ឈ្មោះថា **គរុកំ** ។ ក្នុងមាសកៈនោះ គប្បីជ្រាបដូច្នេះ (រាប់)ដោយអំណាចស្រូវ ព្រោះពាក្យថា ៤ គ្រាប់ស្រូវ ត្រូវជា ១ គុញ្ជា, ២ គុញ្ជា ត្រូវជា ១ មាសកៈ, ដូច្នេះ ៤០ គ្រាប់ស្រូវ ត្រូវជា ១០ គុញ្ជា គឺ ស្មើ ៥ មាសកៈ ។ ក៏ឯពាក្យណា ដែលលោកពោលថា ២០ គ្រាប់ស្រូវ ក្នុងសាមណេរសិក្ខា, ពាក្យនោះមិនត្រឹមត្រូវតាមព្រះបាលី មិនមានក្នុងព្រះអដ្ឋកថា ។ ពាក្យនោះ អ្នកសិក្សាគប្បីពិចារណាមើលផងចុះ ។

## ទុតិយបារាជិកសិក្ខាបទ ចប់

# មនុស្សវិគ្គហសិក្ខាបទ[៤]

៨. ឥឡូវនេះ ដើម្បីសម្ដែងសិក្ខាបទទី ៣ លោកអាចារ្យទើបពោលពាក្យជាដើមថា **មនុស្សបាណំ បាណោ** ដូច្នេះ ។

ក្នុងគាថានោះ សេចក្ដីជាពួកដូច្នេះ ៖

យោ ភិក្ខុ មនុស្សបាណោ ឥតិ ជានន្តោ វធកបិត្តេន មនុស្សបាណំ ជីវិតា វិយោជេតិ សោ ភិក្ខុ សាសនា បារាជិកោ ហោតិ ភិក្ខុឯណា កាលដឹងថាសត្វមានជាតិជាមនុស្ស ហើយមានវធកចិត្ត ញ៉ាំងសត្វមានជីវិតមានជាតិជាមនុស្ស ឱ្យឃ្លាតចាកជីវិត ភិក្ខុនោះ រមែងជាអ្នកចាលចាញ់ចាកព្រះសាសនា ។

ពាក្យថា **មនុស្សបាណំ** សេចក្ដីថា **សត្វមានជីវិតមានជាតិជាមនុស្ស** រាប់ពីដើម ចាប់ពីកលលរូប ដែលល្អិតក្រៃលែង ព្រមជាមួយការកើតឡើងដោយបដិសន្ធិចិត្ត ក្នុងផ្ទៃនៃមាតា រហូតដល់សត្វធ្វើមរណកាល ដែលប្រកបដោយអាយុ ១២០ តាមប្រក្រតី អត្តភាពដែលដល់ហើយនូវសេចក្ដីចម្រើនតាមលំដាប់ក្នុងចន្លោះនេះ អត្តភាពនុ៎ះ ឈ្មោះថា **មនុស្សបាណោ** សត្វមានជាតិជាមនុស្សដូច្នេះឯង ។ ពីរបទថា **បាណោតិ ជានំ** សេចក្ដីថា កាលដឹងថា សត្វមានជីវិត អធិប្បាយថា កាលដឹងថា

---

[៤] វិ. មហាវិ. ភាគ ១ ទំព័រ ២២២ ដល់ ២៨៤

អញញុំាំងសត្វមានជីវិត មានជាតិជាមនុស្សនោះឱ្យដាច់ចាក ជីវិត ។ បទថា **វធកចេតសា** គឺ ដោយវធកចិត្ត ។ បទនេះ ជាតតិយាវិភត្តិចុះក្នុងអត្ថឥត្ថម្ភូត អធិប្បាយថា មានវធកចិត្ត គឺមានបំណងឱ្យស្លាប់ ។ ពាក្យថា **ជីវិតា** គឺ ចាកជីវិតិន្ទ្រិយ ។ ពាក្យថា **យោ** ជាពាក្យដែលមិនកំណត់ **ភិក្ខុណាមួយ** ។ អ្នកសិក្សាគប្បីជ្រាបកិរិយាកំណត់ដោយពាក្យថា **សោ ភិក្ខុនោះ** ។

ពាក្យថា **វិយោជេតិ** សេចក្តីថា ភិក្ខុញុំាំងរូបកាយនៃមនុស្សមានប្រការដូចពោលហើយ ដោយសេចក្តីព្យាយាមដ៏សមគួរដល់កម្មនោះ ដោយការកំដៅ និងការគក់ច្របាច់ក្តី ដោយការផ្សំថ្នាំក្តី វិធីសូម្បីដ៏លើសជាងនោះក្តី សូម្បីក្នុងកាលនៃកលលរូប[៥] ឱ្យឃ្លាតចាកជីវិត ។ ពាក្យថា **សាសតា** ជាបញ្ចមី

[៥] មានសេចក្តីពន្យល់ក្នុងគម្ពីរ **ព្រះអភិធម្មត្ថាធិប្បាយ** របស់សម្តេចព្រះធម្មលិខិត ឧត្តមក្រុមប្រឹក្សា ល្វី ឯម យ៉ាងនេះ ៖ ត្រូវយកសក់របស់មនុស្សក្នុងជម្ពូទ្វីបមួយសរសៃមកច្រៀកជា ៨ ចម្រៀក ហើយចោល ៧ ចម្រៀកចេញ យកតែមួយចម្រៀកយ៉ាងល្អិតតូចឆ្មារបំផុតបានប៉ុនសក់របស់មនុស្សក្នុងឧត្តរកុរុទ្វីបមួយសរសៃ ហើយយកសក់របស់មនុស្សក្នុងឧត្តរកុរុទ្វីបមួយសរសៃយ៉ាងល្អិតតូចឆ្មារបំផុតនោះមកច្រៀកជា ៨ ចម្រៀកទៀត ហើយចោល ៧ ចម្រៀកចេញ យកតែមួយចម្រៀកមកជ្រលក់នឹងប្រេងល្ងដ៏ថ្លាស្អាតជាប់នឹងចម្រៀកសក់នោះប៉ុន្មាន ក៏ពាក្យដែលបណ្ឌិតពោលឱ្យឈ្មោះថា កលលរូបនោះ មានចំនួនយ៉ាងតិចដ៏ភ្លឺថ្លាស្អាតប៉ុណ្ណោះឯងរូបនេះ កើតឡើងព្រមជាមួយនឹងបដិសន្ធិចិត្តជាបឋម រហូតវារៈ ៧ ថ្ងៃ ។ ប្រស្នាទី ៧៦ ទំព័រ ២៣២

វិភត្តិចុះក្នុងប្រយោគនៃបរាបុព្វជិធាតុ  សេចក្ដីថា  ចាកសាសនា នៃព្រះសាស្ដានោះ ។ ពាក្យថា **បរាជិតោ** ប្រែថា **ចាញ់ហើយ** គឺ ដល់ហើយនូវបរាជ័យ ។ ពាក្យថា **ហោតិ** ជាបាលីសេសសល់ ។

## តតិយបារាជិកសិក្ខាបទ ចប់

# ឧត្តរិមនុស្សធម្មសិក្ខាបទ[៦]

៩. ឥឡូវនេះ ដើម្បីសម្ដែងសិក្ខាបទទី ៤ លោកអាចារ្យទើបពោលថា **ឈានាទិភេទំ** ជាដើម ។

ក្នុងគាថានោះ មានសេចក្ដីអធិប្បាយដូច្នេះ ៖

យោ ភិក្ខុ អញ្ញាបទេសញ្ច អធិមានញ្ច វជ្ជេត្វា ហទយេ អសន្តំ ឈានាទិភេទំ ធម្មំ មនុស្សជាតិកស្ស សត្តស្ស វទេយ្យ តស្មឹ ខណេ ញាតេ សោ តតោ សាសនា បារាជិកោ ឯវ ហោតិ ភិក្ខុណា វៀរនូវគ្រឿងអាងដទៃ ឬវៀរតែមានពិត ក៏ពោលអួតនូវធម៌ផ្សេងដោយប្រភេទមានឈានជាដើម ដែលមិនមានក្នុងចិត្តចំពោះសត្វមានជាតិជាមនុស្ស កាលគេដឹងក្នុងខណៈនោះ ភិក្ខុនោះ រមែងជាអ្នកចាលចាញ់ចាកព្រះសាសនាពិត ព្រោះការពោលអួតនោះ ។

ពាក្យថា **ឈានាទិភេទំ** គឺ ឧត្តរិមនុស្សធម៌ ផ្សេងដោយប្រភេទមានឈានជាដើម ដែលព្រះដ៏មានព្រះភាគត្រាស់ទុកហើយយ៉ាងនេះថា[៧] **ឈាន**(គុណជាតសម្រាប់ដុតបង់នូវកិលេស) ១ **វិមោក្ខ** (គុណធម៌ដែលផុតស្រឡះចាករាគៈជាដើម) ១ **សមាធិ**

---

[៦] វិ. មហាវិ. ភាគ ១ ទំព័រ ២៨៥ ដល់ចប់

[៧] វិ. មហាវិ. ភាគ ១ ទំព័រ ៣០០

(សភាពដែលដំកល់ចិត្តស្មើមាំល្អក្នុងអារម្មណ៍) ១ **សមាបត្តិ** (គុណជាតដែលដល់ព្រម) ១ **ញាណទស្សនៈ** (កិរិយាឃើញដោយបញ្ញា) ១ **មគ្គភាវនា** (កិរិយាចម្រើននូវមគ្គ) ១ **ផលសច្ឆិកិរិយា** (ដំណើរធ្វើឱ្យច្បាស់លាស់នូវផល) ១ **កិលេសប្បហាន** (កិរិយាលះបង់កិលេស) ១ **វិនីវរណតា ចិត្តស្ស** ភាពនៃចិត្តប្រាសចាកនីវរណធម៌ ១ **សុញ្ញាគារេ អភិរតិ** សេចក្តីត្រេកអរក្នុងផ្ទះដ៏ស្ងាត់ ១ ។ បទថា **ហទយេ** គឺ ក្នុងចិត្ត ។ ពាក្យថា **អសន្តំ** គឺមិនមានព្រម ។ ពាក្យថា **អញ្ញាបទេសំ** សេចក្តីថា រៀរគ្រឿងអាងដទៃ ដោយន័យជាដើមថា ភិក្ខុណា គង់នៅក្នុងវិហាររបស់អ្នក ភិក្ខុនោះ បានបឋមឈាន ។ សព្ទថា **វិនា** ជានិបាតចុះក្នុងអត្ថថា រៀរ សេចក្តីថា រៀរហើយនូវគ្រឿងអាងនោះ ។ ពាក្យថា **អធិមានំ** សេចក្តីថា មានធម៌ដែលកើតឡើងហើយយ៉ាងនេះថា អាត្មាអញបានត្រាស់ដឹងហើយ ។ វិគ្គហៈថា ៖ **អធិគតោ មានោ** បានត្រាស់ដឹងហើយ សេចក្តីថា រៀរហើយនូវការត្រាស់ដឹងនោះ ។

ពាក្យថា **មនុស្សជាតិស្ស** គឺ ប្រកបដោយជាតិជាមនុស្ស ។ អធិប្បាយថា មិនមែនជាអ្នកណាម្នាក់ ក្នុងបណ្តាសត្វមានទេវតា និងព្រហ្មជាដើម ។ ពាក្យថា **វទេយ្យ** ពោលអួត គឺ

អ្នួតប្រាប់ ។ បទថា **ញាតក្ខណោ** កាត់បទជា **ញាតេ + ខណោ** សេចក្ដីថា កាលសត្វមានជាតិជាមនុស្សដឹងក្នុងខណៈដែលភិក្ខុនោះប្រាប់ហើយនោះ ។ បទថា **តេន** ជាតតិយាវិភត្តិ ចុះក្នុងអត្ថបញ្ចមីវិភត្តិ ។ សេចក្ដីថា ចាលចាញ់ចាកព្រះសាសនានោះ ។

## ចតុត្ថបារាជិកសិក្ខាបទ ចប់

## ចប់ បារាជិកនិទ្ទេសវណ្ណនា

# ២. គរុកាបត្តិនិទ្ទេសវណ្ណនា

## សុក្កវិស្សដ្ឋិសិក្ខាបទ[៨]

១០. ឥឡូវនេះ ដើម្បីប្រកាសនូវអាបត្តិសង្ឃាទិសេស លោកអាចារ្យទើបប្រារព្ធពាក្យជាដើមថា **មោចេតុកាមបិត្តេន** ដូច្នេះ ។

ក្នុងគាថានោះ មានបទវិគ្គហៈថា ចង់ដើម្បីបញ្ចេញ ព្រោះដូច្នោះ ទើបឈ្មោះថា **មោចេតុកាមំ** ។ ចង់បញ្ចេញផង ចិត្តនោះផង ដូច្នោះ ឈ្មោះថា **មោចេតុកាមបិត្តំ** សេចក្ដីថា មានចិត្តត្រេកអរនឹងការបញ្ចេញនោះ ។ ពិតមែន អាបត្តិរមែងមាន ដោយសេចក្ដីត្រេកអរនឹងការបញ្ចេញណាមួយ បណ្ដាសេចក្ដីត្រេកអរទាំង ១១ ប្រការ ។

ក្នុងអធិការនោះ នេះជាសេចក្ដីត្រេកអរទាំង ១១ ប្រការគឺ ៖

១. មោចនស្សាទោ ត្រេកអរនឹងកិរិយាបញ្ចេញទឹកអសុចិ

២. មុច្ចនស្សាទោ ត្រេកអរនឹងការដែលអសុចិកំពុងចេញ

៣. មុត្តស្សាទោ ត្រេកអរនឹងការដែលអសុចិចេញហើយ

---

[៨] វិ. មហាវិ. ភាគ ២ ទំព័រ ១

៤. មេថុនស្សាទោ ត្រេកអរនឹងមេថុន
៥. ផស្សស្សាទោ ត្រេកអរនឹងសម្ផស្ស
៦. កណ្ឌូវនស្សាទោ ត្រេកអរនឹងការអេះ
៧. ទស្សនស្សាទោ ត្រេកអរនឹងការមើល
៨. និសជ្ជស្សាទោ ត្រេកអរនឹងការអង្គុយ
៩. វាចស្សាទោ ត្រេកអរនឹងការនិយាយ
១០. គេហសិតបេមំ ស្រឡាញ់អាស្រ័យផ្ទះ
១១. វនភង្គិយំ ការកាច់ឈើក្នុងព្រៃ ។

បណ្ដាសេចក្ដីត្រេកអរទាំងនោះ ភិក្ខុកាលឱ្យចេញ ឬត្រេកអរដោយចេតនាត្រេកអរក្នុងការបញ្ចេញ ព្យាយាមចេញមក ត្រូវអាបត្តិសង្ឃាទិសេស បើមិនចេញ ត្រូវអាបត្តិថុល្លច្ច័យ ក៏បើក្នុងកាលជាទីដេកភិក្ខុមានរាគៈគ្របសង្កត់ហើយ ក៏ត្បៀតឬក្ដាប់អង្គជាតយ៉ាងមាំដោយភ្លៅ ឬដោយកណ្ដាប់ដៃ ជាអ្នកមានឧស្សាហ៍ដើម្បីឱ្យចេញហើយដេកលក់ទៅ ក៏កាលភិក្ខុនោះដេកលក់ទៅហើយ ទឹកអសុចិតែងឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។

ក្នុងសេចក្ដីត្រេកអរនឹងអសុចិកំពុងចេញគប្បីជ្រាបដូច្នេះ៖ អសុចិកាលចេញតាមធម្មតារបស់ខ្លួន ភិក្ខុតែងត្រេកអរ តែមិនព្យាយាមមិនជាអាបត្តិ ។

ក្នុងសេចក្តីត្រេកអរនឹងកាលដែលអសុចិចេញហើយៈ ទឹកអសុចិចេញហើយ ផុតចាកឋានហើយតាមធម្មតារបស់ខ្លួន ភិក្ខុត្រេកអរពេលក្រោយវៀរសេចក្តីព្យាយាម មិនជាអាបត្តិ ។

ក្នុងសេចក្តីត្រេកអរនឹងមេថុនៈ ភិក្ខុចាប់មាតុគ្រាម ដោយតម្រេកក្នុងមេថុន ពេលនោះ អសុចិតែងឃ្លាតចេញ មិនជាអាបត្តិ (សង្ឃាទិសេស) តែត្រូវអាបត្តិទុក្កដ ។

សេចក្តីត្រេកអរនឹងសម្ផស្សមាន ២ យ៉ាងគឺ សម្ផស្ស ខាងក្នុង ១ ខាងក្រៅ ១ ។ បណ្តាសម្ផស្សទាំង ២ យ៉ាងនោះ ភិក្ខុកាលលេងនូវនិមិត្ត(អង្គជាត)របស់ខ្លួនដោយបំណងថា អញ នឹងដឹងថា រឹងឬទន់ក្តី កាលឱ្យគេលេងដោយភាពជាអ្នកឡេះ ឡោះក្តី អសុចិចេញ មិនជាអាបត្តិ ។ តែក្នុងសេចក្តីត្រេកអរនឹង សម្ផស្សខាងក្រៅ ភិក្ខុកាលចាប់ពាល់ត្រូវស្ត្រី ដោយតម្រេកក្នុង ការស្ទាបអង្អែលកាយ ក៏ពេលចាប់ទាញមកអសុចិចេញ មិនជា សុក្កវិស្សដ្ឋិសង្ឃាទិសេស តែត្រូវកាយសំសគ្គសង្ឃាទិសេស ។

ក្នុងសេចក្តីត្រេកអរនឹងការអេះៈ ភិក្ខុអេះនិមិត្តដែល កំពុងរមាស់ដោយបណ្តាការបៀតបៀនមានរោគឃ្លង់ រមាស់ និងសត្វល្អិតបៀតបៀនជាដើមណាមួយ ដោយសេចក្តីត្រេកអរ ក្នុងការអេះ អសុចិចេញ មិនត្រូវអាបត្តិ ។

ក្នុងសេចក្តីត្រេកអរនឹងការមើលៈ

ភិក្ខុកាលសំឡឹងមើលទីមិនមែនជាឱកាស (អង្គជាត)របស់ស្ត្រី អសុចិចេញមក មិនត្រូវសង្ឃាទិសេសទេ តែត្រូវអាបត្តិទុក្កដ ។

ក្នុងសេចក្ដីត្រេកអរនឹងការអង្គុយៈ ភិក្ខុកាលអង្គុយក្នុងទីស្ងាត់ជាមួយមាតុគ្រាម សូម្បីអសុចិឃ្លាតចេញ មិនត្រូវអាបត្តិសង្ឃាទិសេស តែត្រូវរហោនិសជ្ជាបត្តិ (អាបត្តិបាចិត្តិយ)។

ក្នុងសេចក្ដីត្រេកអរនឹងការនិយាយៈ ភិក្ខុកាលសាសងនឹងមាតុគ្រាមដោយវាចា ដែលប្រកបដោយមេថុន សូម្បីអសុចិចេញមក ក៏មិនជាអាបត្តិសុក្កវិស្សដ្ឋិសង្ឃាទិសេស តែត្រូវទុដ្ឋុល្លវាចាសង្ឃាទិសេស ។

ក្នុងសេចក្ដីស្រឡាញ់អាស្រ័យផ្ទះៈ ភិក្ខុកាលធ្វើកិច្ចឃាត់ចាប់ទាញជាដើម ដោយសេចក្ដីស្រឡាញ់បុគ្គលមានមាតាជាដើមថា មាតាជាដើមមែន សូម្បីអសុចិចេញមក មិនជាអាបត្តិ។ ភិក្ខុកាលស្ទាបអង្អែលនូវបណ្ណាការដែលមានឈ្មោះនៃការកាច់ឈើព្រៃមានផ្កាជាដើម ដែលគេបញ្ជូនទៅស្ត្រីដើម្បីធ្វើសន្ថវៈសេចក្ដីត្រេកអរថា ផ្កាបណ្ណាការនេះ គឺគេបញ្ជូនទៅស្ត្រីឈ្មោះនេះ សូម្បីអសុចិចេញមក មិនជាអាបត្តិ នេះឈ្មោះថា ការកាច់ឈើក្នុងព្រៃ ។ ដើម្បីសម្ដែងថា អាបត្តិមានដោយសេចក្ដីត្រេកអរនឹងការបញ្ចេញក្នុងសេចក្ដីត្រេកអរទាំង ១១ យ៉ាងនុ៎ះយ៉ាងនេះ ទើបពោលពាក្យថា **មោចេតុកាមចិត្តេន** ដូច្នេះ ។ ម្យ៉ាងទៀត ចិត្តចង់បញ្ចេញឯណា របស់ភិក្ខុណា ភិក្ខុនោះ

ឈ្មោះថា **មោចេតុកាមចិត្តោ** ភិក្ខុមានចិត្តចង់បញ្ចេញ, ពាក្យ **មោចេតុកាមចិត្តេន** នោះ ជាតតិយាវិភត្តិ ចុះក្នុងអត្ថឥត្ថម្ភូត, ដែលមានរូបន័យថា **មោចេតុកាមចិត្តោ** ជាអ្នកមានចិត្តចង់បញ្ចេញ ។

ពាក្យថា **ឧបក្កម្ម** សេចក្តីថា ព្យាយាមហើយត្រង់និមិត្ត ដោយអវយវៈណាមួយ មានដៃជាដើម ។

ពាក្យថា **វិមោចយំ** សេចក្តីថា កាលបញ្ចេញទឹកសុក្កៈណា ដោយហោចទៅសូម្បីមានប្រមាណប៉ុនដែលសត្វរុយតូចមួយផឹកបាន ។ ពាក្យថា **សុក្កំ** គឺ ទឹកសុក្កៈណាមួយ បណ្តាសុក្កៈមាន ១០ យ៉ាង ពោលគឺទឹកសុក្កៈពណ៌ខៀវ លឿង ក្រហម ស ពណ៌ដូចទឹកដោះគោមានពពុះ ប្រេង ទឹក ទឹកដោះស្រស់ ទឹកដោះជូរ ទឹកដោះថ្លា។ ពីរបទថា **អញ្ញត្រ សុបិនា** វៀរលែងតែយល់សប្តិ សេចក្តីថា សុក្កវិស្សដ្ឋិណាមានក្នុងសុបិន, វៀរទុកតែសុក្កវិស្សដ្ឋិនោះ ។ បុគ្គលណាមួយ ដែលបានឧបសម្បទាហើយ ឈ្មោះថា **សមណោ** ។ អាបត្តិសង្ឃាទិសេស ឈ្មោះថា **គរុកំ** ។ ពាក្យថា **ផុសេ** ប្រែថា ត្រូវ ។

ក្នុងសិក្ខាបទនេះ មានអង្គ ៣ នេះគឺ ៖

១. **ចេតនា** មានចេតនា

២. **ឧបក្កមោ** ព្យាយាម

៣. **មុច្ចនំ** អសុចិចេញ ដូច្នេះឯង ។

# សុក្កវិស្សដ្ឋិសិក្ខាបទទី ១ ចប់

## កាយសំសគ្គសិក្ខាបទ[១]

១១. ឥឡូវនេះ ដើម្បីសម្ដែងកាយសំសគ្គសិក្ខាបទ លោកអាចារ្យទើបប្រារព្ធពាក្យជាដើមថា **កាយសំសគ្គរាគេន** ។ គប្បីយោជនាដូច្នេះថា ៖

ភិក្ខុ មនុស្សិត្ថិយា មនុស្សិត្ថិសញ្ញី ហុត្វា កាយសំសគ្គ-រាគេន ឧបក្កមិត្វា មនុស្សិត្ថិំ បរាមសន្តោ សង្ឃាទិសេសំ អាបជ្ជេយ្យ ភិក្ខុមានសេចក្ដីសំគាល់មនុស្សស្រីថា ជាមនុស្សស្រី ហើយព្យាយាមប៉ះពាល់មនុស្សស្រី ដោយតម្រេកក្នុងការស្ទាបអង្អែលកាយ ត្រូវអាបត្តិសង្ឃាទិសេស ។

ក្នុងគាថានេះ ពាក្យថា **កាយសំសគ្គរាគេន** សេចក្ដីថា ត្រេកអរហើយដោយសម្ផស្សកាយមានការចាប់ដៃជាដើម គឺថា តម្រេកលាយឡំដោយកាយ ។

ពាក្យថា **មនុស្សិត្ថិំ** បានដល់ មនុស្សស្រីដែលនៅរស់ សូម្បីតែកើតហើយក្នុងថ្ងៃនោះ ។ បទថា **បរាមសំ** ប្រែថា

---

[១] វិ. មហាវិ. ភាគ ២ ទំព័រ ៥៣

កាលប៉ះពាល់, សេចក្តីសម្គាល់ថា ស្រី ឈ្មោះថា **ឥត្ថិសញ្ញា**, **ឥត្ថិសញ្ញា**នោះ មានដល់ភិក្ខុនោះ ដូច្នោះ ទើបឈ្មោះថា **ឥត្ថិសញ្ញី** សេចក្តីថា ជាអ្នកមានសេចក្តីសំគាល់ថា ស្រី ។

ក្នុងសិក្ខាបទនេះ មានអង្គ ៥ នេះគឺៈ

១. **មនុស្សិត្ថី** មនុស្សស្រី

២. **ឥត្ថិសញ្ញិតា** ភិក្ខុមានសេចក្តីសំគាល់ថា ស្រី

៣. **កាយសំសគ្គរាគោ** ត្រេកអរក្នុងការស្ទាបអង្អែលកាយ

៤. **តេន រាគេន វាយាមោ** ព្យាយាមដោយតម្រេកនោះ

៥. **ហត្ថគ្គាហាទិសមាបជ្ជនំ** ដល់ព្រមដោយកម្មមានចាប់ដៃជាដើម ។

## កាយសំសគ្គសិក្ខាបទទី ២ ចប់

## ទុដ្ឋុល្លវាចស្សាទសិក្ខាបទ [១០]

១២. ឥឡូវនេះ ដើម្បីសម្តែងទុដ្ឋុល្លវាចាសិក្ខាបទ លោកអាចារ្យទើបប្រារព្ធពាក្យថា **ទុដ្ឋុល្លវាចស្សាទេន** ជាដើម ។ ក្នុងគាថានោះ មានសម្តែងបំភ្លឺដូច្នេះៈ

ពាក្យថា **ទុដ្ឋុល្លវាចស្សាទេន** តម្រេកក្នុងការពោល

[១០] វិ. មហាវិ. ភាគ ២ ទំព័រ ៨៦

ពាក្យអាក្រក់ គឺ តម្រេក និងសេចក្ដីត្រេកអរដោយវាចា ដែលសំដៅចំពោះវច្ចមគ្គ បស្សាវមគ្គ និងមេថុនធម្ម ។ ច្រើនពាក្យថា **មគ្គំ វារព្ភ មេថុនំ** សេចក្ដីថា ប្រារព្ធនូវមគ្គណាមួយ បណ្ដាវច្ចមគ្គ និងបស្សាវមគ្គ ឬមេថុន ។ បទថា **ឱភាសន្តោ** ប្រែថា ពោលបង្កាប់។ ពាក្យថា **មនុស្សិត្ថី** គឺ មនុស្សស្រីដឹងក្ដី ឈ្លាសប្រតិពលស្គាល់ពាក្យជាសុភាសិត និងទុព្ភាសិត ស្គាល់ពាក្យល្អ និងពាក្យអាក្រក់ ជាអ្នកមានលក្ខណៈអង់អាច ។ បទថា **សុណមានំ** ប្រែថា គួរស្ដាប់បាន ។ ភិក្ខុកាលប្រាប់ដល់ស្រីសូម្បីដែលឈ្លាសប្រតិពលនេះ ដែលឈរនៅត្រង់ថ្នល់ មិនចេញស្ដី ដោយទូត ឬដោយសំបុត្រ រមែងមិនត្រូវទុដ្ឋុល្លវាចាបត្តិទេ ។

ក្នុងសិក្ខាបទនេះ មានអង្គ ៥ នេះគឺៈ

១. **មនុស្សិត្ថី** មនុស្សស្រី

២. **ឥត្ថិសញ្ញិតា** ភិក្ខុមានសេចក្ដីសម្គាល់ជាស្រី

៣. **ទុដ្ឋុល្លវាចស្សាទរាគោ** មានតម្រេកត្រេកអរក្នុងការពោលពាក្យអាក្រក់

៤. **តេន រាគេន ឱភាសនំ** ពោលបង្កាប់ដោយតម្រេកនោះ

៥. **តង្ខណវិជាននំ** ស្រីដឹងសេចក្ដីក្នុងខណៈនោះ ។

## ទុដ្ឋុល្លវាចស្សាទសិក្ខាបទទី ៣ ចប់

## អត្តកាមបារិចរិយសិក្ខាបទ [១១]

១៣. ឥឡូវនេះ ដើម្បីសម្តែងអត្តកាមបារិចរិយសិក្ខាបទ លោកអាចារ្យពោលពាក្យជាដើមថា **វណ្ណំ** ។ ក្នុងគាថានេះ គប្បីជ្រាបសម្ពន្ធដូច្នេះ៖

យោ ភិក្ខុ អត្តនោ កាមបារិចរិយាយ វណ្ណំ វត្វា មេថុនរាគេន ឥត្ថឹ មេថុនំ យាចមានោ គរុំ ផុសេ ភិក្ខុពោលសរសើរគុណនៃការបម្រើខ្លួនដោយកាម ហើយសុំមេថុនធម្មនឹងស្ត្រី ដោយតម្រេកក្នុងមេថុន ត្រូវអាបត្តិសង្ឃាទិសេស ។

ពីរបទថា **វណ្ណំ វត្វា** បានដល់ ការប្រកាសគុណ គឺអានិសង្ស។ ពាក្យថា **អត្តនោកាមបារិចរិយាយ** សេចក្តីថា កិរិយាបម្រើខ្លួនដោយកាម ពោលគឺ មេថុនធម្ម ឈ្មោះថា **កាមបារិចរិយា** ការបម្រើដោយកាមដើម្បីប្រយោជន៍ដល់ខ្លួនឯង ឈ្មោះថា **អត្តកាមបារិចរិយា**, សព្ទនេះ ជាអលុត្តសមាស ។ ម្យ៉ាងទៀត ពាក្យនេះ ជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថគឺសេចក្តីប្រាថ្នាថា **អត្តនោ** របស់ខ្លួន, សេចក្តីថា បំណង គឺសេចក្តីប្រាថ្នារបស់ខ្លួន ឈ្មោះថា **អត្តនោកាមា** សេចក្តីប្រាថ្នារបស់ខ្លួន បានដល់ សេចក្តីប្រាថ្នាដោយអំណាចតម្រេកក្នុងមេថុនដោយខ្លួនឯង, សេចក្តី

---

[១១] វិ. មហាវិ. ភាគ ២ ទំព័រ ១០៥

ប្រាថ្នារបស់ខ្លួនផង ការបម្រើនោះផង ព្រោះដូច្នោះ ទើបឈ្មោះថា **អត្តកាមបារិចរិយា** ដោយការបម្រើខ្លួនដោយកាមនោះ អធិប្បាយថា ភិក្ខុណា ពោលសរសើរគុណយ៉ាងនេះថា ម្នាលប្អូនស្រី ស្រីណា គប្បីបម្រើបុគ្គលអ្នកមានសីល មានកល្យាណធម៌ ប្រព្រឹត្តព្រហ្មចារី ប្រហែលដូចជាអាត្មានេះ ការបម្រើនុ៎ះរបស់ស្ត្រីនុ៎ះ ជាការបម្រើដ៏ប្រសើរ ។ បីបទថា **ឥត្ថឹ មេថុនំ យាចមានោ** សុំមេថុននឹងស្ត្រី គឺ លោកពោលហើយព្រោះ **យាច** ធាតុ ប្រព្រឹត្តទៅក្នុងកម្មពីរយ៉ាង ។ បណ្តាបទទាំងនោះ បទថា **ឥត្ថី** បានដល់ ស្រីមានប្រការដូចបានពោលហើយក្នុងទុដ្ឋុល្លោភាសនសិក្ខាបទ (ទុដ្ឋុល្លវាចស្សាទសិក្ខាបទ) ។

ក្នុងសិក្ខាបទនេះ មានអង្គ ៥ នេះគឺ ៖

១. **មនុស្សិត្ថី** មនុស្សស្រី

២. **ឥត្ថិសញ្ញិតា** ភិក្ខុមានសេចក្តីសម្គាល់ថាជាស្រី

៣. **អត្តកាមបារិចរិយាយ រាគោ** ត្រេកអរក្នុងការបម្រើខ្លួនដោយកាម ។ ៤. **តេន រាគេន វណ្ណភាសនំ** ពោលសរសើរគុណដោយតម្រេកនោះ

៥. **តង្ខណវិជាននំ** ស្រីដឹងសេចក្តីក្នុងខណៈនោះ ។

## អត្តកាមចារិចរិយសិក្ខាបទទី ៤ ចប់

## សញ្ចរិត្តសិក្ខាបទ[១២]

១៤. ឥឡូវនេះ ដើម្បីសម្តែងសញ្ចរិត្តសិក្ខាបទ លោកអាចារ្យប្រារព្ធនូវពាក្យថា **សន្ទេសំ** ដូច្នេះជាដើម ។ ក្នុងគាថានោះ គប្បីជ្រាបសម្ពន្ធ ដូច្នេះ ៖

ភិក្ខុ បុរិសស្ស វា សន្ទេសំ, ឥត្ថិយា វា សន្ទេសំ បដិគ្គហេត្វា វីមំសិត្វា បច្ចាហរន្តោ គរុកំ ផុសេ ភិក្ខុទទួលនូវពាក្យបណ្តាំរបស់បុរសក្តី ពាក្យបណ្តាំរបស់ស្ត្រីក្តី ហើយទៅល្បងមើល រួចត្រឡប់មកវិញ ត្រូវអាបត្តិសង្ឃាទិសេស ។

ក្នុងគាថានោះ ពាក្យថា **សន្ទេសំ** គឺ ដំណឹងរបស់បុរសដែលពោលពឹងពាក់ដូច្នេះថា គច្ឆ ភន្តេ ឥត្ថន្នាមំ មាតុរក្ខិតំ ព្រូហិ ហោហិ កិរ ឥត្ថន្នាមស្ស ភរិយា ធនក្កីតា បពិត្រលោកដ៏ចម្រើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះ ដែលមានមាតារក្សាដូច្នេះថា **គេថានាងឯង ចូរជាធនក្កីតាភរិយារបស់បុរសឈ្មោះនេះទៅ**[១៣] ។ ដំណឹងរបស់ស្ត្រីដែលពោលប្រាប់យ៉ាងនេះ ថា គច្ឆ ភន្តេ ឥត្ថន្នាមំ បុរិសំ ព្រូហិ អហំ តស្ស ភរិយា ភវិស្សាមិ **បពិត្រលោកដ៏ចម្រើន សូមលោកទៅប្រាប់បុរសឈ្មោះនេះថា**

[១២] វិ.មហាវិ.ភាគ ២ ទំព័រ ១២០

[១៣] វិ.មហាវិ.ភាគ ២ ទំព័រ ១៣៦

**ខ្ញុំនឹងជាភរិយារបស់គាត់** ។ ពាក្យថា **បដិគ្គណ្ហិត្វា** សេចក្ដីថា ភិក្ខុធ្វើវចីភេទដោយអាការណាមួយថា ល្អហើយឧបាសក ឬថា មិនអីទេ ឬថា អាត្មានឹងប្រាប់ឱ្យក្ដី, ទទួល គឺថា ព្រមទទួលដោយកាយកម្មមានងក់ក្បាលជាដើមក្ដី ។ ពាក្យថា **វីមំសិត្វា** សេចក្ដីថា ទទួលដំណឹងតាមការដែលពោលហើយ ហើយប្រាប់បុរសក្ដី ស្ត្រីក្ដី ប្រាប់ដល់បុគ្គលទាំងឡាយមានមាតាបិតា បងប្អូនប្រុស និងបងប្អូនស្រីជាដើម ដែលនឹងប្រាប់ដោយពិត ដល់អ្នកទាំងនោះក្ដី ។ គប្បីជ្រាបក្នុងពាក្យថា **ហរំបច្ចា** នេះដូច្នេះ សព្ទថា **ហរ** គឺ លោកធ្វើជាបុព្វនិបាត ពោលទុកហើយព្រោះខ្លាចអំពីការបាត់បង់ឆន្ទៈក្នុងពាក្យដែលគប្បីពោលថា **បច្ចាហរំ** គឺថា **ត្រឡប់មក** ដូច្នេះ ។ បុរសបញ្ជូនទៅក្នុងទីណា ភិក្ខុក៏ទៅក្នុងទីនោះ ហើយប្រាប់តាមពាក្យបុរសនោះ ស្រីនោះ ទទួលថា សាធុក្ដី ប្រកែកក្ដី នៅស្ងៀមព្រោះខ្មាសក្ដី ហើយត្រឡប់មកវិញ នាំដំណឹងទៅប្រាប់បុរសនោះ ដោយហេតុមានប្រមាណប៉ុណ្ណោះ ភិក្ខុនោះត្រូវអាបត្តិសង្ឃាទិសេស ព្រោះអង្គ ៣ យ៉ាង ពោលគឺ ទទួលពាក្យ ទៅប្រាប់ និងត្រឡប់មកប្រាប់វិញនេះ ។

ក្នុងសិក្ខាបទនេះមានអង្គ ៥ នេះគឺៈ

១. **តេសំ មនុស្សជាតិកតា** បុរស ឬស្ត្រីនោះមានជាតិជាមនុស្ស

២. **អលំវចនីយតា** ល្មមអាចស្ដាប់សំដីបានតាមធម្មតា

៣. **បដិគ្គណ្ហនំ** ទទួលពាក្យ
៤. **វីមំសនំ** ទៅល្បងមើល
៥. **បច្ចាហរណំ** ត្រឡប់មកប្រាប់វិញ ។

## សញ្ចរិត្តសិក្ខាបទទី ៥ ចប់

## អមូលកសិក្ខាបទ [១៩]

១៥. ឥឡូវនេះ ដើម្បីសម្តែងអមូលកសិក្ខាបទ លោកអាចារ្យប្រារព្ធពាក្យថា **ទុដ្ឋោ ទោសោ** ជាដើម ។ គប្បីជ្រាបសម្ពន្ធដូច្នេះ ៖

បាវេតុកាមោ ភិក្ខុ អមូលន្តិមវត្ថុនា អញ្ញំ សុណមានំ ភិក្ខុំ ចោទេន្តោ វា ចោទាបេន្តោ វា គរុំ ផុសេ ភិក្ខុមានបំណងចង់ឱ្យឃ្លាត ចោទដោយខ្លួនឯងក្តី ប្រើគេឱ្យចោទក្តី នូវភិក្ខុដទៃដែលកំពុងស្តាប់បានដោយអន្តិមវត្ថុមិនមានមូល ត្រូវអាបត្តិសង្ឃាទិសេស ។

វិនិច្ឆ័យក្នុងគាថានោះ គប្បីជ្រាបដូច្នេះ៖

ពាក្យថា **បាវេតុកាមោ** បានដល់ ចង់ឱ្យឃ្លាតចាកព្រហ្មចរិយ។ ពាក្យថា **ចោទេន្តោ** សេចក្តីថា ភិក្ខុកាលចោទដោយខ្លួនឯងដោយពាក្យទាំងឡាយមានពាក្យថា លោកឯងត្រូវអាបត្តិបារាជិក

[១៩] បឋមទុដ្ឋទោសសិក្ខាបទ វិ. មហាវិ. ភាគ ២ ទំព័រ ២៣៩

មិនមែនជាសមណៈ មិនមែនជាសក្យបុត្រជាដើម ។ ភិក្ខុកាល ចោទយ៉ាងនេះ ត្រូវអាបត្តិសង្ឃាទិសេស គ្រប់ ៗ វាចា ។ បទថា **អមូលន្តិមវត្ថុនា** សេចក្ដីថា បើអន្តិមវត្ថុណា ដែលភិក្ខុអ្នកចោទ មិនបានឃើញ មិនបានឮ មិនបានរង្កៀសចំពោះបុគ្គលដែលត្រូវ ចោទទេ មូលនេះ មិនមានដល់ភិក្ខុនោះ ដូច្នោះ ទើបឈ្មោះថា **អមូលំ** ព្រោះមិនមានមូល ពោលគឺការឃើញ ការឮ ការរង្កៀស ទាំងនេះ,វត្ថុដែលធ្វើនូវទីបំផុតនៃអាបត្តិបារាជិកណា បារាជិកនេះ នោះ ឈ្មោះ អន្តិមវត្ថុ, អមូលផង អន្តិមវត្ថុនោះផង ដូច្នោះ ទើបឈ្មោះថា អមូលន្តិមវត្ថុ, ដោយអន្តិមវត្ថុមិនមានមូលនោះ អធិប្បាយថា ដោយបណ្ដាអាបត្តិបារាជិក ១៩ ដ៏សមគួរ ដល់ភិក្ខុ អាបត្តិណាមួយ ។ ពាក្យថា **ចោទាបយំ** អធិប្បាយថា ភិក្ខុកាល បង្គាប់ភិក្ខុដទៃ ដែលឈរនៅជិតភិក្ខុនោះឱ្យចោទ ភិក្ខុអ្នក បង្គាប់ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ ៗ វាចា នៃភិក្ខុដែលត្រូវ បង្គាប់ហើយនោះ ។ ដោយបទថា **សុណមានំ** នេះ មានសម្ដែង បំភ្លឺដូច្នេះ ភិក្ខុកាលចោទក្នុងទីកំបាំងមុខដោយទូត ឬសំបុត្រ ការ ចោទនោះ រមែងមិនឡើងទេ ។ តែថា ភិក្ខុកាលពោលដោយកង នៃអាបត្តិទាំង ៧ ក្នុងទីកំបាំងមុខ ត្រូវអាបត្តិទុក្កដ ។

សិក្ខាបទនេះ មានអង្គ ៥ នេះគឺ ៖

១. យំ ចោទេតិ តស្ស ឧបសម្បន្នោតិ សង្ខ្យបគមនំ

ចោទបុគ្គលណា បុគ្គលនោះ ជាឧបសម្បន្ន

២. តស្មិំ សុទ្ធសញ្ញិតា សម្គាល់បុគ្គលនោះថា បរិសុទ្ធ

៣. យេន បារាជិកេន ចោទេតិ តស្ស ទិដ្ឋាទិវសេន អមូលកតា ចោទដោយអាបត្តិបារាជិកណា អាបត្តិបារាជិកនោះ មិនមានមូលដោយអំណាចមូលមានការឃើញជាដើម ។

៤. ចាវនាធិប្បាយេន សម្មុខា ចោទនា មានបំណងឱ្យឃ្លាត ចោទចំពោះមុខ ។

៥. តស្ស តង្ខណវិជាននំ ភិក្ខុដែលត្រូវចោទនោះ ដឹងសេចក្ដីក្នុងខណៈនោះ ។

## អមូលកសិក្ខាបទទី ៨ ចប់

## អញ្ញភាគិយសិក្ខាបទ[១៥]

១៦. ឥឡូវនេះ ដើម្បីសម្ដែងអញ្ញភាគិយសិក្ខាបទឡើង លោកអាចារ្យពោលពាក្យជាដើមថា **លេសមត្តំ** ដូច្នេះ ។

ក្នុងគាថានោះ មានអធិប្បាយថា៖

ពាក្យថា **លេសមត្តមុបាទាយ** គឺ ចូលទៅកាន់យកលេសបន្តិចបន្តួច សេចក្ដីថា បណ្ដាលេសទាំង ១០ ពោលដល់លេស គឺ ជាតិ នាម គោត្រ ភេទ អាបត្តិ បាត្រ ចីវរ ឧបជ្ឈាយ៍ អាចារ្យ

---

[១៥] ទុតិយទុដ្ឋទោសសិក្ខាបទ វិ. មហាវិ. ភាគ ២ ទំព័រ ២៧១

សេនាសនៈ លេសណាមួយ តែងប្រាកដក្នុងបុគ្គលនោះ ភិក្ខុមានប្រាថ្នាឱ្យឃ្លាតចាកព្រហ្មចរិយៈចូលទៅកាន់យក គឺអាស្រ័យលេសបន្តិចបន្តួចនោះហើយ ចោទភិក្ខុដែលកំពុងស្តាប់បានដោយអន្តិមវត្ថុដែលមិនមានមូល ត្រូវអាបត្តិសង្ឃាទិសេស។

សួរថា ការចោទដោយលេស គឺជាតិ តើដូចម្តេច ? អ្នកសិក្សាគប្បីជ្រាបសូម្បីលេសគឺនាមជាដើមយ៉ាងនេះ ៖

ភិក្ខុអ្នកចោទនេះ បានឃើញភិក្ខុដទៃ ដែលមានជាតិជាក្សត្រ ត្រូវអាបត្តិបារាជិក ចោទកភិក្ខុនោះ បានឃើញភិក្ខុមានជាតិជាក្សត្រដទៃទៀតដែលមានពៀរនឹងខ្លួន ក៏កាន់យកលេសគឺខត្តិយជាតិនោះ ហើយចោទយ៉ាងនេះថា ខ្ញុំឃើញភិក្ខុជាក្សត្រត្រូវអាបត្តិបារាជិក លោកឯងជាក្សត្រត្រូវអាបត្តិបារាជិកហើយ ឬចោទថា លោកឯងនោះជាក្សត្រ មិនមែនអ្នកដទៃទេ ត្រូវអាបត្តិបារាជិកហើយ ។

ក៏ក្នុងសិក្ខាបទនេះ អង្គទាំងឡាយប្រាកដស្មើដោយអង្គក្នុងសិក្ខាបទជាបន្ទាប់មក នោះឯង ។

## អញ្ញភាគិយសិក្ខាបទទី៩ ចប់

## ចប់ គរុកាបត្តិនិទ្ទេសវណ្ណនា[១៦]

[១៦] ក្នុងឧទ្ទេសនៃសង្ឃាទិសេស មានសិក្ខាបទចំនួន ១៣ តែក្នុងទីនេះ លោកអាចារ្យលើកយកតែ ៧ សិក្ខាបទប៉ុណ្ណោះឡើងកាន់និទ្ទេសនៃគរុកាបត្តិនេះ

ព្រោះសិក្ខាបទទាំង ៦ ដទៃទៀតនោះ ច្រើនជាប់ទាក់ទងហើយដោយអធិករណ៍ជាកម្មដែលសង្ឃគប្បីធ្វើអស់វារៈ៣ ដង ទើបប្រព្រឹត្តទៅជាទោស តែអំពើដែលភិក្ខុប្រព្រឹត្តខុសក្នុងសិក្ខាបទទាំងនោះ មានទៅតាមករិត ដូចសិក្ខាបទដទៃទៀតដែរ ។ អនាចារទាំងនោះ នឹងមានសម្តែងនៅក្នុងបកិណ្ណកនិទ្ទេសខាងមុខពិត ។

សិក្ខាបទសង្ឃាទិសេស ៦ ដែលសេសនោះគឺៈ

៦. កុដិការសិក្ខាបទ ភិក្ខុសូមហត្ថកម្មធ្វើកុដិសម្រាប់ខ្លួន មិនឱ្យសង្ឃសម្តែងទីឱ្យជាដើម ។ វិ. មហាវិ. ភាគ ២ ទំព័រ ១៧៩

៧. វិហារការសិក្ខាបទ ភិក្ខុធ្វើវិហារ ឬកុដិធំ វិ.មហាវិ.ភាគ ២ ទំ. ២២៣

១០. បឋមសង្ឃភេទសិក្ខាបទ ភិក្ខុបំបែកសង្ឃ វិ.មហាវិ.ភាគ ២ ទំ. ២៩១

១១. ទុតិយសង្ឃភេទសិក្ខាបទ ភិក្ខុប្រព្រឹត្តតាមភិក្ខុអ្នកបំបែកសង្ឃ ទំ.៣០៤

១២.ទុព្វចសិក្ខាបទ ភិក្ខុមានទិដ្ឋិលាមក ជាអ្នកប្រដៅបានដោយក្រ ទំ.៣១៣

១៣. កុលទូសកសិក្ខាបទ ភិក្ខុទ្រូស្តត្រកូលប្រកបដោយបាបធម៌ជាដើម។ វិ. មហាវិ. ភាគ ២ ទំព័រ ៣២២

ដទៃអំពីសង្ឃាទិសេសនោះទៅ ក៏នៅមានអនិយតសិក្ខាបទចំនួនពីរទៀត ដែលទាក់ទងដោយព្រះអរិយបុគ្គលជាសោតាបន្ន ចោទទោសដល់ភិក្ខុអ្នកប្រព្រឹត្តខុស ដោយការនៅទីស្ងាត់ និងនិយាយតែពីរនាក់ស្ត្រី ។ តែសិក្ខាបទទាំងពីរនេះ មិនប្រាកដនាបច្ចុប្បន្ននេះទេ ។

១. បឋមានិយតសិក្ខាបទទី ១ វិ.មហាវិ.ភាគ ២ ទំព័រ ៣៥០

២. ទុតិយានិយតសិក្ខាបទទី ២ វិ.មហាវិ.ភាគ ២ ទំព័រ ៣៦១

# ៣. និស្សគ្គិយនិទ្ទេសវណ្ណនា

## បឋមកឋិនសិក្ខាបទ

១៧. ឥឡូវនេះ ដើម្បីសម្តែងសិក្ខាបទក្នុងចីវរ លោកអាចារ្យលើកឡើងនូវពាក្យថា **វិកប្បនំ** ជាដើម ។ រួមសេចក្តីមកថា៖

យោ ភិក្ខុ អកាលចីវរំ វិកប្បនញ្ច អធិដ្ឋានញ្ច អកត្វា ទសាហំ អតិក្កាមេតិ, តស្ស ភិក្ខុនោ និស្សគ្គិយំ សិយា ភិក្ខុណា មិនធ្វើវិកប្ប ឬអធិដ្ឋាន ហើយញ៉ាំងអកាលចីវរឱ្យកន្លង ១០ ថ្ងៃទៅ ភិក្ខុនោះ ត្រូវនិស្សគ្គិយ(បាចិត្តិយ) ។

ក្នុងប្រយោគនោះ គប្បីជ្រាបដូច្នេះ ៖

ពាក្យថា **អកាលចីវរំ** គឺចីវរក្នុងកាលខុស បានដល់ ចីវរ៦ ប្រភេទ ពីកំណើត គឺ៖

១. ខោមំ សំបកឈើ

២. កប្បាសិកំ កប្បាស

៣. កោសេយ្យំ សូត្រ

៤. កម្ពលំ រោមសត្វ

៥. សាណំ សំបកធ្មៃ
និង ៦. ភង្គំ វត្ថុ ៥ លាយគ្នា,

ក៏សំពត់ចីវរទាំង ៦ ប្រភេទនេះ ដែលជាចីវរអនុលោម (ដល់ចីវរទាំង ៦ នោះ) គឺ ទុកូលំ សំពត់សំបកឈើ បត្តុណ្ណំ សំពត់រោមសត្វ សោមារបដ្ដំ សំពត់សោមារ បីឥបដ្ដំ សំពត់ប្រទេសចិន ឥទ្ធិជំ សំពត់កើតដោយឫទ្ធិ និង ទេវទិន្នំ សំពត់ដែលទេវតាថ្វាយឱ្យ ។ បណ្ដាសំពត់ទាំងនោះ សំពត់សំបកឈើអនុលោមចូលសំពត់សំបកធ្មៃ ព្រោះសម្រេចដោយក្រចៅ ។ សំពត់ទាំង ៣ មានសំពត់រោមសត្វជាដើម អនុលោមចូលសំពត់សូត្រ ព្រោះសម្រេចដោយអំបោះដែលគេធ្វើអំពីពួកសត្វល្អិតៗ សំពត់ពីរមានសំពត់សម្រេចដោយឫទ្ធិជាដើម អនុលោមចូលសំពត់ទាំង ៦ មានសំពត់សម្បកឈើជាដើម ព្រោះជាសំពត់ណាមួយ បណ្ដាសំពត់ទាំង ៦ នោះ ។ **អកាលចីវរ**ណាមួយបណ្ដាចីវរទាំង ៦ នេះ។

វិនិច្ឆ័យក្នុងពាក្យថា **វិកប្បនមធិដ្ឋានំ** នេះ គប្បីជ្រាបដូច្នេះ៖ ក៏អ្នកសិក្សាគប្បីជ្រាបចីវរដែលគួរដល់ការវិកប្ប

និងចីវរដែលគួរដល់ការអធិដ្ឋានយ៉ាងនេះ ។ នេះជាបាលីក្នុងសេចក្ដីនោះ អនុជានាមិ ភិក្ខវេ អាយាមេន អដ្ឋង្គុលំ សុគតង្គុលេន បតុរង្គុលវិត្ថតំ បច្ឆិមចីវរំ វិកប្បេតុំ [១៧] ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុវិកប្បចីវរយ៉ាងតូចបំផុត បណ្ដោយត្រឹម ៨ ធ្នាប់ ទទឹងត្រឹម ៤ ធ្នាប់ ដោយធ្នាប់ព្រះសុគត ។ គឺ បណ្ដោយ ២ ចំអាម ទទឹង ១ ចំអាម របស់មជ្ឈិមបុរស ។

**ការវិកប្ប**មានពីរយ៉ាងគឺ ការវិកប្បចំពោះមុខ ១ ការវិកប្បកំបាំងមុខ ១ ។ សួរថា (វិកប្បទាំងនោះ) តើដូចម្ដេច ?

ភិក្ខុគប្បីពោលពាក្យថា ឥមំ ចីវរំ តុយ្ហំ វិកប្បេមិ ខ្ញុំករុណាវិកប្បចីវរនេះដល់លោក, នេះឈ្មោះថា វិកប្បចំពោះមុខ

ភិក្ខុគប្បីពោលថា មយ្ហំ សន្តកំ បរិភុញ្ជ វា វិស្សជ្ជេហិ វា យថាបច្ចយំ វា ករោហីតិ ឯកស្ស សន្តិកេ ឥមំ ចីវរំ តិស្សស្ស ភិក្ខុនោ វិកប្បេមិ ខ្ញុំវិកប្បចីវរនេះ ចំពោះភិក្ខុតិស្សៈក្នុងសំណាក់បុគ្គលម្នាក់ថា លោកចូរប្រើប្រាស់ ចូរលះបង់ ចូរធ្វើឱ្យសមគួរដល់បច្ច័យនូវចីវរជារបស់ខ្ញុំ, នេះជាវិកប្បចំពោះមុខដទៃទៀត ។

---

[១៧] វិ. មហាវគ្គ ភាគ ៨ ទំព័រ ១៤៣

ភិក្ខុនោះគប្បីពោលថា តិស្សស្ស ភិក្ខុនោ សន្តកំ បរិភុញ្ជ វា វិស្សជ្ជេហិ វា យថាបច្ចយំ វា ករោហិ លោកចូរប្រើប្រាស់ក្តី ចូរលះបង់ក្តី ចូរធ្វើឱ្យសមគួរដល់បច្ច័យក្តី នូវចីវរជារបស់ភិក្ខុតិស្សៈចុះ ហើយពោលថា ឥមំ ចីវរំ តុយ្ហំ វិកប្បេតុំ ទម្មិ ខ្ញុំឱ្យចីវរនេះដល់លោកដើម្បីវិកប្ប, ភិក្ខុនោះគប្បីសួរភិក្ខុ(ក្រៅនេះ)ថា កោ តេ មិត្តោ វា សន្ទិដ្ឋោ វា សម្ភត្តោ វា អ្នកណាជាមិត្រ ឬមិត្រធ្លាប់ស្គាល់គ្នាម្តងម្កាល ឬមិត្ររួមរស់នៅជាមួយគ្នារបស់លោក ? ភិក្ខុដទៃក្រៅពីភិក្ខុនោះគប្បីពោលថា តិស្សោ ភិក្ខុ ភិក្ខុឈ្មោះតិស្សៈ ហើយគប្បីពោលទៀតថា អហំ តិស្សស្ស ភិក្ខុនោ ទម្មិ ខ្ញុំឱ្យដល់ភិក្ខុតិស្សៈ ដូច្នេះឈ្មោះថា វិកប្បកំបាំងមុខ ។

កាលពោលពាក្យថា តិស្សស្ស ភិក្ខុនោ សន្តកំ បរិភុញ្ជ វា វិស្សជ្ជេហិ វា យថាបច្ចយំ វា ករោហិ លោកចូរប្រើប្រាស់ក្តី ចូរលះបង់ក្តី ចូរធ្វើឱ្យសមគួរដល់បច្ច័យក្តី នូវចីវរជារបស់តិស្សភិក្ខុចុះ រមែងបានឈ្មោះថា ការដក ។

ចំពោះចីវរច្រើនត្រូវពោលថា ឥមានិ ចីវរទាំងឡាយនេះ មួយទៀត បើចីវរមិននៅក្នុងហត្ថបាសត្រូវពោលថា ឯតំ ចីវរនុ៎ះ

ឬថា ឯតានិ ចីវរទាំងឡាយនុ៎ះ (ក៏សេចក្ដីសំខាន់ក្នុងទីនេះ) គឺភិក្ខុមិនធ្វើហើយនូវវិកប្បយ៉ាងនោះ ។

ក៏ឯប្រមាណនៃត្រៃចីវរដែលតូចជាងចីវរព្រះសុគត ដោយកំណត់យ៉ាងឧក្រិដ្ឋ ទើបគួរ, សង្ឃាដិ (ប្រមាណនោះឯង) ដោយកំណត់យ៉ាងទាប, ចំពោះឧត្តរាសង្គៈ (ចីពរ) បណ្ដោយ ៥ ហត្ថក្ដាប់(៥គក់), ទទឹង ៣ ហត្ថក្ដាប់ (៣ គក់), អន្តរវាសកៈ (ស្បង់)បណ្ដោយ ៥ ហត្ថក្ដាប់ (៥ គក់), ទទឹង សូម្បី ២ ហត្ថ ឬ ២ ហត្ថកន្លះ ក៏គួរ ។ ត្រៃចីវរដែលលើស ឬខ្វះចាកប្រមាណដែលពោលហើយ គប្បីអធិដ្ឋានជាសំពត់បរិក្ខារ ។

គប្បីជ្រាប**ការអធិដ្ឋាន**ចីវរមានពីរយ៉ាង គឺ អធិដ្ឋានដោយកាយ ១ អធិដ្ឋានដោយវាចា ១ ។ ភិក្ខុកាលអធិដ្ឋានត្រៃចីវរត្រូវជ្រលក់ ឱ្យកប្បពិន្ទុ (យកវត្ថុមានពណ៌ខ្មៅជាដើម មកវង់ឱ្យជាគ្រឿងសំគាល់ចីវរ) ហើយដកសង្ឃាដិចាស់ថា ឥមំ សង្ឃាដឹ បច្ចុទ្ធរាមិ អាត្មាអញដកសង្ឃាដិនេះ! រួចយកដៃចាប់សង្ឃាដិថ្មីធ្វើអាភោគចិត្តថា ឥមំ សង្ឃាដឹ អធិដ្ឋាមិ អាត្មាអញអធិដ្ឋានសង្ឃាដិនេះ! កាលធ្វើដោយកាយវិការអធិដ្ឋានដោយកាយយ៉ាងនេះ ឈ្មោះថា ការអធិដ្ឋានដោយកាយ ។ ចំពោះការអធិដ្ឋានដោយកាយនេះ (បើ) ភិក្ខុមិនប៉ះពាល់ត្រៃចីវរនោះដោយសរីរាវយវៈណាមួយទេ មិនគួរឡើយ ។

បញ្ចេញវចីភេទចំពោះចីវរនោះ គប្បីពោលអធិដ្ឋាន ដោយវាចា, បើសង្ឃាដិនៅក្នុងហត្ថបាសត្រូវពោលថា ឥមំ សង្ឃាដឹ អធិដ្ឋាមិ អាត្មាអញអធិដ្ឋានសង្ឃាដិនេះ! ប្រសិនបើមិននៅក្នុងហត្ថបាសទេ គប្បីកំណត់កន្លែងដែលទុកដាក់ហើយ បញ្ចេញវាចាថា ឯតំ សង្ឃាដឹ អធិដ្ឋាមិ អាត្មាអញអធិដ្ឋានសង្ឃាដិនុ៎ះ!, ចំពោះឧត្តរាសង្គៈ និងអន្តរវាសកៈ ក៏ន័យនុ៎ះឯង ។ បរិក្ខារទាំងពួងមានត្រៃចីវរជាដើម ភិក្ខុសូមប្បីប្រមូលទុកក្នុងកន្លែងតែមួយ ហើយអធិដ្ឋានថា ឥមានិ ចីវរានិ បរិក្ខារចោឡានិ អធិដ្ឋាមិ អាត្មាអញអធិដ្ឋាននូវចីវរទាំងឡាយនេះ ឱ្យជាសំពត់បរិក្ខារ ដូច្នេះ ក៏គួរដែរ ។ ក៏សេចក្ដី(សំខាន់ទីនេះ) គឺ ភិក្ខុមិនធ្វើការអធិដ្ឋានយ៉ាងនោះទេ ។

ពាក្យថា **ទសាហំ** ប្រែថា ១០ ថ្ងៃ ។ ពាក្យថា **អតិមាបេតិ** គឺឱ្យកន្លងហួសទៅ ។ ពាក្យថា **តស្ស** គឺភិក្ខុនោះ ។ កិរិយាលះ គឺគួរលះ ឈ្មោះថា **និស្សគ្គិយ** ។ ពាក្យនេះ ជាឈ្មោះវិន័យកម្មដែលភិក្ខុត្រូវធ្វើក្នុងចំណែកខាងដើម, របស់គួរលះមានដល់ភិក្ខុនោះ ដូច្នោះ ភិក្ខុនោះ ទើបឈ្មោះថា **និស្សគ្គិយ** មានរបស់គួរតែលះចេញ ។

សួរថា និស្សគ្គិយនោះ ជាអាបត្តិអ្វី ?

ឆ្លើយថា និស្សគ្គិយនោះ ជាអាបត្តិបាចិត្តិយ

នេះជាសេចក្ដីសង្ខេបក្នុងពាក្យនុ៎ះ គឺ អាបត្តិបាចិត្តិយមួយអន្ទើដោយវិន័យកម្ម គឺការលះ គប្បីមាន ព្រោះទុកឱ្យកន្លងហួសកាលកំណត់នោះទៅ ។ ក៏ឯចីវរនេះនោះ កើតឡើងហើយក្នុងថ្ងៃណា អរុណរះណានៃចីវរនោះ អរុណនោះអាស្រ័យហើយនូវថ្ងៃដែលចីវរកើតឡើង, ព្រោះហេតុនោះ ចីវរត្រូវកន្លង ១០ ថ្ងៃ ក្នុងកាលអរុណថ្ងៃទី ១១ រះឡើង ។

ក្នុងសិក្ខាបទនេះ មានអង្គ ៥ នេះគឺ ៖

| | |
|---|---|
| ១. ចីវរស្ស អត្តនោ សន្តកតា | ចីវរជារបស់ខ្លួន |
| ២. ជាតិប្បមាណយុត្តតា | ចីវរត្រឹមត្រូវតាមជាតិ និងប្រមាណ |
| ៣. ឆិន្នបលិពោធភាវោ | ភិក្ខុមានបលិពោធដាច់ហើយ |
| ៤. អតិរេកចីវរតា | ជាអតិរេកចីវរ |
| ៥. ទសាហាតិក្កមោ | ទុកកន្លង ១០ ថ្ងៃ ។ |

## បឋមកឋិនសិក្ខាបទ ចប់

## ទុតិយកឋិនសិក្ខាបទ

១៨. ឥឡូវនេះ ដើម្បីសម្ដែងសិក្ខាបទទី ២ លោកអាចារ្យក៏ប្រារព្ធពាក្យជាដើមថា **ភិក្ខុសម្មតិយា** ដូច្នេះ ។

ត្រូវចេះសម្ពន្ធដូចនេះ ៖

យោ ភិក្ខុសម្មុតឹ វជ្ជេត្វា កាលញ្ច វិនា អធិដ្ឋិតំ តិចីវរំ ឯកាហំ អតិក្កមាបេតិ តស្ស និស្សគ្គិយំ សិយា ភិក្ខុណា វៀរទុកតែភិក្ខុដែលសង្ឃសន្មត ឬវៀរទុកតែមានកាលចេញ រួចញ៉ាំងត្រៃចីវរដែលបានអធិដ្ឋានហើយឱ្យកន្លងមួយថ្ងៃ ភិក្ខុនោះត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។

ក្នុងគាថានោះ ពាក្យថា **ភិក្ខុសម្មុតិយាញ្ញត្រ** សេចក្ដីថា សង្ឃតែងឱ្យសម្មតិ ដើម្បីនៅប្រាសចាកត្រៃចីវរណា ដល់ភិក្ខុឈឺ, វៀរលែងសម្មតិនោះចេញ ។ ពាក្យថា **តិចីវរមធិដ្ឋិតំ** ជាទុតិយាវិភត្តិចុះក្នុងអត្ថនៃតតិយាវិភត្តិ សេចក្ដីថា ភិក្ខុញ៉ាំងចីវរណាមួយ បណ្ដាចីវរមានសង្ឃាដិជាដើមដែលបានអធិដ្ឋានហើយ តាមន័យនៃការអធិដ្ឋានត្រៃចីវរនោះ ។ ពាក្យថា **ឯកាហំ** មួយថ្ងៃ គឺមួយយប់ ។ ពាក្យថា **អតិមាបេតិ** គឺនៅប្រាស សេចក្ដីថា មិនប្រកបចីវរនៅហើយ ។ អធិប្បាយថា ភិក្ខុដែលមិនបាន សម្មតិពីសង្ឃនោះ កាលនៅប្រាសចាកត្រៃចីវរ សូម្បីអស់មួយរាត្រី ត្រូវនិស្សគ្គិយបាចិត្តិយ ។ ពីរពាក្យថា **សមយំ វិនា** គឺវៀរទុកតែចីវរកាល ។

ក្នុងសិក្ខាបទនេះ មានអង្គ ៤ នេះគឺ ៖

| | |
|---|---|
| ១. អធិដ្ឋិតចីវរតា | ចីវរដែលបានអធិដ្ឋានហើយ |
| ២. អនត្ថតកឋិនតា | ភិក្ខុមិនបានក្រាលកឋិន |

៣. អលទ្ធសម្មុតិតា មិនបានសម្មតិ

៤. រត្តិវិប្បវាសោ នៅប្រាសចាករាត្រី ។

## ទុតិយកឋិនសិក្ខាបទ ចប់

## បុរាណចីវរសិក្ខាបទ

១៩. ឥឡូវនេះ ដើម្បីសម្តែងបុរាណចីវរសិក្ខាបទ លោកអាចារ្យក៏ប្រារព្ធពាក្យជាដើមថា **អញ្ញាតិកា** ។

មានសេចក្តីថា បណ្តាបទទាំងនោះ ពាក្យថា **អញ្ញាតិកា** បានដល់ ភិក្ខុនីមិនមែនជាញាតិ ដូចក្នុងប្រយោគទាំងឡាយមានប្រយោគថា បដិសង្ខា យោនិសោ គប្បីពិចារណាដោយឧបាយនៃប្រាជ្ញា ជាដើម អធិប្បាយថា ភិក្ខុនីមិនមែនជាញាតិ គឺមិនជាប់ទាក់ទងដោយការពាក់ព័ន្ធដោយមាតា (មាតុសម្ពន្ធ) ដោយការពាក់ព័ន្ធដោយបិតា (បិតុសម្ពន្ធ) ទាល់តែសោះ ។ ពាក្យថា **ភិក្ខុនិយា** គឺ ស្ត្រីដែលបានឧបសម្បទាដោយអដ្ឋវាចិកកម្ម ។ ពាក្យថា **អាកោដាបេតិ** គឺ ឱ្យបោកគក់ ។ ពាក្យថា **តំ** គឺ គប្បីជានិស្សគ្គិយបាចិត្តិយ ។

ក្នុងសិក្ខាបទនេះ មានអង្គ ៣ នេះគឺ ៖

១. បុរាណចីវរតា ជាចីវរចាស់

២. ឧបចារេ ឋត្វា អញ្ញាតិកាយ ភិក្ខុនិយា អាណាបនំ ឈរនៅក្នុងឧបចារៈ បង្គាប់ភិក្ខុនី មិនមែនជាញាតិ
៣. តស្សា ធោវនាទីនិ ភិក្ខុនីនោះធ្វើកិច្ចមានការលាងជាដើម។

## បុរាណចីវរសិក្ខាបទ ចប់

## ចីវរប្បដិគ្គហណសិក្ខាបទ

២០. ពីរបទថា **កិញ្ចិ មូលកំ** គឺនាំមកនូវវត្ថុអ្វីតិចតួចជាថ្នូរ។ ពាក្យថា **បីវរាទានេ** សេចក្តីថា កាន់យកនូវចីវរ គឺ ទទួលចីវរ ។

ក្នុងសិក្ខាបទនេះ មានអង្គ ៣ នេះគឺះ
១. វិកប្បនូបគបីវរតា ចីវរគួរដល់ការវិកប្ប
២. បារិវត្តកាភាវោ មិនមានអ្វីតិចតួចជាថ្នូរ
៣. អញ្ញាតិកាយ ហត្ថតោ គហណំ កាន់យកអំពីដៃនាងភិក្ខុនី មិនមែនជាញាតិ ។

## ចីវរប្បដិគ្គហណសិក្ខាបទ ចប់

## អញ្ញាតកវិញ្ញត្តិសិក្ខាបទ

២១. ពាក្យថា **អប្បវារិតំ** សេចក្តីថា សេចក្តីប្រាថ្នា ដែលគេប្រាថ្នាហើយ សេចក្តីគាប់ចិត្តដែលកើតឡើងហើយ ដោយពាក្យថា បពិត្រលោកដ៏ចម្រើន លោកម្ចាស់ត្រូវការ ដោយវត្ថុណា សូមលោកម្ចាស់ប្រាប់មកចុះ! គឺគេមិនបានលើក

ឱ្យទេ ដូចនោះ ទើបឈ្មោះថា គេមិនបានបវារណា ។ ពាក្យថា **វិញ្ញាបេន្តស្ស** ប្រែថា កាលសូម ។ ពាក្យថា **អញ្ញត្រ សមយា** គឺលើកទុកតែកាលដែលចីវរវិនាសបាត់ ។

ក្នុងសិក្ខាបទនេះ មានអង្គ ៤ នេះគឺ ៖

១. វិកប្បនូបគបចីវរតា ចីវរគួរដល់ការវិកប្ប

២. សមយាភាវោ មិនមានសម័យ

៣. អញ្ញាតកវិញ្ញត្តិ សូមជនមិនមែនជាញាតិ

៤. តាយ ច បដិលាភោ បានមកដោយការសូមនោះ ។

## អញ្ញាតកវិញ្ញត្តិសិក្ខាបទ ចប់

## រូបិយប្បដិគ្គហណសិក្ខាបទ

២២. ពាក្យថា **រជតំ** ប្រែថា ប្រាក់ ។ ពាក្យថា **ជាតរូបំ** ប្រែថា មាស ។ ពាក្យថា **មាសកំ** បានដល់ លោហមាសកៈ ទារុមាសកៈ និងជតុមាសកៈ ។ បណ្ដាមាសកៈទាំង ៣ យ៉ាងនោះ មាសកៈធ្វើដោយលោហធាតុមានស្ពាន់ជាដើម ឈ្មោះថា **លោហមាសកៈ** ។ មាសកៈដែលគេឆ្លាក់ធ្វើជារូបដោយឈើមានខ្លឹម ឬដោយបន្ទះឫស្សី ដោយហោចទៅសូម្បីដោយស្លឹកត្នោត ឈ្មោះថា **ទារុមាសកៈ** ។ មាសកៈដែលគេសូនធ្វើឱ្យជារូបឡើង ដោយអាចម៍ល័ក្ត ឬដោយជ័រឈើ ឈ្មោះថា ជតុមាសកៈ

កហាបណៈសម្រេចដោយមាសក្តី សម្រេចដោយប្រាក់ក្តី កហាបណៈប្រក្រតីធម្មតាក្តី ឈ្មោះថា **កហាបណៈ** ។ ពាក្យថា **គណ្ហេយ្យ** សេចក្តីថា ភិក្ខុឃើញទ្រព្យដែលគេឱ្យដើម្បីប្រយោជន៍ដល់ខ្លួនឯងក្តី ទ្រព្យដែលគ្មានគេរក្សា ស្ថិតនៅក្នុងទីណាមួយក្តី ហើយក៏កាន់យកដោយខ្លួនឯង ។ ពាក្យថា **គណ្ហាបេយ្យ** គឺ បង្គាប់អ្នកដទៃឱ្យកាន់យកទ្រព្យនោះឯង ។ ពាក្យថា **និស្សគ្គិ** សេចក្តីថា ភិក្ខុធ្វើកិច្ចណាមួយ បណ្តាកិច្ចមានទទួលខ្លួនឯងជាដើម ត្រូវនិស្សគ្គិយាបត្តិដោយរាប់វត្ថុ ក្នុងបង្វិចដែលចងទុកមិនតឹង គឺធូរៗ ។ ពាក្យថា **សាទិយេយ្យ វា** សេចក្តីថា ភិក្ខុមិនបានទទួលដោយកាយនិងវាចាទេ តែទទួលដោយចិត្ត ។

ក្នុងសិក្ខាបទនេះ មានអង្គ ៣ នេះគឺ ៖

១. ជាតរូបរជតភាវោ ទ្រព្យជាមាសនិងប្រាក់

២. អត្តុទ្ទេសិកតា ទ្រព្យនោះជាចំពោះខ្លួន

៣. គហណាទីសុ អញ្ញតរភាវោ បណ្តាកិច្ចមានទទួលខ្លួនឯងជាដើម កិច្ចណាមួយ ។

រូបិយប្បដិគ្គហណសិក្ខាបទ ចប់

# រូបិយបរិវត្តនសិក្ខាបទ

២៣. រជតាទិបតុព្ធិធំ អកប្បិយំ កប្បិយេនាបិ បរិវត្តេយ្យ សហធម្មិកេ ឋបេត្វា និស្សគ្គិយំ សិយា ភិក្ខុផ្លាស់ប្តូរនូវអកប្បិយវត្ថុ ៤ ប្រភេទ មានមាសជាដើម សូម្បីដោយកប្បិយវត្ថុក៏ដោយ ត្រូវនិស្សគ្គិយបាចិត្តិយ លើកលែងតែដូរ ជាមួយពួកសហធម្មិក ។

ក្នុងគាថានោះ ពាក្យថា **អកប្បិយំ** គឺ នូវវត្ថុជាអកប្បិយ។ ពាក្យថា **កប្បិយេន** គឺ ដោយវត្ថុជាកប្បិយ ។ ពាក្យថា **សហធម្មិកេ** បានដល់ ពួកសហធម្មិកទាំង ៥ ពោលគឺ ភិក្ខុ ភិក្ខុនី សាមណេរ សាមណេរី និងសិក្ខមានា ។

ក្នុងសិក្ខាបទនេះ មានអង្គ ២ នេះគឺ ៖

១. រូបិយភាវោ ជារូបិយវត្ថុ

២. បរិវត្តនំ ផ្លាស់ប្តូរគ្នា ។

*រូបិយបរិវត្តនសិក្ខាបទ ចប់*

# បឋមបត្តសិក្ខាបទ

២៤. គប្បីជ្រាបសេចក្តី(សំខាន់ក្នុងសិក្ខាបទនេះ)ថា៖ ភិក្ខុមិនបានធ្វើការវិកប្បដោយន័យមានន័យជាដើមថា ឥមំ បត្តំ តុយ្ហំ វិកប្បេមិ ខ្ញុំវិកប្បបាត្រនេះដល់លោក! និងមិនបានអធិដ្ឋាន

ដោយន័យមានន័យជាដើមថា ឥមំ បត្តំ អធិដ្ឋាមិ ខ្ញុំអធិដ្ឋានបាត្រនេះ! ដូច្នេះ ។

នេះជាសេចក្តីវិនិច្ឆ័យក្នុងពាក្យថា **បមាណិកំ** នេះ ៖

គប្បីយកអង្ករស្រូវសាលីចាស់ដែលមិនបាក់ គឺគេបុកបានស្អាតល្អចំនួន ២ នាឡិ មគធៈ ហើយយកទៅចម្អិនជាបាយមិនជាត់ទឹកស្អាតល្អ កុំឱ្យជ្រាយពេក កុំឱ្យស្រួយពេក ឱ្យដូចជាគំនរផ្កាម្លិះក្រពុំក្នុងឆ្នាំងដោយអង្ករនោះ ហើយដាក់ចុះក្នុងបាត្រទាំងអស់កុំឱ្យសល់ ហើយដាក់ថែមនូវសម្លសណ្តែកបាយដែលគេផ្សំដោយគ្រឿងផ្សំទាំងពួង មិនខាប់ពេកមិនរាវពេក ដែលជនអាចនាំទៅដោយដៃបាន ប្រមាណជាចំណែកទី ៤ នៃបាយនោះបន្ទាប់ពីនោះទៅ គប្បីដាក់ម្ហូបក្រៀមមានត្រីសាច់ជាដើម ឱ្យល្មមនឹងពំនូតបាយមុន រហូតដល់ល្មមសមគួរដល់ពំនូតបាយ ។ ចំណែកទឹកដោះថ្លា ប្រេង ទឹកដោះជូរ ទឹកដោះរាវ និងទឹកជ្រលក់ជាដើម មិនគួររាប់ ។ ពិនមែន ទឹកដោះថ្លាជាដើមនោះមានគតិដូចបាយនោះឯង មិនអាចដើម្បីបន្ថយចុះ ឬបន្ថែមឡើងទេ ។ សូម្បីរបស់ទាំងពួងនោះ ដែលគេដាក់ហើយយ៉ាងនោះ រមែងតាំងនៅស្មើស្នាមគំនូសខាងក្រោមកណ្តាប់មាត់បាត្រ និងពាល់ត្រូវខាងក្រោមនៃអំបោះ ឬចំណែកតូចៗដែលធ្លុះដោយអំបោះ ឬបំណែកតូចៗ បាត្រនេះ ឈ្មោះថា បាត្រខ្នាតធំ បើកន្លងស្នាមគំនូសនោះ ហើយកំពុងឡើងទៅ បាត្រនេះ ឈ្មោះថា

បាត្រខ្នាតធំយ៉ាងតូច ។ បើមិនដល់ស្នាមគំនូសនោះ ស្រកចុះនៅខាងក្នុងប៉ុណ្ណោះ បាត្រនេះ ឈ្មោះថា បាត្រខ្នាតធំយ៉ាងធំ ។ ប្រមាណពាក់កណ្ដាលបាត្រខ្នាតធំ ឈ្មោះថា បាត្រខ្នាតកណ្ដាល ប្រមាណពាក់កណ្ដាលបាត្រខ្នាតកណ្ដាល ឈ្មោះថា បាត្រខ្នាតតូច។ អ្នកសិក្សាគប្បីជ្រាបប្រភេទសូម្បីនៃបាត្រទាំងឡាយនោះ តាមន័យដែលពោលហើយនោះឯង ។ បណ្ដាបាត្រទាំង ៩ យ៉ាងនោះ បាត្រពីរគឺបាត្រខ្នាតធំយ៉ាងធំ ១ បាត្រខ្នាតតូចយ៉ាងតូច ១ មិនមែនជាបាត្រដោយប្រការដូច្នេះ ។ បាត្រប្រកបដោយប្រមាណយ៉ាងនេះគឺ បាត្រ ៧ ដ៏សេស ឈ្មោះថា ប្រកបដោយប្រមាណ តំ បមាណិកំ បាត្រដែលប្រកបដោយប្រមាណនោះ (ដែលលោកប្រាថ្នាយកក្នុងទីនេះ) ។ ពាក្យថា **បត្តំ** គឺ បាត្រទាំង ៧ ណាមួយ ។ សិក្ខាបទនេះ មានអង្គ ៥ នេះ គឺ ៖

១. បត្តស្ស អត្តនោ សន្តកតា បាត្រជារបស់ខ្លួន
២. បមាណយុត្តតា ជាបាត្រប្រកបដោយប្រមាណ
៣. អធិដ្ឋានូបគតា ជាបាត្រដែលគួរអធិដ្ឋាន
៤. អតិរេកបត្តតា ជាអតិរេកបាត្រ
៥. ទសាហាតិក្កមោ កន្លងហួស ១០ ថ្ងៃ ។

បឋមបត្តសិក្ខាបទ ចប់

# ឩនបញ្ចពន្ធនសិក្ខាបទ

២៥. គប្បីជ្រាបសម្ពន្ធដូច្នេះ ៖

យោ ភិក្ខុ បញ្ចពន្ធនេន ឩនបត្តេ សតិ បរំ បន នវំ បត្តំ វិញ្ញាបេតិ តស្សបិ ភិក្ខុនោ និស្សគ្គិយំ សិយា ភិក្ខុណា កាលនៅមានបាត្រខ្វះចំណាងប្រាំនៅឡើយស្រាប់តែសូមបាត្រថ្មីដទៃទៀត សូម្បីភិក្ខុនោះ ក៏ត្រូវនិស្សគ្គិយដែរ ។ ក្នុងប្រយោគនោះពាក្យថា **បរំ** ប្រែថា ដទៃ, ស្មើគ្នានឹងពាក្យថា **នវំ បត្តំ** បាត្រថ្មី ។

សិក្ខាបទនេះ មានអង្គ ៤ នេះគឺ ៖

១. អធិដ្ឋានុបគបត្តស្ស ឩនបញ្ចពន្ធនតា បាត្រមានចំណាង ៥ មិនទាន់គ្រប់

២. អត្តុទ្ទេសិកតា បាត្រចំពោះជារបស់ខ្លួន

៣. កតវិញ្ញត្តិ ចេញមាត់សុំ

៤. តាយ ច បដិលាភោ បានមកដោយការសុំនោះ ។

ឩនបញ្ចពន្ធនសិក្ខាបទ ចប់

# ភេសជ្ជវិធានសិក្ខាបទ

២៦. គប្បីជ្រាប(វិនិច្ឆ័យក្នុងភេសជ្ជវិធានសិក្ខាបទ)ដូច្នេះ ៖

យោ សប្បិតេលាទិកំ បន ភេសជ្ជំ បដិគ្គហេត្វា **សត្តាហបរមំ** សន្និធិការកំ ភុញ្ជេយ្យ សត្តាហំ អតិក្កាមេតិ តស្ស និស្សគ្គិយំ សិយា ភិក្ខុណាមួយ កាលទទួលភេសជ្ជៈមានទឹកដោះថ្លា និងប្រេងជាដើម ទុកឱ្យកន្លង ៧ ថ្ងៃទៅ ហើយបរិភោគភេសជ្ជៈជាសន្និធិការកៈ ភិក្ខុនោះ ត្រូវជានិស្សគ្គិយ ។

ក្នុងប្រយោគនោះ អ្នកសិក្សាគប្បីជ្រាបដូច្នេះ ៖ សព្ទថា **អាទិ** ក្នុងពាក្យថា **សប្បិតេលាទិកំ** លោកអាចារ្យតែងសង្គ្រោះយកទឹកដោះខាប់ ទឹកឃ្មុំ ស្ករអំពៅផងដែរ ។

ក្នុងភេសជ្ជៈ ៥ យ៉ាងនោះ អ្នកសិក្សាគប្បីស្គាល់ដូចនេះ៖ ទឹកដោះថ្លានៃសត្វម្រឹគទាំងឡាយមានគោជាដើម ឈ្មោះថា **សប្បិ**, សាច់នៃសត្វទាំងឡាយណាសមគួរ សប្បិ (ទឹកដោះថ្លា) នៃសត្វទាំងនោះ ក៏គួរដែរ, ចំពោះ**នវនីតំ** ទឹកដោះខាប់ក៏ដូចគ្នា។ ប្រេងដែលកើតអំពីគ្រាប់ស្ពៃ ស្រគំ ល្ហុងខ្វែរ និងខ្លាញ់ជាដើម ឈ្មោះថា **តេលំ** ។ ទឹកផ្អែមដែលកើតចេញពីមេឃ្មុំហ្នឹងឯង ឈ្មោះថា **មធុ** ។ ទឹកអាស្រ័យនៃដើមអំពៅ ឈ្មោះថា ទឹកអំពៅ, ក៏ឯរសដែលកើតអំពីដើមអំពៅ សូម្បីទាំងពួងដែលមិនបាន

រំងាស់ក្តី រំងាស់ប្រាសចាកវត្ថុ គឺកាកក្តី គប្បីជ្រាបថា **ផាណិតំ** ស្កររអំពៅ ។

## ភេសជ្ជវិធានសិក្ខាបទ ចប់

## អច្ឆិន្នសិក្ខាបទ

២៧. គប្បីជ្រាបយោជនាក្នុងសិក្ខាបទនេះ ដូចនេះ ៖

ភិក្ខុស្ស ចីវរំ ទត្វា បុន តំ ចីវរំ សកសញ្ញាយ អប្បិន្នន្តស្ស វា អប្បិន្នាបយតោបិ វា និស្សគ្គិយំ សិយា ភិក្ខុកាល ឱ្យចីវរដល់ភិក្ខុផងគ្នា ហើយដណ្តើមយកខ្លួនឯងក្តី ពុំនោះសោត ឱ្យគេដណ្តើមយកក្តី នូវចីវរនោះ ដោយសំគាល់ថា ជារបស់ខ្លួន ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។ ក្នុងប្រយោគនោះ បទថា **ទត្វា** គឺប្រាថ្នាតបនូវកិច្ចទាំងឡាយ មានការបំរើជាដើម ហើយឱ្យ ។ បទថា **អប្បិន្នន្តស្ស** សេចក្តីថា ភិក្ខុឃើញភិក្ខុនោះ កាលមិនធ្វើការបម្រើជាដើម ក៏កាន់យកដោយពលក្ការ ។ **អប្បិន្នាបយតោ** ចំពោះការប្រើគេឱ្យដណ្តើមយកក៏ដូចគ្នា ។

សិក្ខាបទនេះ មានអង្គ ៥ នេះគឺ ៖

១. វិកប្បនូបគចីវរតា ចីវរគួរដល់ការវិកប្ប

២. សាមំទិន្នតា ឱ្យដោយខ្លួនឯង

៣. សកសញ្ញិតា សំគាល់ថា ជារបស់ខ្លួន

៤. ឧបសម្បន្នតា អ្នកទទួលជាឧបសម្បន្ន
៥. កោធវសេន អប្បិន្ទនំ វា អប្បិន្ទាបនំ វា ដណ្តើមយកដោយខ្លួនឯងក្តី ឱ្យគេដណ្តើមយកក្តី ដោយអំណាចសេចក្តីក្រោធ ។

អច្ឆិន្ទនសិក្ខាបទ ចប់

## សុត្តវិញ្ញត្តិសិក្ខាបទ

២៨. គប្បីជ្រាបសេចក្តីបំព្រួញ(ក្នុងសិក្ខាបទនេះ)ដូច្នេះ៖

អប្បវារិតំ អញ្ញាតឹ គហបតឹ សុត្តំ យាចិត្វា ញាតិប្បវារិតេ វជ្ជេត្វា តន្តវាយេហិ ចីវរំ វាយាបេន្តស្ស និស្សគ្គិយំ សិយា ភិក្ខុកាលសុំ (អំបោះ) ចំពោះគហបតីដែលមិនបានបវារណា មិនមែនជាញាតិ វៀរលែងតែជនជាញាតិ និងអ្នកបវារណាចេញ ញ៉ាំងជាងតម្បាញឱ្យត្បាញចីវរ ជានិស្សគ្គិយ

ក្នុងប្រយោគនោះ ពាក្យថា **សុត្តំ** បានដល់ អំបោះ ៦ ប្រភេទ មានអំបោះសម្រេចដោយសំបកឈើជាដើម ឬអំបោះដែលអនុលោមចូលអំបោះ ៦ យ៉ាងនោះ ។ ពាក្យថា **យាចិយ** គឺសុំដើម្បីប្រយោជន៍ចីវរ ។

សិក្ខាបទនេះ មានអង្គ ៣ នេះគឺ៖
១. ចីវរត្ថាយ វិញ្ញាបិតសុត្តំ ភិក្ខុសុំអំបោះដើម្បីប្រយោជន៍ចីវរ
២. អត្តុទ្ទេសិកតា ចំពោះចីវរជារបស់ខ្លួន

៣. អកប្បិយតន្តុវាយេន អកប្បិយវិញ្ញត្តិយា វាយាបនំ ញ៉ាំង ជាងតម្បាញជាអកប្បិយ ឱ្យត្បាញអំបោះជាអកប្បិយវិញ្ញត្តិ ។

សុត្តវិញ្ញត្តិសិក្ខាបទ ចប់

## បរិណាមនសិក្ខាបទ

២៩. គប្បីជ្រាបសេចក្តីវិនិច្ឆ័យ(ក្នុងសិក្ខាបទនេះ)ដូច្នេះ៖

យោ ភិក្ខុ សង្ឃស្ស បរិណតំ លាភំ ជានន្តោ អត្តនោ បរិណាមេតិ តស្ស និស្សគ្គិយំ សិយា ភិក្ខុណា កាលដឹងលាភ ដែលគេបង្អោនទៅដើម្បីសង្ឃហើយ បង្អោនមកដើម្បីខ្លួនវិញ ភិក្ខុនោះ ត្រូវនិស្សគ្គិយបាចិត្តិយ ។

ក្នុងគាថានោះ ពាក្យថា **ជានំ** ប្រែថា កាលដឹង ។ ពាក្យថា **លាភំ** គឺ វត្ថុមានចីវរជាដើមដែលសង្ឃគប្បីបាន ។ ពាក្យថា **បរិណតំ** គឺ វត្ថុដែលគេបន្ទាបទៅដើម្បីព្រះសង្ឃ បន្ទន់ទៅដើម្បីសង្ឃ ទោរទៅដើម្បីសង្ឃ ហើយឈប់នៅ ។ ពាក្យថា **អត្តនោ បរិណាមេតិ** គឺ ភិក្ខុកាលពោលនូវពាក្យមាន ពាក្យជាដើមថា អ្នកទាំងឡាយ ចូរប្រគេនដល់អាត្មា ដូច្នេះជា ដើម ។ ឈ្មោះថា ធ្វើការបង្អោនមកដើម្បីខ្លួន ។

សិក្ខាបទនេះ មានអង្គ ៣ នេះគឺ ៖

១. សង្ឃេ បរិណតភាវោ គេបង្អោនទៅដើម្បីសង្ឃ

២. តំ ញត្វា អត្តនោ បរិណាមេតំ ដឹងសេចក្ដីនោះដែរ តែបង្អោនមកដើម្បីខ្លួន

៣. បដិលាភោ បានមក ។

## បរិណាមនសិក្ខាបទ ចប់

## ចប់ និស្សគ្គិយនិទ្ទេសវណ្ណនា[១៨]

[១៨] ក៏ក្នុងនិស្សគ្គិយបាចិត្តិយាបត្តិនេះ មានសិក្ខាបទចំនួន ៣០ គត់ តែងឡើងកាន់ឧទ្ទេស គឺព្រះភិក្ខុបាតិមោក្ខ មានក្នុងព្រះវិនយបិដកមហាវិភង្គ តតិយភាគ ៣ តែក្នុងនិស្សគ្គិយនិទ្ទេសនេះ លោកអាចារ្យលើកយកតែ ១៣ សិក្ខាបទ ប៉ុណ្ណោះមកអធិប្បាយ គឺ ៥ សិក្ខាបទ ក្នុងចីវរវគ្គ ២ សិក្ខាបទក្នុងកោសិយវគ្គ និង ៦ សិក្ខាបទក្នុងបត្តវគ្គ។ នេះ គឺសិក្ខាបទនិស្សគ្គិយទាំង ៣០, សិក្ខាបទដែលមានក្នុងទីនេះហើយ ខ្ញុំមិនពន្យល់ទេ ថែមទាំងកំម៉ៅអក្សរផងដែរ ៖

១. ចីវរវគ្គ

១. **បឋមកឋិនសិក្ខាបទ** វិ. មហាវិ.ភាគ ៣ ទំព័រ ១

២.**ឧទ្ទោសិតសិក្ខាបទ** (ទុតិយកឋិនសិក្ខាបទ) វិ.មហាវិ. ៣ ទំព័រទី ៩

៣. តតិយកឋិនសិក្ខាបទ សម្ដែងអំពីអកាលចីវរ គឺចីវរដែលកើតឡើងក្នុងឱកាស ១១ ខែ រាប់តាំងពីត្រឹមថ្ងៃ ១ រោច ខែកត្តិក ទៅដល់ថ្ងៃ ១៥ កើតខែអស្សុជ នេះជាអកាលចីវររបស់ភិក្ខុដែលឥតបានក្រាលកឋិន ។ ឯភិក្ខុដែលបានក្រាលកឋិន អកាលចីវរមានកំណត់ ៧ ខែ រាប់តាំងពីត្រឹមថ្ងៃ ១ រោច ខែផល្គុនទៅដល់ថ្ងៃ ១៥ កើតខែអស្សុជ ។ ក្នុងកំឡុងនេះ បើ មានចីវរកើត ដល់ភិក្ខុ ៗ គួរទទួលធ្វើចុះ តែកុំទុកឱ្យលើស ១ ខែឡើយ ។ វិ.មហាវិ.៣ ទំ.២៤

៤. **បុរាណចីវរសិក្ខាបទ** វិ.មហាវិ.ភាគ ៣ ទំព័រទី ៣២

**៥. ចីវរប្បដិគ្គហណសិក្ខាបទ** វិ.មហាវិ.ភាគ ៣ ទំព័រទី ៤០
**៦. អញ្ញាតកវិញ្ញត្តិសិក្ខាបទ** វិ.មហាវិ.ភាគ ៣ ទំព័រទី ៤៨
៧. តទុត្តរិសិក្ខាបទ បើគហបតីក្តី គហបតានីក្តី បវារណាប្រាថ្នាឱ្យភិក្ខុកាន់យកចីវរដ៏ច្រើន ភិក្ខុគួរត្រេកអរ ត្រឹមតែអន្តរវាសកៈ (ស្បង់) និង ឧត្តរាសង្គៈ (ចីពរ)ប៉ុណ្ណោះ មិនត្រូវត្រេកអរលើសកំណត់ឡើយ ។ វិ.មហាវិ. ៣ ទំព័រ ៥៩
៨. បឋមឧបក្ខដសិក្ខាបទ មានគេចង់ទិញចីវរប្រគេនភិក្ខុ តែមិនទាន់បានបវារណាទេ ភិក្ខុឮយ៉ាងនោះ ដោយមានចិត្តចង់បានចីវរល្អ ក៏ទៅបង្គាប់ថាល្អហើយញោមដែលញោមចង់ប្រគេនចីវរដល់អាត្មា ញោមចូរទិញចីវរបែបនេះៗ ដូចនេះ ។ វិ.មហាវិ.ភាគ ៣ ទំព័រទី ៦២
៩. ទុតិយឧបក្ខដសិក្ខាបទ ដូចសិក្ខាបទទី ៨ មុននេះដែរ តែសិក្ខាបទនេះមានម្ចាស់ទានពីរនាក់ ចង់ជាវចីវរប្រគេន លោកក៏ឱ្យគេចូលលុយគ្នាទិញទៅព្រោះចង់បានចីវរល្អ ។ វិ.មហាវិ.ភាគ ៣ ទំព័រទី ៧០
១០. រាជសិក្ខាបទ មានគេយកលុយមកបវារណាភិក្ខុសម្រាប់ទិញចីវរ ទុកដាក់ក្នុងដៃវេយ្យាវច្ចករ ភិក្ខុអាចតឹងទារឱ្យគេទិញចីវរបាន ៣ ដងយ៉ាងច្រើន បើមិនបានអាចទៅឈរស្ងៀមបាន ៦ ដងយ៉ាងច្រើន កុំឱ្យលើសពីនោះ ។ ឯកិច្ចដែលត្រូវធ្វើនោះ គឺ ភិក្ខុទៅប្រាប់ដោយខ្លួនឯង ឬឱ្យគេទៅប្រាប់ម្ចាស់លុយវិញ ។ វិ.មហាវិ.ភាគ ៣ ទំព័រ ៨០

## ២. កោសិយវគ្គ

១. កោសិយសិក្ខាបទ ភិក្ខុឱ្យគេធ្វើសន្ថត(សម្ពត់ទ្រាប់អង្គុយ) លាយដោយសូត្រ ។ វិ.មហាវិ.ភាគ ៣ ទំព័រ ៨៩
២. សុទ្ធកាឡកសិក្ខាបទ ភិក្ខុឱ្យគេធ្វើសន្ថតលាយដោយរោមចៀមខ្មៅសុទ្ធ ។ វិ.មហាវិ.ភាគ ៣ ទំព័រ ៩២

---

៣. ទ្វេភាគសិក្ខាបទ បើចង់ឱ្យគេធ្វើសន្ថ័តត្រូវធ្វើលាយពណ៌គឺ យករោមចៀមខ្មៅសុទ្ធ ២ ភាគ, ស ១ ភាគ និងក្រហម ១ ភាគ ។ វិ.មហាវិ.៣ ទំព័រ ៩៥
៤. ឆព្វស្សសិក្ខាបទ ភិក្ខុត្រូវប្រើសន្ថ័តថ្មីដែលឱ្យគេធ្វើរហូត ៦ ឆ្នាំ មិនត្រូវឱ្យគេធ្វើទៀតឡើយ លើកលែងតែភិក្ខុដែលបានសម្មតិអំពីសង្ឃ ។ វិ.មហាវិ.ភាគ ៣ ទំព័រ ១០០
៥. និសីទនសន្ថតសិក្ខាបទ បើភិក្ខុធ្វើសន្ថ័តសម្រាប់ទ្រាប់អង្គុយថ្មី ត្រូវយកសន្ថ័តចាស់ ១ ចំអាមព្រះសុគតមកផ្សំ បើមិនយកមកផ្សំទេ សន្ថ័តនោះជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ វិ.មហាវិ.ភាគ ៣ ទំព័រ ១១២
៦. ឯឡកលោមសិក្ខាបទ ភិក្ខុដើរផ្លូវឆ្ងាយ បើមានគេប្រគេនរោមចៀមទទួលយកដើរទៅទៀត បានត្រឹម ៣ យោជន៍យ៉ាងឆ្ងាយ បើចង់ទុកត្រូវឱ្យគេយកទៅប្រគេន ។ វិ.មហាវិ.ភាគ ៣ ទំព័រ ១១៧
៧. ឯឡកលោមធោវាបនសិក្ខាបទ ភិក្ខុប្រើនាងភិក្ខុនីឱ្យលាង ជ្រលក់សិត ឬត្រដោះរោមចៀម ។ វិ.មហាវិ.ភាគ ៣ ទំព័រ ១២២
៨. **រូបិយសិក្ខាបទ** វិ.មហាវិ.ភាគ ៣ ទំព័រ ១២៨
៩. **រូបិយសំវោហារសិក្ខាបទ (រូបិយប្បរិវត្តនសិក្ខាបទ)** វិ.មហាវិ.ភាគ ៣ ទំព័រ ១៣៤ ទិញដូរដោយប្រាក់
១០. កយវិក្កយសិក្ខាបទ ភិក្ខុទិញដូរដោយរបស់មានប្រការផ្សេង ៗ វិ.មហាវិ.ភាគ ៣ ទំព័រ ១៤១

### ៣. បត្តវគ្គ

១. **បឋមបត្តសិក្ខាបទ** វិ.មហាវិ.ភាគ ៣ ទំព័រ ១៤៥
២. **ឩនបញ្ចពន្ធនសិក្ខាបទ** វិ.មហាវិ.ភាគ ៣ ទំព័រ ១៥៣
៣. **ភេសជ្ជវិធានសិក្ខាបទ** វិ.មហាវិ.ភាគ ៣ ទំព័រ ១៦៧

---

៤. វស្សិកសាដិកសិក្ខាបទ ភិក្ខុត្រូវរកសំពត់វស្សិកសាដកសម្រាប់ងូតទឹកភ្លៀង ១ ខែខាងចុងគិម្ហរដូវ គឺពី ១ រោចខែជេស្ឋដល់ពេញបូណ៌មីខែអាសាឍ្ហ ហើយធ្វើឱ្យហើយក្នុងកន្លះខែខាងចុងគិម្ហរដូវ គឺរដូវក្តៅ រាប់ពីថ្ងៃ មួយកើតខែអាសាឍ្ហរហូតដល់ពេញបូណ៌មី ។ វិ.មហាវិ.ភាគ ៣ ទំព័រ ១៨០

៥. **ចីវរអច្ឆិន្ទនសិក្ខាបទ** វិ.មហាវិ.ភាគ ៣ ទំព័រ ១៨៥

៦. **សុត្តវិញ្ញត្តិសិក្ខាបទ** វិ.មហាវិ.ភាគ ៣ ទំព័រ ១៩០

៧. មហាបេសការសិក្ខាបទ មានគេចង់ឱ្យត្បាញចីវរប្រគេនភិក្ខុ តែគេមិនបវារណាទេ ក៏ចូលទៅបង្គាប់ជាងតម្បាញឱ្យត្បាញឱ្យល្អជាដើម ចាំលោកថែមរង្វាន់ខ្លះទៀត ។ វិ.មហាវិ.ភាគ ៣ ទំព័រ ១៩៩

៨. អច្ចេកចីវរសិក្ខាបទ នៅថ្ងៃ ៥ កើតខែអស្សុជ បើមានគេប្រគេនចីវរ គប្បីទទួលទុក កុំឱ្យលើសកំណត់ឱ្យសោះ គឺបើភិក្ខុមិនបានក្រាលកឋិនទុកបាន ១ ខែ ១១ ថ្ងៃ ។ បើបានក្រាលកឋិនទុកបាន ៥ ខែ ១១ ថ្ងៃ ។ វិ.មហាវិ.ភាគ ៣ ទំព័រ ២០៥

៩. សាសង្កសិក្ខាបទ ភិក្ខុរស់នៅក្នុងសេនាសនៈវត្តឯព្រៃ ឬទីដែលមិនមានសុវត្ថិភាពគ្រប់គ្រាន់ អាចទុកចីវរណាមួយ បណ្តាចីវរទាំង ៣ នៅតាមចន្លោះស្រុកភូមិបាន តែត្រូវទៅពិនិត្យ ៦ ថ្ងៃយ៉ាងយូរ មិនឱ្យលើសឡើយ វៀរតែភិក្ខុដែលបានសម្មតិពីសង្ឃ ។ វិ.មហាវិ.ភាគ ៣ ទំព័រ ២១១

១០. **បរិណតសិក្ខាបទ** វិ.មហាវិ.ភាគ ៣ ទំព័រ ២១៦

# ៤. បាចិត្តិយនិទ្ទេសវណ្ណនា

## មុសាវាទវគ្គ ទី ១

៣០. ឥឡូវនេះ ដើម្បីសម្តែងបាចិត្តិយសិក្ខាបទឡើង លោកអាចារ្យទើបប្រារព្ធពាក្យថា **សម្បជានមុសាវាទេ** ជាដើម។

ក្នុងគាថានោះ ពាក្យថា **សម្បជានមុសាវាទេ** ជាសត្តមីវិភត្តិចុះក្នុងអត្ថនិមិត្ត សេចក្តីថា តស្មា យោ ភិក្ខុ សម្បជានន្តោ មុសា វទតិ តស្ស តន្និមិត្តំ តំហេតុ តប្បច្ចយា បាចិត្តិយំ ឱទីរិតំ ប្រែថា ព្រោះហេតុនោះ ភិក្ខុណា កាលដឹងខ្លួនពោលកុហក, ភិក្ខុនោះ បណ្ឌិតពោលថា ត្រូវអាបត្តិបាចិត្តិយ ព្រោះនិមិត្តនោះ ព្រោះហេតុនោះ ព្រោះបច្ច័យនោះ ។[១៩]

ពាក្យថា **ភិក្ខុញ្ច ឱមសន្តស្ស** សេចក្តីថា ជាតិនាមគោត្តកម្មសិប្បវិយអាពាធលិង្គកិលេសាបត្តិអក្កោសេសុ ភូតេន វា អភូតេន វា យេន កេនចិ មុខសត្តិនា ភិក្ខុំ ឱវិជ្ឈន្តស្ស ភិក្ខុនោ បាចិត្តិយំ ឱទីរិតំ[២០] ភិក្ខុកាលចាក់ដោតភិក្ខុផងគ្នាដោយលំពែងគឺមាត់ ដោយបណ្តាអក្កោសវត្ថុ គឺ ជាតិ ឈ្មោះ គោត្រ ការងារ

---

[១៩] មុសាវាទសិក្ខាបទ ទី ១ វិ. មហាវិ.ភាគ ៣ ទំព័រ ២២១

[២០] ឱមសវាទសិក្ខាបទ ទី ២ វិ. មហាវិ.ភាគ ៣ ទំព័រ ២៣៦

សិប្បៈ វ័យ អាពាធ ភេទ កិលេស និងអាបត្តិណាមួយ ទោះពិតក្តី មិនពិតក្តី លោកពោលថា ត្រូវអាបត្តិបាចិត្តិយ ។

ពាក្យថា **បេសុញ្ញហរណោបិ ច** គឺ ពាំនាំពាក្យញុះញង់របស់ភិក្ខុផងគ្នា អធិប្បាយថា ជាតិអាទីហិ អក្កោសវត្ថូហិ ភិក្ខុំ អក្កោសន្តស្ស ភិក្ខុនោ សុត្វា ភិក្ខុនោ បិយកម្យតាយ វា ភេទាធិប្បាយេន វា យោ អក្កុទ្ធោ តស្ស ភិក្ខុស្ស កាយេន វា វាចាយ វា បេសុញ្ញហរណាវបនេ បាចិត្តិយំ ឧទីរិតំ ភិក្ខុណាជាអ្នកមិនក្រោធទេ ពេលឮពាក្យរបស់ភិក្ខុកំពុងជេរប្រទេចភិក្ខុផងគ្នា ដោយបណ្តាអក្កោសវត្ថុទាំងឡាយ មានជាតិជាដើម ដោយភាពជាអ្នកចង់ឱ្យភិក្ខុនោះស្រឡាញ់ខ្លួន ឬចង់ឱ្យគេបែកបាក់គ្នា លោកពោលថា ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ព្រោះពាំនាំពាក្យញុះញង់ដោយកាយ ឬដោយវាចា ។[៦១]

៣១. គប្បីជ្រាបសេចក្តីសរុប(ក្នុងគាថានេះ)ដូចនេះ ៖ [៦២]

សង្គីតិត្តយមារុឡ្ហំ បិដកត្តយំ ធម្មំ ភិក្ខុញ្ច ភិក្ខុនិញ្ច ឋបេត្វា អញ្ញេន បុគ្គលេន សទ្ធិំ ឯកតោ បទំ បទំ ភណន្តស្ស ភិក្ខុនោ បទគណនាយ បាចិត្តិយំ ឧទីរិតំ ភិក្ខុកាលពោលធម៌ គឺ

[៦១] បេសុញ្ញសិក្ខាបទ ទី ៣ វិ. មហាវិ.ភាគ ៣ ទំព័រ ២៧២

[៦២] បទសោធម្មសិក្ខាបទ ទី ៤ វិ. មហាវិ.ភាគ ៣ ទំព័រ ២៨៥

ព្រះត្រៃបិដកដែលឡើងកាន់សង្គីតិទាំងបីគ្រាជាបទៗ ក្នុងពេលតែមួយជាមួយបុគ្គលដទៃ លើកទុកតែភិក្ខុ និងភិក្ខុនីចេញ លោកពោលថា ត្រូវបាចិត្តិយ ដោយរាប់បទ ។

៣២. ពាក្យថា **អនុបសម្បន្នេនេវ** គប្បីសម្គន្ធដូចនេះ៖ [៦៣]

ភិក្ខុំ ឋបេត្វា អន្តមសោ បារាជិកវត្ថុភូតេន តិរច្ឆានគតេនាបិ សហ តិរត្តិយំ សយិត្វា ចតុត្ថទិវសេ អត្ថង្គតេ សូរិយេ បុន សហសេយ្យាយ បាចិត្តិ សិយា វៀរតែភិក្ខុចេញ ភិក្ខុដេក(ជាមួយអនុបសម្បន្ន)ដោយហោចទៅ សូម្បីជាមួយសត្វតិរច្ឆានដែលជាវត្ថុនៃអាបត្តិបារាជិកអស់បីរាត្រី កាលព្រះសុរិយាថ្ងៃទី ៤ អស្តង្គតទៅ ដេកម្តងទៀត ត្រូវអាបត្តិបាចិត្តិយ ។ ក្នុងគាថានោះ បទថា **សហសេយ្យាយ** គប្បីជ្រាបដោយការដេក គឺដោយការដេកមិនប៉ងទុកមុនក្តី ក្នុងខណៈតែមួយជាមួយគ្នាក្តី លើសេនាសនៈដែលប្រក់ និងបិទបាំងទាំងអស់ក្តី ប្រក់ និងបិទបាំងដោយច្រើនក្តី។ បណ្តាសេនាសនៈទាំងនោះសេនាសនៈដែលមិនមានជញ្ជាំងទល់ដល់ដំបូល សូម្បីបិទបាំងដោយគ្រឿងបិទបាំងមានកំផែងជាដើម មានកំពស់មួយហត្ថកន្លះ គប្បីជ្រាបថា សេនាសនៈបិទបាំងទាំងអស់ ដូច្នេះពិត ។

៣៣. គប្បីជ្រាបសេចក្តី(ក្នុងគាថានេះ)ថា ៖ [៦៤]

---

[៦៣] បឋមសហសេយ្យសិក្ខាបទ ទី ៥ វិ. មហាវិ.ភាគ ៣ ទំព័រ ២៨៩

ឯករត្តម្បិ ឥត្ថិយា សទ្ធឹ សេយ្យំ កប្បយតោ តស្ស ភិក្ខុនោបិ បាចិត្តិ សិយា ភិក្ខុកាលសម្រេចនូវទីដេកជាមួយស្ត្រី សូម្បីអស់មួយរាត្រីក៏ដោយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយដែរ ។ ក្នុងគាថានោះ ពាក្យថា **ឥត្ថិយា** គឺដោយហោចទៅសូម្បីកើតហើយក្នុងថ្ងៃនោះ ។

ពីរបាទគាថាថា **ទេសេន្តស្ស វិនា វិញ្ញុំ ធម្មញ្ច ឆប្បទុត្តរិំ** សេចក្តីថា វិញ្ញុំ បុរិសំ វិនា ឥត្ថិយា ឆប្បទតោ ឧត្តរិំ ធម្មំ ទេសេន្តស្ស ភិក្ខុនោ បាចិត្តិ សិយា ភិក្ខុកាលសម្តែងធម៌លើសពី ៦ ម៉ាត់ឡើងទៅដល់ស្ត្រី វៀរតែមានបុរសដឹងក្តីនៅជាមួយក្តី ត្រូវអាបត្តិបាចិត្តិយ បណ្តាពាក្យទាំងនោះ ក្នុងពាក្យថា **ឆប្បទុត្តរិំ** អ្នកសិក្សាគប្បីជ្រាបប្រមាណនៃបទក្នុងទីទាំងពួងយ៉ាងនេះថា បាទនៃគាថាមួយ ឈ្មោះថា ១ បទ (១ ម៉ាត់) ។ បទទាំងឡាយ ៦ ឈ្មោះថា ៦ បទ (៦ ម៉ាត់), លើសជាង ៦ ម៉ាត់ទៅ ឈ្មោះថា លើសពី ៦ ម៉ាត់ឡើងទៅ។[៦៥]

៣៤. គប្បីជ្រាបសេចក្តីដូចនេះ ៖

---

[៦៤] ទុតិយសហសេយ្យសិក្ខាបទ ទី ៦ វិ. មហាវិ. ភាគ ៣ ទំព័រ ២៩៥

[៦៥] ធម្មទេសនាសិក្ខាបទ ទី ៧ វិ. មហាវិ.ភាគ ៣ ទំព័រ ៣០៣

ភិក្ខុសម្មុតឹ ឋបេត្វា ភិក្ខុនោ ទុដ្ឋុល្លំ វជ្ជំ អភិក្ខុនោ វិទន្តស្ស បាចិត្តិយំ ឱទីរិតំ ភិក្ខុកាលប្រាប់នូវទោសដ៏អាក្រក់ ដល់បុគ្គលមិនមែនជាភិក្ខុ វៀរលែងតែបានភិក្ខុសម្មតិ លោកពោលថា ត្រូវអាបត្តិបាចិត្តិយ ។ ក្នុងគាថានោះ ពាក្យថា **ទុដ្ឋុល្លំ** ក្នុងទីនេះ គឺលោកបំណងយកអាបត្តិសង្ឃាទិសេស ។ ពាក្យថា **ភិក្ខុសម្មតិយា** គឺ លើកទុកតែកតិកាដែលសង្ឃធ្វើ ឬមិនធ្វើនូវទីបំផុតនៃអាបត្តិទាំងឡាយ និងត្រកូលទាំងឡាយ ទើបអបលោកអស់វារៈ ៣ ដង ចំពោះភិក្ខុដែលត្រូវអាបត្តិរឿយៗ ដើម្បីឱ្យសង្រួមតទៅ ។ ពាក្យថា **អភិក្ខុនោ** គឺ ដល់អនុបសម្បន្ន ។ ពាក្យថា **វិទន្តស្ស** ប្រែថា ប្រាប់ ។[៦៦]

៣៥. យោ អកប្បិយំ បឋវឹ ខណេយ្យ វា ខណាបេយ្យ វា តស្ស បាចិត្តិយំ សិយា[៦៧] ភិក្ខុណា ជីកឯងក្តី ឱ្យគេជីកក្តី នូវផែនដីជាអកប្បិយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។ បណ្តាបទទាំងនោះ បទថា **អកប្បិយំ** បានដល់ ផែនដីដែលគេមិនដុតដោយអំណាចការដុតចម្អិនក្នុងចង្ក្រានជាដើមក្តី មិនដុតផ្ទាល់ដោយប្រការយ៉ាងនេះៗក្តី លោកហៅថា **ជាតបឋវី** ជាតបឋវី

---

[៦៦] ទុដ្ឋុល្លារោចនសិក្ខាបទ ទី ៩ វិ. មហាវិ.ភាគ ៣ ទំព័រ ៣៣៦

[៦៧] បឋវីខននសិក្ខាបទ ទី ១០ វិ.មហាវិ.ភាគ ៣ ទំព័រ ៣៤២

នោះ មាន ៣ ដោយអំណាចដីសុទ្ធ (សុទ្ធបឋវី) ដីលាយក្រួស ជាដើម (មិស្សកបឋវី) និងគំនរអាចម៍ដី (បុញ្ជបឋវី) ។ បណ្តា ជាតបឋវីទាំងនោះ អាចម៍ដីសុទ្ធតាមប្រក្រតី ឬដីស្អិតសុទ្ធ ឈ្មោះថា **សុទ្ធបឋវី** ។ ចំណែកដីទី ៣ នៃដុំថ្ម ក្រួស អំបែង ក្រួសរវាន និងខ្សាច់ណាមួយ អំពីអាចម៍ដី ឬដីស្អិតមានក្នុងទីណា ដីក្នុងទីនោះឈ្មោះថា **មិស្សកបឋវី** គំនរអាចម៍ដី ឬដីស្អិតដែលភ្លៀងបង្អុរត្រូវហើយលើសជាង ៤ ខែឡើងទៅ ឈ្មោះថា **បុញ្ជបឋវី** ។ ក៏តាមលក្ខណៈដែលពោលហើយនេះ សូម្បីគំនរមិស្សកបឋវីដែលភ្លៀងពាល់ត្រូវសូម្បីនូវធូលីដ៏ស្អិតតាំងនៅ លើផែនថ្មអស់វារៈ ១ ដង បើធូលីសើម ឱកាសដែលសើមតាំងនៅរហូតដល់បួនខែកន្លងទៅ រមែងដល់ការរាប់ថា បុញ្ជបឋវី ពិត[២៨]។

មុសាវាទវគ្គ ទី ១ ចប់[២៩]

---

[២៨] ធូលីដែលគរទុកលើថ្ម ឈ្មោះថា មិស្សកបឋវី តែបើមានភ្លៀងត្រូវដីនោះតែម្តងក៏ដោយ បើសើមរហូតដល់ ៤ ខែ ក៏រាប់ជាបុញ្ជបឋវីទៅវិញ បើភិក្ខុទំលាយ ត្រូវអាបត្តិបាចិត្តិយ ។

[២៩] ពាក្យនេះ មិនមានក្នុងទីនេះទេ តែខ្ញុំដាក់មក ព្រោះចង់ដើម្បីសម្តែងសិក្ខាបទបាចិត្តិយសូម្បីទាំងអស់តាមវគ្គដោយពិត ។ ក៏ឯបាចិត្តិយសិក្ខាបទទាំងឡាយមាន ៩២ តែងឡើងកាន់ឧទ្ទេសរាល់ៗកន្លះខែម្តង ដែលមានក្នុងភិក្ខុប្បាតិមោក្ខ និងវិនយបិដក មហាវិភង្គ តតិយភាគ ៣ និងចតុត្ថភាគ ៤ ។ តែក្នុងទីនេះ លោកអាចារ្យលើកយកតែ ៤១ សិក្ខាបទប៉ុណ្ណោះ ឡើងកាន់

## ភូតគាមវគ្គ ទី ២

សេចក្តីសម្ពន្ធអ្នកសិក្សាគប្បីជ្រាបដូច្នេះ៖ [៣០]

យោ ភិក្ខុ ភូតគាមំ វិកោបេយ្យ តស្ស បាចិត្តិយំ សិយា ភិក្ខុណា កំទេចនូវភូតគាម ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។ ក្នុងអធិការនោះ ពាក្យថា **ភូតគាមំ** មានវិគ្រោះដូចនេះ ៖ ធម្មជាតិណា តែងកើត និងគប្បីកើត ព្រោះដូច្នោះ ធម្មជាតិនោះ ឈ្មោះថា **ភូតា**, អធិប្បាយថា តែងកើត តែងចម្រើន គឺកើតហើយចម្រើនហើយ, គំនរ ឈ្មោះថា **គាមោ** គំនរនៃភូតគាមទាំងឡាយ ឬភូតនោះឯងជាគំនរ ដូច្នេះ ឈ្មោះថា **ភូតគាម**, ពាក្យនេះ ជាឈ្មោះនៃធម្មជាតិមានស្មៅ និងឈើដែលមានពណ៌ខៀវដុះនៅស៊ប់ហើយជាដើម ។ លោកសំដៅយក

---

និទ្ទេស ដូច្នេះ ដើម្បីសិក្ខាកាមទាំងឡាយមិនលំបាកស្វែងរក ទើបខ្ញុំនាំយកសិក្ខាបទសូម្បី ៥១ ដទៃទៀត ដោយពាក្យថា មុសាវាទវគ្គទី ១ ជាដើម ។ មុសាវាទវគ្គនេះ លោកអាចារ្យសម្តែងហើយដោយច្រើន សេសតែសិក្ខាបទ ទី ៨ មួយប៉ុណ្ណោះ ព្រោះមានន័យ ដូចបានពោលហើយក្នុងចតុត្ថបារាជិកសិក្ខាបទមែនពិត ។ សិក្ខាបទដ៏សេសនោះគឺ

៨. ភូតារោចនសិក្ខាបទ ទី ៨ ភិក្ខុពោលប្រាប់ឧត្តរិមនុស្សធម៌ ដែលមានពិតក្នុងខ្លួន ។ វិ. មហាវិ.ភាគ ៣ ទំព័រ ៣១១

[៣០] ១. ភូតគាមសិក្ខាបទ ទី ១ វិ.មហាវិ.ភាគ ៣ ទំព័រ ៣៤៧

ភូតគាមនោះ ។ ពាក្យថា **វិកោបេយ្យ** គឺ ធ្វើកិច្ចមានការកាត់និងការបំបែកជាដើម ។

៣៦. គប្បីជ្រាបសេចក្តីប្រកបដូច្នេះ ៖ [៣១]

យោ ភិក្ខុ សង្ឃិកំ មញ្ចាទឹ អជ្ឈោកាសេ សន្ថរណាទិកំ កត្វា អាបុច្ឆនាទិកំ អកត្វា យាតិ តស្ស បាចិត្តិ សិយា ភិក្ខុណាធ្វើកិច្ចមានការក្រាលជាដើម នូវសេនាសនៈមានគ្រែជាដើមជារបស់សង្ឃ មិនធ្វើកិច្ចមានកិរិយាប្រាប់ជាដើមទេហើយទៅ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។ ក្នុងគាថានោះ ពាក្យថា **សង្ឃិកំ** គឺវត្ថុជារបស់នៃសង្ឃ។ ដោយ**អាទិ**សព្ទ ក្នុងពាក្យថា **មញ្ចាទឹ** នេះ លោកអាចារ្យតែងសង្គ្រោះយកអាសនៈមានតាំង ពូក និងខ្នើយ ជាដើម ។ ពាក្យថា **សន្ថរណាទិកំ** សេចក្តីថា ធ្វើដោយខ្លួនឯងក្តី ប្រើគេឱ្យធ្វើក្តី នូវកិច្ចមានការក្រាលជាដើម ។ បទថា **អាបុច្ឆនាទិកំ** សេចក្តីថា កិរិយាប្រាប់ក្តី រើយកមកទុកដោយខ្លួនឯងក្តី ប្រើគេឱ្យរើយកមកទុកឱ្យក្តី។ បទថា **យាតិ** ប្រែថា ទៅ ។

៣៧. គប្បីជ្រាបសេចក្តីយ៉ាងនេះថា៖ [៣២]

យោ ភិក្ខុ សង្ឃិកាវសថេ សេយ្យំ សន្ថរណាទិកំ កត្វា

---

[៣១] ៤. បឋមសេនាសនសិក្ខាបទ ទី ៤ វិ. មហាវិ.ភាគ ៣ ទំព័រ ៣៦៨

[៣២] ៥. ទុតិយសេនាសនសិក្ខាបទ ទី ៥ វិ.មហាវិ.ភាគ ៣ ទំព័រ ៣៧៥

អាបុច្ឆនាទិកំ អកត្វា យាតិ តស្ស ភិក្ខុនោ បាចិត្តិ សិយា ភិក្ខុណា ធ្វើនូវកិច្ចមានការក្រាលជាដើមនូវទីដេក ក្នុងសំណាក់ជាទីនៅរបស់សង្ឃ មិនធ្វើកិច្ចមានការប្រាប់ជាដើម ស្រាប់តែចេញទៅ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

ក្នុងគាថានោះ ពាក្យថា **សង្ឃិកាវសថេ** បានដល់ បន្ទប់ក្នុងវិហារជាទីនៅអាស្រ័យរបស់សង្ឃក្តី សេនាសនៈដែលសង្ឃគ្រប់គ្រងដែលបិទបាំងទាំងអស់ដទៃក្តី ។ ពាក្យថា **សេយ្យំ** បានដល់ ទីដេកមានជាដើមយ៉ាងនេះថា ពូក កម្រាល ទ្រនាប់ សំពត់សម្រាប់ដណ្តប់ (ភួយ) កម្រាលសម្រាប់គ្រែ ឬតាំង កម្រាលផែនដី កន្ទេលទន់ ច្រមខ័ណ្ឌ សំពត់សម្រាប់ទ្រាប់អង្គុយ គ្រឿងកម្រាល កម្រាលធ្វើអំពីស្មៅ កម្រាលធ្វើអំពីស្លឹកឈើ ។ បទថា **សន្ថរណាទិកំ** សេចក្តីថា ភិក្ខុធ្វើខ្លួនឯងក្តី ប្រើគេឱ្យធ្វើកិច្ចមានការក្រាលជាដើម ដោយបទទាំងនោះណាមួយ ។

៣៨-៣៩. គប្បីជ្រាបយោជនាដូច្នេះ៖

យោ បន ភិក្ខុ ជានំ សប្បាណកំ តោយំ បរិភុញ្ជេយ្យ តស្ស ភិក្ខុនោ បាចិត្តិ សិយា ភិក្ខុណាមួយ កាលដឹងហើយប្រើប្រាស់ទឹកដែលមានសត្វក្តី ត្រូវអាបត្តិបាចិត្តិយ ។ បណ្តាបទទាំងនោះ ពីរបទថា **ជានំ សប្បាណកំ** សេចក្តីថា ភិក្ខុកាលឃើញក្តី ឮក្តី ដឹងហើយ ដោយអាការណាមួយក្តី ថា ទឹកនេះមានសត្វ ។

បទថា **តោយំ** ប្រែថា ទឹក ។ ពាក្យថា **បរិភុញ្ជេយ្យ** ប្រែថា គប្បីបរិភោគប្រើប្រាស់ ។[៣៣]

## ភូតគាមវគ្គ ទី ២ ចប់[៣៤]

[៣៣] ១០. សប្បាណកសិក្ខាបទ ទី ២ មានក្នុងសប្បាណកវគ្គទី ៧ ឯណោះ ដែលនិយាយអំពីភិក្ខុដឹងថាទឹកមានសត្វហើយនៅតែឆាន់ទឹកនោះ ។ វិ.មហាវិ. ភាគ ៤ ទំព័រ ២៥២ តែក្នុងទីភូតគាមវគ្គនេះ ជាសិញ្ចនសិក្ខាបទ ទី ១០ និយាយពីភិក្ខុដឹងថា ទឹកមានសត្វហើយ ដងយកទៅស្រោចដំណាំជាដើម វិ.មហាវិ. ៤ ទំព័រ ២០

[៣៤] ក្នុងភូតគាមវគ្គនេះ មាន ១០ សិក្ខាបទ តែលោកអាចារ្យលើកតែ ៤ សិក្ខាបទឡើងកាន់និទ្ទេស ឯសិក្ខាបទដ៏សេសគឺះ

២. អញ្ញវាទសិក្ខាបទ ទី ២ ភិក្ខុធ្វើឱ្យសង្ឃលំបាក ប្រដៅបានដោយក្រ ។ វិ.មហាវិ.ភាគ ៣ ទំព័រ ៣៥៣

៣. ឧជ្ឈាបនសិក្ខាបទ ទី ៣ ភិក្ខុបង្គាប់ភិក្ខុផងគ្នា ឱ្យពោលទោសភិក្ខុផងគ្នា ។ វិ.មហាវិ.ភាគ ៣ ទំព័រ ៣៦២

៦. អនុបុប្ខជ្ជសិក្ខាបទ ទី ៦ ភិក្ខុរំខានភិក្ខុដទៃដែលនៅមុនក្នុងវិហាររបស់សង្ឃ ។ វិ.មហាវិ. ភាគ ៤ ទំព័រ ១

៧. និក្កឌ្ឍនសិក្ខាបទ ទី ៧ ភិក្ខុខឹងក្រោធហើយទង់ទាញភិក្ខុផងគ្នាចេញពីវិហារសង្ឃដោយខ្លួនឯង ឬប្រើគេ ។ វិ. មហាវិ.ភាគ ៤ ទំព័រ ៥

៨.វេហាសកុដិសិក្ខាបទ ទី ៨ ភិក្ខុអង្គុយ ឬដេកដោយរហ័សលើគ្រែឬតាំងដែលគេគ្រាន់តែស៊កជើងទុក ។ វិ.មហាវិ.ភាគ ៤ ទំព័រ ១១

៩. មហល្លកវិហារសិក្ខាបទ ទី ៩ ភិក្ខុប្រក់កុដិធំត្រូវឈរនៅក្នុងទីគ្មានដំណាំ ឬស្មៅខៀវ បានពីរបីជាន់។ វិ.មហាវិ. ភាគ ៤ ទំព័រ ១៥

## ឱវាទវគ្គ ទី ៣

យោ ភិក្ខុ បារិវត្តកំ ឋបេត្វា អញ្ញាតិកាយ ភិក្ខុនិយា ចីវរំ ទេតិ តស្ស ភិក្ខុនោ បាចិត្តិ សិយា ភិក្ខុណាមួយ ឱ្យចីវរដល់ភិក្ខុនីមិនមែនជាញាតិ វៀរលែងតែការផ្លាស់ប្តូរគ្នា ត្រូវបាចិត្តិយ សេចក្តីប្លែកគ្នាត្រឹមតែប៉ុណ្ណោះ គឺ ក្នុងចីវរប្បដិគ្គហណសិក្ខាបទ ភិក្ខុជាអ្នកទទួល តែក្នុងសិក្ខាបទនេះ ភិក្ខុនីជាអ្នកទទួល ។[៣៥]

អញ្ញាតិកាយ ភិក្ខុនិយា ចីវរំ សិព្វតោបិ តស្ស ភិក្ខុនោ បាចិត្តិ សិយា[៣៦] ភិក្ខុនោះ សូម្បីតែដេរចីវរឱ្យដល់នាងភិក្ខុនីមិនមែនជាញាតិ ក៏ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា **ចីវរំ** បានដល់ចីវរដែលសមគួរដល់ការស្លៀកដណ្តប់ ។ ពាក្យថា **សិព្វតោ** សេចក្តីថា ភិក្ខុកាលដេរដោយខ្លួនឯង កាលស៊កម្ជុលចូលទៅ ហើយដកចេញ ត្រូវអាបត្តិបាចិត្តិយ ដោយរាប់ប្រយោគ ។ ប៉ុន្តែចំពោះភិក្ខុអ្នកប្រើឱ្យដេរប្រាប់គេថា ចូរដេរ សូម្បីបើគេឱ្យសម្រេចសូចនកិច្ចទាំងអស់ ត្រូវអាបត្តិបាចិត្តិយតែមួយប៉ុណ្ណោះ កាលបង្គាប់(ញយៗ) ត្រូវអាបត្តិបាចិត្តិយដោយរាប់ប្រយោគ ។

ឱវាទវគ្គ ទី ៣ ចប់[៣៧]

---

[៣៥] ៥. ចីវរទានសិក្ខាបទ ទី ៥ វិ. មហាវិ.ភាគ ៤ ទំព័រ ៥៤

[៣៦] ៦. ចីវរសិព្វនសិក្ខាបទ ទី ៦ វិ. មហាវិ.ភាគ ៤ ទំព័រ ៥៩

[៣៧] នេះជាសិក្ខាបទដ៏សេស ក្នុងឱវាទវគ្គទី ៣ នេះ

# ភោជនវគ្គ ទី ៤

គប្បីជ្រាបសេចក្ដីថា៖ បវារេត្វាន អតិរិត្តំ អការេត្វា ភុញ្ជតោ បាចិត្តិ សិយា ភិក្ខុហាមភត្តហើយ មិនឱ្យគេធ្វើឱ្យជាអតិរិត្តភោជន ហើយបរិភោគ ត្រូវអាបត្តិបាចិត្តិយ ។ [៣៨] នេះជាសេចក្ដីវិនិច្ឆ័យក្នុងពាក្យនោះគឺ ៖

---

១. ឱវាទសិក្ខាបទ ទី ១ ភិក្ខុមិនបានសម្មតិពីសង្ឃមិនត្រូវឱ្យឱវាទដល់ភិក្ខុនី ។ វិ.មហាវិ.ភាគ ៤ ទំព័រ ២៤

២. អត្ថង្គតសិក្ខាបទ ទី ២ ទោះជាបានសង្ឃសម្មតិក៏ដោយ ភិក្ខុមិនត្រូវទៅប្រដៅភិក្ខុនីក្នុងវិកាល ។ វិ.មហាវិ.ភាគ ៤ ៣៩

៣. ភិក្ខុនីឧបស្សយសិក្ខាបទ ទី ៣ ភិក្ខុចូលទៅប្រដៅភិក្ខុនីដល់លំនៅ ។ វិ.មហាវិ.ភាគ ៤ ទំព័រ ៤៤

៤. អាមិសសិក្ខាបទ ទី ៤ ភិក្ខុពោលទោសភិក្ខុផងគ្នាថា ទេសន៍ប្រដៅភិក្ខុនីព្រោះតែអាមិស ។ វិ.មហាវិ.ភាគ ៤ ទំព័រ ៥០

៧. សំវិធានសិក្ខាបទ ទី ៧ បបួលភិក្ខុនីដើរផ្លូវជាមួយគ្នា ។ វិ.មហាវិ.៤ ទំ ៦៣

៨. នាវាភិរុហនសិក្ខាបទ ទី ៨ បបួលភិក្ខុនីជិះទូកជាមួយគ្នា ។ វិ.មហាវិ.ភាគ ៤ ទំព័រ ៦៩

៩. បរិបាចនសិក្ខាបទ ទី ៩ ភិក្ខុដឹងហើយឆាន់ចង្ហាន់ដែលនាងភិក្ខុនីចាត់ចែង វិ.មហាវិ.ភាគ ៤ ទំព័រ ៧៤

១០. រហោនិសជ្ជសិក្ខាបទ ទី ១០ អង្គុយក្នុងទីស្ងាត់តែពីរនាក់ភិក្ខុនី ។ វិ.មហាវិ.ភាគ ៤ ទំ. ៨០

[៣៨] ៥. បឋមប្បវារណាសិក្ខាបទ ទី ៥ វិ. មហាវិ.ភាគ ៤ ទំព័រ ១១៨

ឱទនោ សត្តុ កុម្មាសោ មច្ឆោ មំសន្តិ បញ្ចន្នំ ភោជនានំ អញ្ញតរំ សាសបមត្តម្បិ អជ្ឈោហរិត្វា ភោជនំ បដិក្ខេបំ កត្វា អញ្ញេន ឥរិយាបថេន អលមេតំ សព្វន្តិ អតិរិត្តំ អការេត្វា បរិភុញ្ជតោ បាចិត្តិ ហោតិ ភិក្ខុកាលលេបចូលនូវភោជនណាមួយ បណ្ដាភោជនទាំង ៥ គឺ បាយ នំស្រស់ នំក្រៀម ត្រី សាច់ សូម្បីប្រមាណប៉ុនគ្រាប់ស្ពៃ ហើយធ្វើការបដិសេធចំពោះភោជន មិនបានឱ្យគេធ្វើឱ្យជាអតិរិត្តភោជនថា របស់ទាំងអស់នេះគួរហើយ ដូច្នេះទេ ក៏ឆាន់ក្នុងឥរិយាបថដទៃ (អំពីឥរិយាបថហាមភត្ត) ត្រូវអាបត្តិបាចិត្តិយ ។

៤០. គប្បីជ្រាបសេចក្ដីដូចនេះ៖ [៣៩]

យោ ភិក្ខុ អាសាទនាបេក្ខោ ភុត្តាវី បវារិតំ ភិក្ខុំ ហន្ទ ភិក្ខុ ខាទ វា ភុញ្ជ វាតិ អនតិរិត្តេន បវារេតិ ភោជនេ ភុត្តេ តស្ស បាចិត្តិយំ ឧទីរិតំ ភិក្ខុណា សំឡឹងមើលទោស បវារណាបង្ខំភិក្ខុដែលឆាន់ហើយហាមភត្តហើយ ដោយអនតិរិត្តភោជនថា ហ៏ភិក្ខុ! លោកចូរទំពាស៊ីក្ដី ចូរបរិភោគក្ដី កាលភិក្ខុនោះឆាន់រួច ភិក្ខុអ្នកបង្ខំនោះត្រូវអាបត្តិបាចិត្តិយ។ ក្នុងប្រយោគនោះ ពាក្យថា **អាសាទនា-**

---

[៣៩] ៦. ទុតិយប្បវារណាសិក្ខាបទ ទី ៦ វិ. មហាវិ.ភាគ ៤ ទំព័រ. ១២៥

**បេត្វា** សេចក្តីថា ចងអាឃាត ចោទ សម្លឹងរំពៃរកនូវភាពនៃការធ្វើឱ្យខ្មាស ។

៤១.៤២. គប្បីជ្រាបសេចក្តីវិនិច្ឆ័យដូចនេះ៖ [៦០]

យោ ភិក្ខុ សន្និធិភោជនំ ភុញ្ជេយ្យ តស្ស ភិក្ខុនោ បាចិត្តិ សិយា ភិក្ខុណា ឆាន់ភោជនដែលខ្លួនធ្វើការសន្សំទុក ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។ បណ្តាបទទាំងនោះ ពាក្យថា **សន្និធិភោជនំ** បានដល់ ភោជនដែលភិក្ខុទទួលហើយទុកឱ្យកន្លងមួយរាត្រីទៅ ។

យោជនាដូច្នេះ [៦១] ៖ វិកាលេ យាវកាលិកំ ភុញ្ជតោ វាបិ បាចិត្តិ សិយា សូម្បីភិក្ខុឆាន់វត្ថុជាយាវកាលិក ក្នុងវេលាវិកាល ក៏ត្រូវអាបត្តិបាចិត្តិយដែរ ។

បណ្តាបទទាំងនោះ បទថា **វិកាលេ** គឺ កាលទៅប្រាសហើយ សេចក្តីថា រយៈពេលកន្លងថ្ងៃត្រង់ទៅរហូតដល់អរុណរះឡើង ។ ពាក្យថា **យាវកាលិកំ** គឺអាមិសភោជន មានមើមឈើ ផ្លែឈើក្នុងព្រៃជាដើម ។

យោជនានេះគឺ៖ [៦២] អគិលានោ ភិក្ខុ បណីតកំ សប្បិ

---

[៦០] ៨. សន្និធិការកសិក្ខាបទ ទី ៨ វិ. មហាវិ.ភាគ ៤ ទំព័រ. ១៣៥

[៦១] ៧. វិកាលភោជនសិក្ខាបទ ទី ៧ វិ. មហាវិ.ភាគ ៤ ទំព័រ. ១៣១

ភត្តាទិកម្បិ វិញ្ញាបេត្វាន ភុញ្ជេយ្យ តស្ស ភិក្ខុនោ បាចិត្តិ សិយា ភិក្ខុគ្មានជម្ងឺ សុំភោជនដ៏ប្រណីត មានភត្តលាយដោយសប្បិជាដើមក៏ដោយ ហើយបរិភោគ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។ បណ្តាបទទាំងនោះ ភិក្ខុមិនមានឈឺថ្កាត់ ឈ្មោះថា **អគិលានោ** ។ បទថា **បណីតកំ** បានដល់ ភោជនយ៉ាងប្រណីតដែលកើតចេញអំពីធញ្ញជាតិ ៧ ប្រភេទ លាយដោយភេសជ្ជៈ ពោលគឺ ទឹកដោះថ្លា ប្រេង ទឹកឃ្មុំ ស្ករអំពៅ ត្រី សាច់ ទឹកដោះស្រស់ ទឹកដោះជូរ

សេចក្តីថា យោ ភិក្ខុ ទន្តកដ្ឋោទកំ វិជ្ជេត្វា អប្បដិគ្គហិតកំ ភុញ្ជេយ្យ បាចិត្តិ សិយា ភិក្ខុណា បរិភោគវត្ថុដែលគេមិនបានប្រគេន វៀរលែងតែទឹកនិងឈើស្ទន់ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។

បណ្តាបទទាំងនោះ បទថា **អប្បដិគ្គហិតំ** គឺ ភិក្ខុយកដោយកាយ ឬវត្ថុជាប់ដោយកាយនូវវត្ថុដែលគេឈរក្នុងហត្ថបាសដែរ តែមិនបានឱ្យដោយកាយ ឬវត្ថុជាប់នឹងកាយ ឬបោះឱ្យណាមួយឡើយ (យ៉ាងនេះ) ឈ្មោះថា **មិនបានប្រគេន** ។[៦៣]

ភោជនវគ្គ ទី ៤ ចប់[៦៤]

[៦២] ៩. បណីតភោជនសិក្ខាបទ ទី ៩ វិ. មហាវិ.ភាគ ៤ ទំព័រ. ១៣៩

[៦៣] ១០. ទន្តបោនសិក្ខាបទ ទី ១០ វិ. មហាវិ.ភាគ ៤ ទំព័រ. ១៤៥

[៦៤] នេះជាសិក្ខាបទដ៏សេស ក្នុងវគ្គនេះ ៖

## អចេលកវគ្គ ទី ៥

៤៣. មានសម្ពន្ធដូច្នេះ យោ ភិក្ខុ តិត្ថិយស្ស សហត្ថតោ កិញ្ចិ ភុញ្ជិតព្វំ ទទេយ្យ តស្ស បាចិត្តិ សិយា ភិក្ខុណា គប្បីឱ្យវត្ថុតិចតួចដែលគួរបរិភោគដោយដៃខ្លួនឯង ដល់តិរ្ថិយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។[៥]

បណ្តាបទទាំងនោះ បទថា **តិត្ថិយស្ស** បានដល់ ជនអ្នកមានលទ្ធិដទៃ ។ ពីរបទថា **កិញ្ចិ ភុញ្ជិតព្វំ** បានដល់ វត្ថុដែលគួរបរិភោគណាមួយ ពាក្យថា **សហត្ថតោ** គឺ អំពីដៃខ្លួនឯង។

---

១. អាវសថបិណ្ឌសិក្ខាបទ ទី ១ ភិក្ខុគ្មានជម្ងឺ ឆាន់បិណ្ឌបាតក្នុងរោងទានបានតែម្តង ។ វិ.មហាវិ.ភាគ ៤ ទំ. ៨៤

២. គណភោជនសិក្ខាបទ ទី ២ ភិក្ខុមិនមានសម័យគឺមិនបានក្រាលកឋិនជាដើម ឆាន់ភោជនដែលគេនិមន្តដោយចេញឈ្មោះភត្តណាមួយ មានបាយ នំ ជាដើម ។ វិ. មហាវិ.ភាគ ៤ ទំព័រ ៨៩

៣. បរម្បរភោជនសិក្ខាបទ ទី ៣ ភិក្ខុមិនបានក្រាលកឋិនជាដើម ទទួលនិមន្តឯណោះ ហើយទៅទទួលនិមន្តឆាន់ចង្ហាន់ របស់ទាយកផ្សេងទៀត ។ វិ.មហាវិ.ភាគ ៤ ទំព័រ ១០០

៤. កាណមាតាសិក្ខាបទ ទី ៤ ភិក្ខុទទួលបវារណាឱ្យទទួលនំតាមប្រាថ្នា គប្បីយកត្រឹមតែពីរបីបាត្រប៉ុណ្ណោះ ហើយត្រូវយកមកចែកគ្នាឆាន់ចុះ មិនត្រូវប្រាប់គ្នីគ្នាឱ្យទៅបិណ្ឌបាតនៅផ្ទះនោះទៀតទេ ។ វិ.មហាវិ.ភាគ ៤ ទំព័រ ១១០

[៥] អចេលកសិក្ខាបទ ទី ១ វិ. មហាវិ.ភាគ ៤ ទំព័រ. ១៥០

សម្ពន្ធថា “[៦៦] យោ ភិក្ខុ មាតុគាមេន ឯកតោ រហោ និសជ្ជំ កប្បេយ្យ តស្ស បាចិត្តិ សិយា ភិក្ខុណា សម្រេចនូវការអង្គុយក្នុងទីស្ងាត់តែមួយជាមួយនឹងមាតុគ្រាម ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។ បទថា **រហោ** ប្រែថា ក្នុងទីស្ងាត់ ។ បទថា **កប្បេ** ប្រែថា គប្បីសម្រេច ។ បទថា **ឯកតោ** គឺជាមួយគ្នា ។

អចេលកវគ្គ ទី ៥ ចប់ [៦៧]

---

[៦៦] ៤.៥. រហោនិសជ្ជសិក្ខាបទ វិ. មហាវិ.ភាគ ៤ ទំព័រ. ១៦៥ និង ទំព័រ ១៦៩

[៦៧] នេះជាសិក្ខាបទដ៏សេស ក្នុងវគ្គនេះ៖

២. ឧយ្យោជនសិក្ខាបទ ទី ២ ភិក្ខុបបួលភិក្ខុផងគ្នាទៅស្រុកបិណ្ឌបាត មិនឱ្យគេឱ្យអ្វីតិចតួចដេញគ្នាមកវិញ ។ វិ.មហាវិ.ភាគ ៤ ទំ. ១៥៦

៣. សភោជនសិក្ខាបទ ទី ៣ ភិក្ខុទៅអង្គុយក្នុងផ្ទះដែលគេនៅ តែពីរនាក់ប្ដីប្រពន្ធគេ ។ វិ.មហាវិ.ភាគ ៤ ទំព័រ ១៦១

៦. ចារិត្តសិក្ខាបទ ទី ៦ ភិក្ខុមិនបានក្រាលកឋិនជាដើមទេ ទទួលនិមន្តគេហើយ ក៏ចូលទៅកាន់ត្រកូលដទៃ ឱ្យភិក្ខុផងគ្នារង់ចាំឯផ្ទះអ្នកនិមន្តឆាន់ ។ វិ. មហាវិ.ភាគ ៤ ទំព័រ ១៧៣

៧. មហានាមសិក្ខាបទ ទី ៧ ភិក្ខុគ្មានជម្ងឺ ត្រូវត្រេកអរការបវារណាបានត្រឹម ៤ ខែ វៀរលែងតែគេបវារណាថែមទៀត ឬគេបវារណាជានិច្ច ។ វិ. មហាវិ.ភាគ ៤ ទំព័រ ១៨៣

៨. ឧយ្យុត្តសិក្ខាបទ ទី ៨ ភិក្ខុទៅមើលកងទ័ពដែលគេលើកចេញទៅច្បាំង។ វិ.មហាវិ.ភាគ ៤ ទំព័រ ១៩២

## សុរាបានវគ្គ ទី ៦

៥៤. វិនិច្ឆ័យក្នុងពាក្យថា **សុរាមេរយបានេបិ** នេះ គប្បីជ្រាប ដូចនេះ៖ [៤៨]

ទឹកស្រវឹងដែលគេធ្វើដោយវត្ថុទាំងឡាយមានម្សៅជាដើម ឈ្មោះថា **សុរា** ។ គ្រឿងត្រាំដែលគេធ្វើផ្សំដោយគ្រឿងផ្សំទាំងឡាយ មានផ្កាឈើជាដើម ឈ្មោះថា **មេរ័យ** អធិប្បាយថា យោ ភិក្ខុ តទុភយម្បិ ពីជតោ បដ្ឋាយ កុសគ្គេនាបិ បិវតិ តស្ស តប្បានបច្ចយា បាចិត្តិយំ ឱទីរិតំ ភិក្ខុណា ផឹកនូវសុរា និងមេរ័យ សូម្បីទាំងពីរនោះ តាំងពីពូជទៅ (គឺតាំងពីផ្សំហើយទៅ) សូម្បីប៉ុនចុងស្បូវ ភិក្ខុនោះ លោកពោលថា ត្រូវអាបត្តិបាចិត្តិយ ព្រោះបច្ច័យ គឺការផឹកនោះ ។

ពាក្យថា **អង្គុលិបតោទកេ បាបិ** សេចក្តីថា អង្គុលីហិ

---

៩. សេនាវាសសិក្ខាបទ ទី ៩ បើមានហេតុអ្វីត្រូវទៅទីកងទ័ព អាចនៅបាន ត្រឹមពីរបីរាត្រី ។ វិ.មហាវិ.ភាគ ៤ ទំ. ១៩៧

១០. ឧយ្យោធិកសិក្ខាបទ ទី ១០ នៅក្នុងកងទ័ពពីរបីរាត្រីហើយ ដើរទៅកាន់ទីច្បាំងគ្នា ត្រួតពលជាដើម។ វិ.មហាវិ.ភាគ ៤ ទំព័រ ២០០

[៤៨] ១. សុរាបានសិក្ខាបទ ទី ១ វិ. មហាវិ.ភាគ ៤ ទំព័រ ២០៤

ឧបកច្ឆកាទីនំ ឃដ្ដនបច្ចយា បាចិត្តិ សិយា ត្រូវអាបត្តិបាចិត្តិយ ព្រោះបច្ច័យ គឺការចាក់លេងទៅលើរាងកាយមានក្លៀកជាដើម ដោយម្រាមដៃ (ចាក់ក្រឡេកគ្នាលេង) ។ [៤៩]

ពាក្យថា **ហស្សធម្មេបិ ឧទកេ** សេចក្តីថា ឧបរិគោប្ផកេ ឧទកេ ហស្សធម្មេ កីឡានិមិត្តំ តស្ស បាចិត្តិ សិយា និមិត្តព្រោះការលេងធម៌ គឺការសើចក្នុងទឹកមានជម្រៅប្រមាណលើភ្នែកគោរ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។ [៥០]

៤៥. ពីរពាក្យថា **អនាទរេបិ បាចិត្តិ** សេចក្តីថា បុគ្គលស្ស វា ធម្មស្ស វា អនាទរករណេបិ បាចិត្តិ សិយា ភិក្ខុត្រូវអាបត្តិបាចិត្តិយ សូម្បីព្រោះការធ្វើសេចក្តីមិនអើពើចំពោះបុគ្គល ឬចំពោះធម៌ ។ អធិប្បាយថា ភិក្ខុណា កាលដែលឧបសម្បន្នភិក្ខុតាមដែលទ្រង់បញ្ញត្តបានពោលដាស់តឿនហើយ ព្រោះជាអ្នកមិនចង់ធ្វើតាមពាក្យរបស់ភិក្ខុនោះក្តី ព្រោះជាអ្នកមិនចង់ដើម្បីសិក្សាធម៌នោះក្តី ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ព្រោះសេចក្តីមិនអើពើនោះ ។ [៥១]

ភយានកំ កបំ កត្វា វា ភយានកំ រូបំ ទស្សេត្វា វា ភិក្ខុំ

---

[៤៩] ២. អង្គុលិប្បតោទកសិក្ខាបទ ទី ២ វិ. មហាវិ.ភាគ ៤ ទំព័រ ២១១

[៥០] ៣. ហស្សធម្មសិក្ខាបទ ទី ៣ វិ. មហាវិ.ភាគ ៤ ទំព័រ ២១៤

[៥១] ៤. អនាទរិយសិក្ខាបទ ទី ៤ វិ. មហាវិ.ភាគ ៤ ទំព័រ ២១៨

ភីសយតោបិ បាចិត្តិ សិយា ភិក្ខុសូម្បីកាលពោលកថាគួរឱ្យភ័យខ្លាចក្តី បន្លាចភិក្ខុផងគ្នាឱ្យភ័យខ្លាចដោយបង្ហាញរូបដ៏គួរឱ្យភ័យខ្លាចក្តី ត្រូវអាបត្តិបាចិត្តិយ ។[៦២]

៤៦. យោ ភិក្ខុ អគិលានោ កិញ្ចិ បច្ចយំ ឋបេត្វា ជោតិំ ជលេយ្យ វា ជលាបេយ្យ វា តស្ស បាចិត្តិយំ សិយា ភិក្ខុណា ជាអ្នកគ្មានជម្ងឺបង្កាត់ឯងក្តី ឱ្យគេបង្កាត់ក្តី នូវភ្លើង វៀរលែងតែមានហេតុណាមួយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។ បណ្តាបទទាំងនោះ ពីរបទថា **កិញ្ចិ បច្ចយំ** សេចក្តីថា លើកទុកតែមានហេតុមានសភាពដូច្នេះ គឺ អុចប្រទីប ឬបង្កាត់ភ្លើងក្នុងទីទាំងឡាយមានកន្លែងដុតបាត្រជាដើម ។ បទថា **ជោតិំ** ប្រែថា ភ្លើង ។[៦៣]

៤៧-៤៨. កប្បពិន្ទុំ អនាទាយ **នវចីវរភោគិនោ** នវំ ចីវរំ ភុញ្ជន្តស្ស បាចិត្តិ សិយា ភិក្ខុប្រើប្រាស់ចីវរថ្មីគឺមិនបានធ្វើកប្បពិន្ទុទេ ហើយប្រើប្រាស់ចីវរថ្មី ត្រូវអាបត្តិបាចិត្តិយ។[៦៤] បទថា **កប្បពិន្ទុំ** បានដល់ កិរិយាកំណត់ឱ្យមានស្នាមប្រមាណប៉ុនរង្វង់ភ្នែកក្ងោក ឬខ្នងក្រចកណាមួយ ។ បទថា **អនាទាយ** គឺមិនកាន់យក ។

---

[៦២] ៥. ភឹសាបនសិក្ខាបទ ទី ៥ វិ. មហាវិ.ភាគ ៤ ទំព័រ ២២១

[៦៣] ៦. ជោតិសមាទហនសិក្ខាបទ ទី ៦ វិ.មហាវិ.ភាគ ៤ ទំព័រ ២២៤

[៦៤] ៨. ទុព្វណ្ណករណសិក្ខាបទ ទី ៨ វិ.មហាវិ.ភាគ ៤ ទំព័រ ២៣៧

ភិក្ខុនោ ចីវរាទិកំ បរិក្ខារំ អបនេត្វា និធេន្តស្ស វា និធាបេន្តស្ស វា ហសាបេក្ខស្ស ភិក្ខុនោ បាចិត្តិ សិយា ភិក្ខុមានបំណងនឹងលេងសើច នាំយកលាក់ដោយខ្លួនឯងក្តី ឱ្យគេយកលាក់ក្តីនូវបរិក្ខារមានចីវរជាដើមរបស់ភិក្ខុផងគ្នា ត្រូវអាបត្តិបាចិត្តិយ ។ ដោយ**អាទិ**-សព្ទថា **ចីវរាទិកំ** លោកអាចារ្យតែងសង្គ្រោះយកបរិក្ខារមានបាត្រ និសីទនៈ បំពង់ម្ជុល និងកាយពន្ធជាដើមដែរ ។ ពាក្យថា **និធេន្តស្ស** គឺ យកទៅលាក់ទុក ។ ពាក្យថា **ហសាបេក្ខស្ស** គឺ ប៉ុនប៉ងចង់ឱ្យបានសើចលេងសប្បាយ ។[55]

សុរាបានវគ្គ ទី ៦ ចប់[56]

## សប្បាណកវគ្គ ទី ៧

ពាក្យថា **ជានំ បាណំ ហនេ ភិក្ខុ តិរច្ឆានគតម្បិ ប** សេចក្តីថា យោ ភិក្ខុ បាណោតិ ជានន្តោ តិរច្ឆានគតំ បាណំ

---

[55] ១០. ចីវរាបនិធានសិក្ខាបទ ទី ១០ វិ. មហាវិ.ភាគ ៤ ទំព័រ ២៤៥

[56] នេះជាសិក្ខាបទដ៏សេសក្នុងវគ្គនេះ៖

៧. នហានសិក្ខាបទ ទី ៧ មិនទាន់ដល់កន្លះខែភិក្ខុមិនត្រូវងូតទឹកទេ វៀរលែងតែមានសម័យ ។ វិ.មហាវិ.ភាគ ៤ ទំព័រ ២២៨

៩. វិកប្បនសិក្ខាបទ ទី ៩ ភិក្ខុវិកប្បចីវរចំពោះសហធម្មិកណាមួយ ហើយប្រើប្រាស់ចីវរដែលមិនទាន់ឱ្យដកវិកប្បចេញ ។ វិ. មហាវិ. ៤ ទំ ២៤១

ខុទ្ទកម្បិ មហន្តម្បិ ហនេយ្យ តស្ស បាចិត្តិយំ សិយា ភិក្ខុណា មួយ កាលដឹងថា សត្វមានជីវិត ហើយសម្លាប់សត្វតិរច្ឆានដែល មានជីវិតរស់នៅតូចក៏ដោយ ធំក៏ដោយ ត្រូវអាបត្តិបាចិត្តិយ ។[៥៧]

៤៩. កន្លះគាថាថា **ឆាទេតុកាមោ ឆាទេតិ ទុដ្ឋុល្លំ ភិក្ខុនោបិ ប** សេចក្តីថា យោ ភិក្ខុ ភិក្ខុនោ ទុដ្ឋុល្លសង្ខាតំ សង្ឃាទិសេសំ ឆាទេតុកាមោ ហុត្វា ឆាទេតិ តស្ស បាចិត្តិយំ សិយា ភិក្ខុណា ប្រាថ្នាដើម្បីបិទបាំងនូវអាបត្តិសង្ឃាទិសេស ពោលគឺទុដ្ឋុល្លាបត្តិរបស់ភិក្ខុផងគ្នា ហើយបិទបាំងទុក ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។[៥៨]

ឥត្ថិយា សហ សំវិធាយ គាមន្តរគតស្ស ភិក្ខុនោ បាចិត្តិយំ សិយា ភិក្ខុបបួលគ្នាដើរទៅកាន់ចន្លោះស្រុកជាមួយ ស្ត្រី ត្រូវអាបត្តិបាចិត្តិយ ។[៥៩]

សប្បាណកវគ្គ ទី ៧ ចប់[៦០]

---

[៥៧] ១. សញ្ចិច្ចបាណសិក្ខាបទ ទី ១ វិ. មហាវិ.ភាគ ៤ ទំព័រ ២៤៩

[៥៨] ៤. ទុដ្ឋុល្លសិក្ខាបទ ទី ៤ វិ. មហាវិ.ភាគ ៤ ទំព័រ ២៥៧

[៥៩] ៧. សំវិធានសិក្ខាបទ ទី ៧ វិ. មហាវិ.ភាគ ៤ ទំព័រ ២៧២

[៦០] នេះជាសិក្ខាបទដ៏សេស ក្នុងវគ្គនេះ ៖

២. សប្បាណកសិក្ខាបទ ទី ២ មានសម្តែងហើយក្នុងភូតគាមវគ្គ សិក្ខាបទទី ១០ ។ វិ.មហាវិ.ភាគ ៤ ទំព័រ ២៥២

# សហធម្មិកវគ្គ ទី ៨

៥០. បាទគាថាថា **ភិក្ខុំ វា បហរេយ្យាថ** គប្បីជ្រាបយោជនាដូចនេះថា

យោ ភិក្ខុ ភិក្ខុំ បហរេយ្យ តស្ស បាចិត្តិយំ សិយា ភិក្ខុណា វាយប្រហារភិក្ខុផងគ្នា ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។ [១]

បាទគាថាថា **តលសត្តិកមុគ្គិរេ** សេចក្តីថា យោ ភិក្ខុ បហរណាការំ ទស្សេន្តោ កាយំ វា កាយប្បដិពទ្ធំ វា ឧគ្គិរេយ្យ

៣. ឧក្កោដនសិក្ខាបទ ទី ៣ ភិក្ខុដឹងថាអធិករណ៍ដែលសង្ឃធ្វើស្រេចតាមធម៌ហើយ សើរើទៀត ។ វិ. មហាវិ.ភាគ ៤ ទំព័រ ២៥៤

៥. ឩនវីសតិសិក្ខាបទ ទី ៥ ភិក្ខុឱ្យឧបសម្បទាដល់បុគ្គលមានអាយុមិនទាន់គ្រប់ ២០ ។ វិ. មហាវិ.ភាគ ៤ ទំ. ២៦១

៦. ថេយ្យសត្ថសិក្ខាបទ ទី ៦ បបួលគ្នាដើរផ្លូវឆ្ងាយជាមួយពួកឈ្មួញចោរ (រកស៊ីខុសច្បាប់) ។ វិ. មហាវិ.ភាគ ៤ ទំ. ២៦៨

៨. អរិដ្ឋសិក្ខាបទ ទី ៨ ភិក្ខុមានទិដ្ឋិថា ធម៌ដែលព្រះមានព្រះភាគត្រាស់ ថាមានអន្តរាយ មិនអាចមានអន្តរាយទេ គឺលោកដឹងច្បាស់យ៉ាងនេះ ។ សង្ឃគប្បីហាមភិក្ខុនោះ មិនឱ្យបង្អាក់ព្រះពុទ្ធដីកា ហើយមិនលះ ។ វិ. មហាវិ.ភាគ ៤ ទំ. ២៧៦

៩. ឧក្ខិត្តសំភោគសិក្ខាបទ ទី ៩ ភិក្ខុនៅរួមជាមួយភិក្ខុមានប្រក្រតីពោលយ៉ាងនោះ មិនធ្វើតាមធម៌... ។ វិ.មហាវិ.ភាគ ៤ ទំ. ២៨៨

១០. កណ្ដកសិក្ខាបទ ទី ១០ ភិក្ខុនៅរួមជាដើមជាមួយសមណុទ្ទេសដែលសង្ឃឱ្យវិនាសហើយ ។ វិ.មហាវិ.ភាគ ៤ ទំ. ២៩៣

[១] ៤. បហារសិក្ខាបទ ទី ៤ វិ. មហាវិ.ភាគ ៤ ទំព័រ ៣២១

តស្ស បាចិត្តិយំ សិយា ភិក្ខុណា កាលសម្តែងនូវអាការប្រហារ ហើយងាឡើងនូវកាយ(ដៃ) ឬវត្ថុជាប់ដោយកាយ(វត្ថុនៅក្នុងដៃ) ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។ [៦២]

កន្លះគាថាថា **ចោទេយ្យ វា ចោទាបេយ្យ ភិក្ខុំ អមូលកេន ច** សេចក្តីថា យោ ភិក្ខុ ភិក្ខុំ អមូលកេន សង្ឃាទិសេសេន ចោទេយ្យ វា ចោទាបេយ្យ វា តស្ស បាចិត្តិយំ សិយា ភិក្ខុណាមួយ ចោទឯងក្តី ឱ្យចោទក្តី នូវភិក្ខុផងគ្នាដោយអាបត្តិសង្ឃាទិសេសមិនមានមូល ត្រូវបាចិត្តិយ ។ [៦៣]

បណ្តាបទទាំងនោះ បទថា **អមូលកេន** គឺ វៀរហើយចាកមូលមានមូលគឺការឃើញជាដើម ។

៥១. បាទគាថាថា **កុក្កុច្ចុប្បាទនេ ច** សេចក្តីថា ឩនវីសតិវស្សោ ត្វំ មញ្ញេតិអាទីនិ ភណន្តោ កុក្កុច្ចំ ឧប្បាទេយ្យ តស្ស កុក្កុច្ចុប្បាទនបច្ចយា បាចិត្តិយំ ហោតិ ភិក្ខុកាលនិយាយឱ្យមានសេចក្តីសង្ស័យឱ្យកើតឡើងដោយពាក្យមានជាដើមថា លោកមានវស្សាមិនទាន់គ្រប់ ២០ ទេដឹង ត្រូវអាបត្តិបាចិត្តិយ ព្រោះការញុាំងសេចក្តីសង្ស័យឱ្យកើតឡើងជាបច្ច័យ ។ [៦៤]

---

[៦២] ៥. តលសត្តិកសិក្ខាបទ ទី ៥ វិ.មហាវិ.ភាគ ៤ ទំព័រ ៣២៤

[៦៣] ៦. អមូលកសិក្ខាបទ ទី ៦ វិ.មហាវិ.ភាគ ៤ ទំព័រ ៣២៧

[៦៤] ៧. សញ្ចិច្ចសិក្ខាបទ ទី ៧ វិ. មហាវិ.ភាគ ៤ ទំព័រ ៣៣០

យោ ភិក្ខុ ភណ្ឌនក្តាយ ភណ្ឌនជាតានំ វចនំ សោតុំ ឧបស្សុតឹ យាតិ តស្ស បាចិត្តិយំ សិយា ភិក្ខុណា ទៅឈរ អែបចាំស្តាប់ ដើម្បីឮពាក្យរបស់ភិក្ខុទាំងឡាយ ដែលប្រកួតប្រកាន់គ្នាដើម្បីការប្រកួតប្រកាន់ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ។ បណ្តាបទទាំងនោះ បទថា **ភណ្ឌនក្តាយ** គឺដើម្បីជម្លោះ ។ បទថា **ភណ្ឌនជាតានំ** សេចក្តីថា របស់ពួកភិក្ខុដែលឈ្លោះគ្នា ។ ពាក្យថា **ឧបស្សុតឹ** គឺ ឈរអែបក្នុងទីជិតដើម្បីស្តាប់ ។ [១៥]

៥២. យោ ភិក្ខុ សង្ឃស្ស បរិណាមិតំ យំ លាភំ តំ បរបុគ្គលស្ស នាមេតិ តស្ស បាចិត្តិយំ សិយា ភិក្ខុណាមួយ បង្អោនលាភដែលគេបង្អោនទៅដើម្បីសង្ឃហើយ មកដើម្បីបុគ្គលដទៃវិញ ត្រូវអាបត្តិបាចិត្តិយ ។ បណ្តាបទទាំងនោះ បទថា **នាមេតិ** ប្រែថា បង្អោនទៅ ។ [១៦]

សហធម្មិកវគ្គ ទី ៨ ចប់ [១៧]

---

[១៥] ៨. ឧបស្សុតិសិក្ខាបទ ទី ៨ វិ.មហាវិ.ភាគ ៤ ទំព័រ ៣៣៤

[១៦] ១២. បរិណាមនសិក្ខាបទ ទី ១២ វិ. មហាវិ.ភាគ ៤ ទំព័រ ៣៤៩

[១៧] នេះជាសិក្ខាបទដ៏សេស ក្នុងវគ្គនេះ ៖

១. សហធម្មិកសិក្ខាបទ ទី ១ កាលភិក្ខុផងគ្នាពោលពាក្យប្រកបដោយធម៌ ភិក្ខុក៏ថា បើមិនទាន់បានសួរលោកអ្នកចេះដឹងវិនយធរណា មិនរៀនយកទេ ។

វិ. មហាវិ.ភាគ ៤ ទំ. ៣០៦

# រតនវគ្គ ទី ៩

ពីរបទថា **បុច្ឆំ អកត្វា** សេចក្តីថា ភិក្ខុមិនបានលាថា ខ្ញុំប្រាប់លានូវកិរិយាចូលទៅកាន់ស្រុកក្នុងវេលាវិកាល ឬថា ខ្ញុំនឹងចូលទៅកាន់ស្រុក ។ ពាក្យថា **សន្តភិក្ខុំ** សេចក្តីថា ភិក្ខុឃើញភិក្ខុណា ក្នុងឧបចារៈនៃការឃើញក្នុងខាងក្នុងឧបចារសីមា ជាអ្នកអាចដើម្បីប្រាប់ដោយពាក្យជាប្រក្រតីបាន ភិក្ខុមានសភាពដូចនេះ ឈ្មោះថា ភិក្ខុដែលមាននៅ ។ បទថា **គាមស្ស** ប្រែថាកាន់ស្រុក ពាក្យនេះ ជាឆដ្ឋីវិភត្តិចុះក្នុងអត្ថនៃកម្ម ។ បទថា **គតេ** ជាទុតិយាវិភត្តិចុះក្នុងអត្ថនៃសម្បទាន មានរូបជា **គតស្ស** វិញ ។

---

២. វិលេខនសិក្ខាបទ ទី ២ ពេលភិក្ខុកំពុងសម្តែងបាតិមោក្ខ ក៏ពោលបង្អាប់សិក្ខាបទតូចៗ ថា មានប្រយោជន៍អ្វី លើកមកនាំតែក្តៅក្រហាយលំបាក រសេមរសាមចិត្តទេ ។ វិ.មហាវិ.ភាគ ៤ ទំ. ៣១១

៣. មោហនសិក្ខាបទ ទី ៣ ភិក្ខុក្លែងធ្វើពើ មិនដឹងសិក្ខាបទ ថា មានក្នុងព្រះបាលី ជាដើម ។ វិ. មហាវិ.ភាគ ៤ ទំ. ៣១៤

៩. កម្មប្បដិពាហនសិក្ខាបទ ទី ៩ ភិក្ខុឱ្យឆន្ទៈក្នុងកម្មប្រកបដោយធម៌ ហើយត្រឡប់តិះដៀលវិញ ។ វិ. មហាវិ.ភាគ ៤ ទំ. ៣៣៧

១០. ឆន្ទំ អទត្វា គមនសិក្ខាបទ ទី ១០ សង្ឃកំពុងវិនិច្ឆ័យក្តី មិនឱ្យឆន្ទៈស្រាប់តែក្រោកចេញ ។ វិ. មហាវិ.ភាគ ៤ ទំ. ៣៤១

១១. ទព្វសិក្ខាបទ ទី ១១ កាលបើសង្ឃព្រមព្រៀងគ្នាប្រគល់ចីវរ ក៏តិះដៀលជាក្រោយថាធ្វើតាមតែចិត្ត ។ វិ. មហាវិ. ភាគ ៤ ទំ. ៣៤៥

រួមសេចក្តីមកថា សន្តំ ភិក្ខុំ អនាបុច្ឆិត្វា វិកាលេ គាមំ គតស្ស ភិក្ខុនោ បាចិត្តិយំ សិយា អាបត្តិបាចិត្តិយ គប្បីមានដល់ភិក្ខុ កាលមិនប្រាប់លាភិក្ខុដែលមាននៅ ហើយចូលទៅកាន់ស្រុក ក្នុងវេលាវិកាល ។ ពាក្យដ៏សេស មានអត្ថន័យងាយយល់ពិត ហើយដូច្នោះហោង ។[៦៨]

## រតនវគ្គទី៩ ចប់

## ចប់ បាចិត្តិយនិទ្ទេសវណ្ណនា[៦៩]

---

[៦៨] ៣. វិកាលេ គាមប្បវេសនសិក្ខាបទ ទី ៣ វិ. មហាវិ.៤ ទំ. ៣៧៣

[៦៩] នេះជាសិក្ខាបទដ៏សេស ក្នុងវគ្គនេះ ៖

១. អន្តេបុរសិក្ខាបទ ទី ១ ភិក្ខុចូលទៅក្នុងក្រឡាបន្ទំរបស់ស្តេច ។ វិ. មហាវិ.ភាគ ៤ ទំ. ៣៥៤

២. រតនសិក្ខាបទ ទី ២ ភិក្ខុរើសរតនៈ ឬវត្ថុដែលគេសន្មតថា រតនៈ រៀរទុកតែរបស់ដែលគេភ្លេចក្នុងវត្ត ។ វិ. មហាវិ. ភាគ ៤ ទំ. ៣៦៥

៤. សូចិឃរសិក្ខាបទ ទី ៤ ភិក្ខុឱ្យគេធ្វើបំពង់ម្ជុលពីឆ្អឹង ស្នែង ភ្លុក ។ ត្រូវកំទេចចោលសិន ទើបសម្តែងអាបត្តិបាន។ វិ. មហាវិ.ភាគ ៤ ទំ. ៣៨១

៥. មញ្ចសិក្ខាបទ ទី ៥ ភិក្ខុឱ្យគេធ្វើគ្រែមានជើងលើសជាង ៨ ធ្នាប់ព្រះសុគត ។ វិ. មហាវិ.ភាគ ៤ ទំ. ៣៨៥

៦. តូលោនទ្ធសិក្ខាបទ ទី ៦ ភិក្ខុឱ្យគេធ្វើគ្រែ ឬតាំងញាត់ដោយសំឡី ។ វិ. មហាវិ.ភាគ ៤ ទំ. ៣៨៨

៧. និសីទនសិក្ខាបទ ទី ៧ ភិក្ខុឱ្យធ្វើនិសីទនៈលើស បណ្តោយ ២ ចំអាម ទទឹង ១ ចំអាមកន្លះ ដោយចំអាមព្រះសុគត ។ វិ. មហាវិ.ភាគ ៤ ទំ. ៣៩២

---

៨. កណ្ឌុប្បដិច្ឆាទិសិក្ខាបទ ទី ៨ ភិក្ខុឱ្យធ្វើសំពត់គ្របកមលើស បណ្ដោយ ៤ ចំអាម ទទឹង ២ ចំអាម ដោយចំអាមព្រះសុគត ។ វិ. ៤ ទំ. ៣៩៦

៩. វស្សិកសាដិកសិក្ខាបទទី ៩ ភិក្ខុឱ្យគេធ្វើសំពត់វស្សិកសាដក លើសប្រមាណបណ្ដោយ ៦ ចំអាម ទទឹង ២ ចំអាមកន្លះ ដោយចំអាម ព្រះសុគត ។ វិ.មហាវិ.ភាគ ៤ ទំ. ៣៩៩

១០. នន្ទត្ថេរសិក្ខាបទទី ១០ ភិក្ខុឱ្យធ្វើចីវរប៉ុន ឬធំជាងចីវរព្រះសុគត គឺបណ្ដោយ ៩ ចំអាម ទទឹង ៦ ចំអាម ដោយចំអាមព្រះសុគត ។
វិ. មហាវិ.ភាគ ៤ ទំ. ៤០២

**បាដិទេសនីយសិក្ខាបទ ចំនួន ៤, សេខិយៈ ៧៥ និងអធិករណសមថៈ ៧ មិនមានមកក្នុងទីនេះដោយចំពោះទេ ។**

# ៥. បកិណ្ណកនិទ្ទេសវណ្ណនា

៥៣. ឥឡូវនេះ ដើម្បីសម្តែងបកិណ្ណកនិទ្ទេសឡើង លោកអាចារ្យទើបប្រារព្ធនូវពាក្យថា **សង្ឃិកំ** ដូចនេះជាដើម ៖ [៧០]

ក្នុងគាថានេះ មានពាក្យអធិប្បាយថា យោ ភិក្ខុ ឥស្សរោ ហុត្វា សង្ឃិកំ គរុភណ្ឌំ អញ្ញស្ស ទេតិ តស្ស ថុល្លច្ចយំ សិយា ភិក្ខុណា តាំងខ្លួនជាធំឱ្យវត្ថុជាគរុភណ្ឌជារបស់សង្ឃដល់បុគ្គលដទៃ ភិក្ខុនោះ ត្រូវអាបត្តិថុល្លច្ច័យ ។ បើឱ្យដល់អ្នកដទៃដោយចិត្តលួច ត្រូវអាបត្តិបារាជិកជាដើមតាមវត្ថុ គឺវត្ថុទុក្កដ ត្រូវអាបត្តិទុក្កដ វត្ថុថុល្លច្ច័យ ត្រូវអាបត្តិថុល្លច្ច័យ វត្ថុបារាជិក ត្រូវអាបត្តិបារាជិក ។

៥៤. **អាទិ**-សព្ទក្នុងពាក្យថា **កុសាទិមយចីរានិ** លោកអាចារ្យតែងសង្គ្រោះយកសំបកឈើ និងផែនក្តារដែរ គឺថា សំពត់សម្រេចដោយស្បូវភ្លាំង សំពត់សម្រេចដោយសំបកឈើ សំពត់សម្រេចដោយផែនក្តារ ។ បណ្តាសំពត់ទាំង ៣ ប្រភេទនោះ សំពត់ដែលគេក្រងនូវស្បូវភ្លាំងទាំងឡាយ ឈ្មោះថា សំពត់សម្រេចដោយស្បូវភ្លាំង ។ សំបកឈើរបស់តាបសទាំងឡាយ ឈ្មោះថា សំពត់សម្រេចដោយសម្បកឈើ ។

[៧០] វិ. ចុ. ភាគ ១០ ទំព័រ ៣៣៩

សំពត់ដែលគេវែងនូវផែនក្តារ ឈ្មោះថា សំពត់សម្រេចដោយផែនក្តារ ។ ពីរបទថា **កម្ពលំ កេសវាលជំ** សេចក្តីថា សំពត់កម្ពលដែលត្បាញពីសក់ សំពត់កម្ពលដែលត្បាញពីរោមកន្ទុយសត្វ ឈ្មោះថា សំពត់កេសកម្ពល សំពត់វាលកម្ពល អធិប្បាយថា សំពត់ដែលគេត្បាញអំបោះលាយដោយសក់ទាំងឡាយ ឈ្មោះថា កេសកម្ពល ។ សំពត់ដែលគេត្បាញអំបោះលាយដោយរោមកន្ទុយសត្វចាមរីទាំងឡាយ ឈ្មោះថា វាលកម្ពល ។ ពីរបទថា **សមយំ វិនា** គឺលើកទុកតែកាលចីវរខូច ។ បទថា **ធារយតោ** ស្មើនឹង **ធារយន្តស្ស** កាលទ្រទ្រង់ ។ ពាក្យថា **លូកបក្ខាជិនក្ខិបំ** សេចក្តីថា ស្លាបនៃសត្វមៀម និងស្បែកនៃសត្វខ្លា ។ បណ្តាសំពត់ពីរយ៉ាងនោះ សំពត់ដែលធ្វើដោយស្លាបនៃសត្វមៀម ឈ្មោះថា ឱលូបក្ខំ ។ ស្បែកនៃម្រឹគ គឺខ្លារខិនទាំងរោមទាំងក្រចក ឈ្មោះថា អជិនក្ខិប [៩១] ។ សេចក្តីរួមថា ឆដ្ឋចីវរកាលំ ឋបេត្វា ឥមេសុ សត្តសុ វត្ថេសុ យំ កិញ្ចិ ធារយតោ ថុល្លច្ចយំ សិយា អាបត្តិថុល្លច្ច័យ គប្បីមានដល់ភិក្ខុកាលទ្រទ្រង់នូវវត្ថុគឺសំពត់ណាមួយ បណ្តាសំពត់ទាំង ៧ ប្រភេទ លើកទុកតែកាលនៃចីវរខូចបាត់ ។

---

[៩១] វិ. មហាវគ្គ ភាគ ៨ ទំព័រ ១៦៦-៧

៥៥. កម្មដែលគេគប្បីធ្វើដោយកូនកាំបិត ឈ្មោះថា **សត្ថកម្ម** ព្រោះសត្ថកម្មនោះ ។ កម្មដែលគេគប្បីធ្វើត្រង់ក្បាលនៃឫសដូងបាត ឈ្មោះថា **វត្ថិកម្ម** ព្រោះវត្ថិកម្មនោះ ។ [៧២]

ពីរបទថា **សំ និមិត្តំ** បានដល់ អង្គជាតរបស់ខ្លួន ។ សេចក្ដីរួមថា តំ ឆិន្ទតោ ថុល្លច្ចយំ សិយា អាបត្តិថុល្លច្ច័យ គប្បីមានដល់ភិក្ខុកាលកាត់នូវអង្គជាតនោះ ។ [៧៣]

**អាទិ**-សព្ទក្នុងពាក្យថា **មំសាទិភោជនេ** នេះ លោកអាចារ្យតែងសង្គ្រោះយកនូវឆ្អឹង ឈាម ស្បែក និងរោមទាំងឡាយផងដែរ ។ ព្រោះហេតុនោះ អ្នកសិក្សាគប្បីជ្រាបសេចក្ដីរួមថា មនុស្សានំ មំសអដ្ឋិលោហិតចម្មលោមភោជនេ ថុល្លច្ចយំ សិយា អាបត្តិថុល្លច្ច័យ គប្បីមានព្រោះបច្ច័យ គឺការឆាន់សាច់ ឆ្អឹង ឈាម ស្បែក និងរោមរបស់មនុស្សទាំងឡាយ [៧៤]

៥៦. វិនិច្ឆ័យក្នុងពាក្យថា **កទលេរកក្កុស្សានិ** នេះ គប្បីជ្រាបដូចនេះៈ [៧៥]

---

[៧២] វិ. មហាវគ្គ ភាគ ៧ ទំព័រ ២៧២-៣

**សត្ថកម្ម** = កាត់ឫសដូងបាត **វត្ថិកម្ម** = ចងរឹតក្បាលឫសដូងបាត

[៧៣] វិ. ចុ. ភាគ ១០ ទំព័រ ១៤២

[៧៤] វិ. មហាវគ្គ ភាគ ៧ ទំព័រ ២៧៩

[៧៥] វិ.មហាវគ្គ ភាគ ៨ ទំព័រ ១៦៦ - ១៧០ រាប់ចីវរខៀវសុទ្ធជាដើមផង

កទលិឯរកអក្កវាកេហិ កតានិ វត្ថានិ ធារយន្តស្ស ទុក្កដំ ភិក្ខុកាលទ្រទ្រង់នូវសម្ពត់ដែលត្បាញដោយដើមចេក ដើមរៃទឹក និងដើមរាក់ ត្រូវអាបត្តិទុក្កដ ។ សំពត់ដែលគេធ្វើដោយសំបកក្រចៅ ហៅថា **បោត្ថកំ** ។

ដោយ**អាទិ**-សព្ទក្នុងពាក្យថា **សព្វបីតាទិកំ** លោកអាចារ្យតែងសង្គ្រោះយកសម្ពត់ពណ៌ខៀវសុទ្ធ ក្រហមសុទ្ធ ខ្មៅសុទ្ធ និងពណ៌ហង្សបាទសុទ្ធ ។ បណ្តាពណ៌ទាំងនោះ ពណ៌ខៀវទាំងអស់នោះឯង ឈ្មោះថា **សព្វនីលកំ** ។ សូម្បីក្នុងពណ៌ដ៏សេសក៏យ៉ាងនោះដែរ ។ ពណ៌ខៀវ គឺ ខៀវដូចពណ៌នៃផ្កាត្រកៀត ។ ពណ៌លឿង គឺលឿងដូចពណ៌នៃផ្កាកណិការ ។ ពណ៌ក្រហម គឺក្រហមដូចពណ៌នៃផ្កាច្បា ។ ពណ៌ខ្មៅ គឺខ្មៅដូចពណ៌នៃផ្កាផ្គាំ ។ ពណ៌ហង្សបាទ គឺដូចពណ៌កាកល័ក្ត ។ សេចក្តីរួមថា ឥមេសុ អដ្ឋសុ វត្ថេសុ យំ កិញ្ចិ ធារយន្តស្ស ទុក្កដំ សិយា អាបត្តិទុក្កដ គប្បីមានដល់ភិក្ខុកាលទ្រទ្រង់វត្ថុ គឺសំពត់ណាមួយបណ្តាវត្ថុ គឺសំពត់ទាំង ៨ យ៉ាងនេះ ។

៥៧-៥៨. ពាក្យថា **ហត្ថិស្សរគសោណាគំ** បានដល់ សាច់ឆ្អឹង ឈាម ស្បែក និងរោមទាំងឡាយ នៃសត្វដំរី សេះ ពស់ និងឆ្កែស្រុកទាំងឡាយ ។ ពាក្យថា **សីហព្យគ្ឃច្ឆទីបិនំ** គឺសាច់ជាដើមនៃសត្វសីហៈ ខ្លាធំ ខ្លាឃ្មុំ និងខ្លាដំបងទាំងឡាយ ។

តរប្ឆស្ស ប មំសាទី ឧទ្ទិស្សកតមំសញ្ច អនាបុច្ឆិតមំសញ្ច ភុញ្ជតោ ទុក្កដំ សិយា ភិក្ខុឆាន់នូវសរីរាង្គមានសាច់ជាដើមនៃខ្លារខិនក្តី ឆាន់សាច់ដែលគេធ្វើចំពោះខ្លួនក្តី ឆាន់សាច់ដែលខ្លួនមិនបានសាកសួរក្តី ត្រូវអាបត្តិទុក្កដ ។[៧៦]

**អាទិ**-សព្ទក្នុងពាក្យថា **ទកតិត្ថាទិកំ** ជាដើម លោកអាចារ្យតែងសង្គ្រោះយកវច្ចកុដិ និងបស្សាវកុដិដែរ ។ ព្រោះហេតុនោះ អ្នកសិក្សាគប្បីជ្រាបសេចក្តីថា ភិក្ខុលះបង់ គឺ វៀរបង់នូវលំដាប់ភិក្ខុដែលទៅមុន គឺលំដាប់នៃភិក្ខុដែលមកដល់ហើយ **វជេ** គប្បីវៀរ គឺថា ភិក្ខុណា ទៅកាន់កំពង់ទឹកក្តី វច្ចកុដិក្តី បស្សាវកុដិក្តី ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ ។[៧៧]

៥៩. បទថា **សហសា** ស្មើនឹង វេគសា វេគេន ប្រែថា ដោយរហ័ស ។ ពាក្យថា **វុត្តជិត្វាន** គឺ លើកស្បង់បោះទៅឆ្ងាយមែនពិត, វ អក្សរ មានមកដោយអំណាចសន្ធិ ។ បទថា **បវិសេ** ប្រែថា គប្បីចូលទៅ ។ វច្ចកុដិ និងបស្សាវកុដិ ឈ្មោះថា **វច្ចបស្សាវកុដិ** ។ បទថា **វិសេ** ប្រែថា គប្បីចូលទៅ ។

---

[៧៦] វិ. មហាវគ្គ ភាគ ៧ ទំព័រ ២៧៩ ដល់ ២៨៤ អំពីសាច់ ៩ យ៉ាង ។ មិនពិចារណាឆាន់សាច់ និងសាច់ចំពោះ នៅ ទំព័រ ៣៣៧

[៧៧] វិ. ចុ. ភាគ ១១ ទំព័រ ១៣២ ដល់ ១៣៥ រាប់ដល់បន្ទោបង់ព្ធផ្លាច់ៗ

គប្បីយោជនាដូចនេះ ៖ យោ ភិក្ខុ វច្ចបស្សាវកុដិកំ សហសា បវិសេយ្យ វា និក្ខមេយ្យ វា ឧក្កាសិត្វា វា បវិសេយ្យ វា និក្ខមេយ្យ វា ឧក្កាសិកំ វជ្ជេត្វា តំ បវិសេយ្យ តស្ស ទុក្កដំ សិយា ភិក្ខុណា ចូលទៅក្តី ចេញមកក្តី ដោយរហ័សកាន់វច្ចកុដិ និងបស្សាវកុដិ ឬក៏បោះស្បង់ទៅហើយ គប្បីចូលទៅចេញមកក្តី មិនក្អកគ្រហែមចូលទៅវច្ចកុដិ និងបស្សាវកុដិនោះក្តី ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។

៦០. និត្ថុនន្តោ វច្ចំ ករេយ្យ ទន្តកដ្ឋញ្ច ខាទន្តោ តស្ស ទុក្កដំ សិយា ភិក្ខុកាលប្រឹងរមាត់ និងកំពុងទំពាឈើស្ទន់ បន្ទោបង់វច្ចៈ ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ ។ វច្ចបស្សាវទោណិនំ ពហិ វច្ចាទិកំ វច្ចបស្សាវំ ករេយ្យ តស្ស ទុក្កដំ សិយា ភិក្ខុបន្ទោបង់វច្ចៈ និងបស្សាវៈ ឱ្យវច្ចៈជាដើមធ្លាក់ចេញក្រៅទវច្ចៈ ឬបស្សាវៈ ត្រូវអាបត្តិទុក្កដ ។

៦១. បាទគាថាថា **ខរេន បរិលេខេយ្យ** សេចក្តីថា គប្បីកិតដោយចំណាំងឈើ ដែលបែកហើយក្តី ដោយពួថៅក្តី ដោយផ្ទាំងឈើក្តី ដោយដើមស្រល់ក្តី ដោយដើមឈើមានប្រហោងក្តី ។ បទថា **កដ្ឋំ** គឺកំណាត់ឈើសម្រាប់កិត ។ បទថា **កូបកេ** គឺ រណ្តៅនៃវច្ចៈ ។ បទថា **ឧហាតញ្ច** គឺ ប្រឡាក់

ហើយដោយគូថ ។ ពាក្យថា **ន ធោវេយ្យ** សេចក្ដីថា ភិក្ខុមិនលាងដោយខ្លួនឯងក្ដី មិនប្រើគេឱ្យលាងក្ដី ។ ពាក្យថា **ឱក្លាបញ្ច សំបុកពីងពាង** គឺ សម្រាម ។ ពាក្យថា **ន សោធយេន** គឺមិនបោសជម្រះ ។

៦២. **បបុបបូ**តិ សទ្ទំ កត្វា ឧទកកិច្ចំ ករោន្តស្ស អាបមន្តស្ស ទុក្កដំ សិយា ភិក្ខុកាលធ្វើឧទកកិច្ចលាងជម្រះ ក៏ធ្វើឱ្យឮសម្លេងថា ចបុ ចបុ (ផ្លាច់ៗ) ដូច្នេះ ត្រូវអាបត្តិទុក្កដ ។

ពាក្យថា **អនជ្ឈិដ្ឋោវ** គឺ មិនបានអារាធនាទាល់តែសោះ ពាក្យថា **ថេរេន** គឺ ភិក្ខុជាថេរៈក្នុងសង្ឃ ។ បាតិមោក្ខុទ្ទេស ឈ្មោះថា **បាតិមោក្ខ** ។ **ឧទ្ទេសេ** គឺ គប្បីសម្ដែងឡើង, ត្រូវអាបត្តិទុក្កដ ។ [៧៨]

៦៣. បាទគាថាថា អនាបុច្ឆាយ បញ្ហស្ស កថនេ សេចក្ដីថា ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ ព្រោះហេតុ ៤ យ៉ាងនេះគឺ ៖

អនាបុច្ឆាយ បញ្ហស្ស វិស្សជ្ជនេ មិនសុំឱកាសដោះស្រាយនូវបញ្ហា ១ អនាបុច្ឆាយ សជ្ឈាយករណោ មិនសុំឱកាសធ្វើការស្វាធ្យាយ ១ អនាបុច្ឆាយ បទីបជាលនេ មិនសុំឱកាស

[៧៨] វិ.មហាវគ្គ ភាគ ៦ ទំព័រ ៣៧៥

អុជប្រទីប ១ អនាបុច្ឆាយ បទីបវិជ្ឈាបនេ មិនសុំឱកាសពន្លត់ប្រទីប ១ ។

៦៤. សម្ពន្ធថា អនាបុច្ឆា វាតបានកវាដានិ វិវរេយ្យ វា ថកេយ្យ វា តស្ស ទុក្កដំ សិយា ភិក្ខុមិនបានសុំឱកាស (មិនបានប្រាប់) គប្បីបើកក្តី បិទក្តី នូវទ្វារ និងបង្អួច ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។

**អាទិ**-សព្ទក្នុងពាក្យថា **វន្ទនាទី** [៧៩] នេះ លោកអាចារ្យតែងសង្គ្រោះយកការបង្គាប់ឱ្យគេថ្វាយបង្គំខ្លួនចូលផង ។

សេចក្តីសម្ពន្ធជាប្រយោគដូច្នេះ៖ យោ ភិក្ខុ នគ្គោ វន្ទនំ ករេយ្យ វន្ទាបនំ ករេយ្យ គមនំ ករេយ្យ ភោជនំ ករេយ្យ បិវនំ ករេយ្យ ខាទនំ ករេយ្យ គហណំ ករេយ្យ ទានំ ករេយ្យ តស្ស សព្វត្ថ ទុក្កដំ ភិក្ខុណា ជាអ្នកអាក្រាតកាយ ធ្វើការថ្វាយបង្គំក្តី ឱ្យគេថ្វាយបង្គំក្តី ធ្វើដំណើរទៅ(កាន់ស្រុក)ក្តី ធ្វើការបរិភោគ (ឆាន់ចង្ហាន់)ក្តី ផឹកក្តី ទំពាឆាន់(ផ្លែឈើជាដើម)ក្តី ធ្វើទទួលក្តី ឱ្យក្តី ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ ក្នុងទីទាំងពួង ។

៦៥. ពីរបទថា **តិបដិច្ឆន្នកំ វិនា** គឺ លោកអាចារ្យបានលើកយកគ្រឿងបិទបាំងទាំង ៣ ប្រការ ដែលព្រះមានព្រះភាគ

[៧៩] វិ. ចុ. ភាគ ១០ ទំព័រ ១៧៦-៧

ទ្រង់អនុញ្ញាតទុកយ៉ាងនេះថា អនុជានាមិ ភិក្ខវេ តិស្សោ បដិច្ឆាទិយោ ជន្តាឃរបដិច្ឆាទឹ ឧទកបដិច្ឆាទឹ វត្ថបដិច្ឆាទឹ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតគ្រឿងបិទបាំង ៣ យ៉ាង គឺ បិទបាំងដោយរោងភ្លើង បិទបាំងដោយទឹក បិទបាំងដោយសំពត់ ដូច្នេះ ហើយក៏ពោលថា គ្រឿងបិទបាំង ៣ យ៉ាង ដូច្នេះ ។ អធិប្បាយថា តិបដិច្ឆន្នកំ ឋបេត្វា បរិកម្មំ សយំ ករេយ្យ បរំ ការាបេយ្យ តស្ស ទុក្កដំ សិយា វៀរតែគ្រឿងបិទបាំង ៣ យ៉ាង ចេញ ភិក្ខុធ្វើបរិកម្មដោយខ្លួនឯងក្តី ប្រើគេឱ្យធ្វើក្តី ត្រូវអាបត្តិទុក្កដ ។ [៩០]

បទថា **ឧបាឃំ** សេចក្តីថា យោ ភិក្ខុ ឧហាយន្តោ កុដ្តេ វា ថម្ភេ វា តរុម្ហិ វា កាយំ ឧបឃំសេយ្យ តស្ស ទុក្កដំ សិយា ភិក្ខុណា កាលងូតទឹកត្រដុសកាយនឹងជញ្ជាំងក្តី សសរក្តី ដើមឈើក្តី ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ ។

៦៦. យោ ភិក្ខុ ឧហាយន្តោ កុរុវិន្ទកសុត្តេន កាយំ ឃំសេយ្យ **កាយតោ** កាយេន អញ្ញមញ្ញំ ឃំសេយ្យ តស្ស ទុក្កដំ សិយា ភិក្ខុណាមួយ ងូតទឹកត្រដុសកាយដោយឈើ ឈ្មោះ

---

[៩០] វិ. ចុ. ភាគ ១០ ទំព័រ ១៧៨

កុរុវិន្ទកៈ និងដុំអំបោះក្តី ត្រដុសគ្នានិងគ្នាដោយកាយក្តី ត្រូវអាបត្តិទុក្កដ ។ [៩១]

យោ អគិលានោ សឧបាហនោ **ពហារាមេ** ពហិអារាមេ បវេយ្យ តស្ស ទុក្កដំ សិយា ភិក្ខុណាមួយ មិនមានជម្ងឺទេ ពាក់ស្បែកជើងដើរទៅខាងក្រៅអារាម ត្រូវអាបត្តិទុក្កដ ។

៦៧. **អាទិ**-សព្ទក្នុងពាក្យថា **សព្វនីលាទិកម្បិ ប** នេះ លោកអាចារ្យតែងសង្គ្រោះយកនូវស្បែកជើងទាំងឡាយ មានស្បែកជើងមានពណ៌ក្រហម ស លឿង ខ្មៅ ហង្សបាទ លឿងទុំ និងក្រហមក្រមៅជាដើមផង ។ សម្ពន្ធដូចនេះ ៖ យោ ភិក្ខុ សព្វនីលសព្វលោហិតាទិកំ ឧបាហនំ ធារេតិ តស្ស ទុក្កដំ សិយា ភិក្ខុណាមួយ ពាក់នូវស្បែកជើងមានពណ៌ខៀវសុទ្ធ និងពណ៌ក្រហមសុទ្ធជាដើម ត្រូវអាបត្តិទុក្កដ ។ [៩២]

យោ ភិក្ខុ **រត្តោ** រត្តចិត្តោ តទហុជាតាយបិ ឥត្ថិយា និមិត្តំ បស្សេយ្យ តស្ស ទុក្កដំ សិយា ភិក្ខុណាមួយ មានចិត្តតម្រេកសម្លឹងមើលនិមិត្តរបស់ស្ត្រី សូម្បីកើតក្នុងថ្ងៃនោះ ត្រូវអាបត្តិទុក្កដ ។ [៩៣]

---

[៩១] វិ. ចុ. ភាគ ១០ ទំព័រ ១២៣ ដល់ ១២៧ រាប់ពីត្រដុសនឹងជញ្ជាំងមក

[៩២] វិ. មហាវគ្គ ភាគ ៧ ទំព័រ ១៧៥

[៩៣] វិ ២ភាគ .មហាវិ .ទំព័រ ៤៧

យោ ភិក្ខុ **ភិក្ខុទាយិយា** ភិក្ខុទាយិកាយ ឥត្ថិយា មុខំ បស្សេយ្យ តស្ស ទុក្កដំ សិយា ភិក្ខុណាមួយ សម្លឹងមើលមុខរបស់ទាយក ទាយិកា (បុរស ស្ត្រី) ដែលកំពុងប្រគេនភិក្ខា (ចង្ហាន់) ត្រូវអាបត្តិទុក្កដ ។ [៩៤]

៦៨-៦៩. យោ ភិក្ខុ ឧជ្ឈានសញ្ញី ហុត្វា **អញ្ញស្ស** ភិក្ខុនោ បត្តំ វា បស្សេយ្យ តស្ស ទុក្កដំ សិយា ភិក្ខុណាមួយ ជាអ្នកប្រាថ្នាដើម្បីលើកទោស ហើយសំឡឹងមើលបាត្ររបស់ភិក្ខុដទៃ ត្រូវអាបត្តិទុក្កដ ។ [៩៥]

អាទាសាទិម្හි ឧទកបត្តេ អត្តនោ មុខំ បស្សេយ្យ តស្ស ទុក្កដំ សិយា ភិក្ខុណាមួយ សម្លឹងមើលមុខរបស់ខ្លួនក្នុងគ្រឿងឆ្លុះមានកញ្ចក់ជាដើម ឬក្នុងភាជន៍ទឹក ត្រូវអាបត្តិទុក្កដ ។ [៩៦]

ឧច្ចាសនមហាសនេ **និសជ្ជាទឹ** និសីទនសយនាទឹ ករោន្តស្ស ភិក្ខុនោ ទុក្កដំ សិយា ភិក្ខុធ្វើកិច្ចមានអង្គុយ និងដេកជាដើម លើអាសនៈដ៏ខ្ពស់ហួសប្រមាណ និងអាសនៈដ៏ប្រសើរ ត្រូវអាបត្តិទុក្កដ ។ [៩៧]

---

[៩៤] វិ. ចុ. ភាគ ១១ ទំព័រ ១១៧ និង ១២២

[៩៥] វិ. មហាវិ. ភាគ ៤ ទំព័រ ៤៦២ (សិក្ខាបទនេះ មានក្នុងសេខិយ ៧៥ ហើយ)

[៩៦] វិ. ចុ. ភាគ ១០ ទំព័រ ២៧២

[៩៧] វិ. ចុ. ភាគ ១០ ទំព័រ ២៧២ និង ៣១៨ វិ.មហាវគ្គ ភាគ ៧ ទំព័រ ១៩៦

ឧក្ខិត្តានុបសម្បន្ននានាសំវាសកាទីនំ វន្ទនេបិ ទុក្កដំ សិយា សូម្បីព្រោះហេតុតែការថ្វាយបង្គំចំពោះភិក្ខុដែលសង្ឃលើកវត្ត និងភិក្ខុមានសង្វាសផ្សេងគ្នាជាដើម ក៏ត្រូវអាបត្តិទុក្កដដែរ ។ បណ្ដាបទទាំងនោះ បទថា **ឧក្ខិត្តោ** បានដល់ ភិក្ខុដែលសង្ឃលើកវត្ត ៣ ពួក ដែលលោកប្រាថ្នាយកក្នុងទីនេះ គឺៈ [៩៨]

អាបត្តិយា អទស្សនេ ឧក្ខិត្តកោ ភិក្ខុដែលសង្ឃលើកវត្ត ព្រោះមិនឃើញអាបត្តិ ១ អាបត្តិយា អប្បដិកម្មេ ឧក្ខិត្តកោ ភិក្ខុដែលសង្ឃលើកវត្ត ព្រោះមិនសម្ដែងអាបត្តិ ១ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខិត្តកោ ភិក្ខុដែលសង្ឃលើកវត្ត ព្រោះមិនលះបង់ទិដ្ឋិដ៏លាមកចោល ១ ។ ដោយពាក្យថា **អនុបសម្បន្នោ** នេះ លោកអាចារ្យសំដៅយកទាំងភិក្ខុនី សាមណេរ សាមណេរី សិក្ខមានា ខ្ទើយ ស្ត្រី និងបព្វជិតដែលពោលលាសិក្ខាហើយផង ។ ពាក្យថា **នានាសំវាសកោ** គឺលោករាប់យកបុគ្គលដែលមានសំវាសផ្សេងគ្នា គឺ លទ្ធិ ។ បុគ្គលដែលមានមូលដាច់ហើយ (ភិក្ខុត្រូវអាបត្តិបារាជិក) ក៏លោករាប់ចូលហើយដោយ**អាទិ**-សព្ទដែរ ។

---

[៩៨] វិ. ចុ. ភាគ ១០ ទំព័រ ៣១៤ អវន្ទិយបុគ្គល ១០ ពួក និងវន្ទិយបុគ្គល ៣ ពួក

៧០-៧១. យោ ទីឃាសនេ **បណ្ឌកិត្ថីហិ** បណ្ឌកេន វា ឥត្ថិយា វា ឧភតោព្យញ្ជនេន វា ឯកតោ និសីទេយ្យ តស្ស ទុក្កដំ សិយា ភិក្ខុណា អង្គុយលើអាសនៈវែងតែមួយជាមួយនឹងមនុស្សខ្ទើយក្តី ស្ត្រីក្តី ឧភតោព្យញ្ជនៈ(បុគ្គលមានភេទពីរ)ក្តី ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ។ ពីរបទថា **អទីឃេ អាសនេ** គឺ លើអាសនៈខ្លី ។

យោ ភិក្ខុ វស្សាសនេ មញ្ចេ វា បីឋេ វា អសមានាសនិកេន ឯកតោ សយេយ្យ តស្ស ទុក្កដំ សិយា ភិក្ខុណាមួយ ដេកលើអាសនៈខ្លី គឺ គ្រែក្តី តាំងក្តី តែមួយជាមួយនឹងភិក្ខុដែលមានអាសនៈមិនស្មើគ្នា ត្រូវអាបត្តិទុក្កដ ។[៤៩]

ដោយ**អាទិ**-សព្ទក្នុងពាក្យថា **ផលបុប្ផាទិកំ** នេះ លោកអាចារ្យតែងសង្គ្រោះយកវត្ថុទាំងឡាយ មានឫស្សី លំអិតឈើស្ងួន់ (ច្រាសនិងថ្នាំដុសធ្មេញ) និងដីស្អិតជាដើមផង ។ ភ្ជាប់សេចក្តីថា កុលសង្គហត្ថាយ ផលបុប្ផាទិកំ ទទតោ ទុក្កដំ សិយា ភិក្ខុឱ្យនូវវត្ថុមានផ្លែឈើ និងផ្កាឈើជាដើម ដើម្បីសង្គ្រោះត្រកូល ត្រូវអាបត្តិទុក្កដ ។[៥០]

៧២-៧៣. វិនិច្ឆ័យក្នុងគាថាទី ៧២ និង ៧៣ អ្នកសិក្សាគប្បីជ្រាបសម្ពន្ធដូចនេះ ៖

---

[៤៩] វិ. ចុ. ភាគ ១០ ទំព័រ ៣៣៦

[៥០] មានក្នុងកុលទូសកសិក្ខាបទ

យោ ភិក្ខុ គន្ថិមាទី សយំ ករេយ្យ បរំ ការាបេយ្យ តស្ស ទុក្កដំ សិយា ភិក្ខុណា ធ្វើនូវកិច្ចមានការក្រងផ្កាជាដើម ដោយខ្លួនឯងក្តី ប្រើគេឱ្យធ្វើក្តី ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ ។[៦១]

យោ ភិក្ខុ ជិនេន វារិតបច្ចយេ បរិភុញ្ជេយ្យ តស្ស[៦២] ទុក្កដំ សិយា ភិក្ខុណា បរិភោគប្រើប្រាស់នូវបច្ច័យទាំងឡាយ ដែលព្រះជិនស្រីទ្រង់ហាមហើយ ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ ។

**អព្យត្តោ** ពាលោ យោ ភិក្ខុ អាចរិយុបជ្ឈាយេ **អនិស្សាយ** និស្សយំ អគ្គហេត្វា វសេយ្យ តស្ស ទុក្កដំ សិយា ភិក្ខុណា ជាអ្នកមិនឈ្លាស ជាបុគ្គលល្ងង់ មិនអាស្រ័យអាចារ្យ និងឧបជ្ឈាយ៍ ហើយនៅទាំងមិនកាន់និស្ស័យ ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ ។

យោ ភិក្ខុ **អនុញ្ញាតេហិ** មាតាបិតុអាទីហិ បុគ្គលេហិ **អញ្ញស្ស** បុគ្គលស្ស ភេសជ្ជំ ករេយ្យ វា វទេយ្យ វា តស្ស ទុក្កដំ សិយា ភិក្ខុណាមួយ ធ្វើក្តី ប្រាប់ក្តី នូវថ្នាំចំពោះបុគ្គលដទៃ ក្រៅពីបុគ្គលដែលព្រះដ៏មានព្រះភាគ ទ្រង់អនុញ្ញាតហើយមានមាតាបិតា ជាដើម ត្រូវអាបត្តិទុក្កដ ។

---

[៦១] កុលទូសកសិក្ខាបទ និងខាងចុងនៃខុទ្ទកវត្ថុខន្ធកៈ

[៦២] បច្ច័យដែលស្វែងរកដោយមិនត្រឹមត្រូវ

សាបត្តិកោ យោ ភិក្ខុ ឱបោសថប្បវារណំ ករេយ្យ តស្ស ទុក្កដំ សិយា ភិក្ខុមានអាបត្តិជាប់ខ្លួន មិនគួរធ្វើឧបោសថ ឬបវារណាទេ ភិក្ខុណាធ្វើ ត្រូវអាបត្តិទុក្កដ ។[៩៣]

បណ្ដាបទទាំងនោះ សេចក្ដីវិនិច្ឆ័យគប្បីជ្រាបដូច្នេះ ៖

ព្រះជិនស្រីដ៏មានព្រះភាគទ្រង់ហាមហើយ ឈ្មោះថា ជិនវារិតា, ជិនវារិតា ផង បច្ច័យទាំងឡាយនោះផង ទើបឈ្មោះថា **ជិនវារិតប្បច្ចយា** ព្រោះបច្ច័យដែលព្រះជិនស្រីដ៏មានព្រះភាគទ្រង់ហាមហើយនោះ ។ ឈ្មោះថា ជាអ្នកមិនឈ្លាស **អព្យត្តោ** ព្រោះជាអ្នកមានមាតិកាទាំងពីរស្ទាត់ដោយតិចតួច ។

៧៤. យោ ភិក្ខុ អាភោគំ វា និយោគំ វា វជ្ជេត្វា ទ្វារពន្ធាទិកេ ឋានេ បរិវត្តកវាដកំ អបិធាយ ទិវា សយេយ្យ តស្ស ទុក្កដំ សិយា ភិក្ខុណាមួយ ប្រាសចាកអាភោគចិត្ត ឬទីមិនមែនជាទីនៅរបស់ខ្លួនមិនបានបិទនូវសន្ទះទ្វារដែលគួរបង្វិលបានក្នុងទីដែលមានទីប្រកបទ្វារមានទ្វារពន្ធជាដើម (រោងមានទ្វារ) ហើយដេកក្នុងវេលាថ្ងៃ ត្រូវអាបត្តិទុក្កដ។[៩៤] បទថា **ទ្វារពន្ធាទិកេ** សេចក្ដីថា សូម្បីនៅទីលានល្ហល្ហេវដែលមានចងបិទបាំងទុកមាន

[៩៣] វិ. មហាវគ្គ. ភាគ ៧ ទំព័រ ១២៥ បវារណា

[៩៤] វិ. មហាវិ.ភាគ ១ ទំព័រ ១២៨

ទ្វារ ដោយលក្ខណៈនេះ ដោយហោចទៅសូម្បីទីវាល និងត្រង់គល់ឈើដែលគេបិទបាំងណាមួយក៏ដោយ ។ បទថា **អបិធាយ** ប្រែថា មិនបានបិទហើយ ។ បទថា **វិគាភោគំ** សេចក្ដីថា ប្រាសចាកអាភោគចិត្តដូច្នេះថា ទ្វារនុ៎ះគត់មត់ហើយ ។ បទថា **និយោគំ** ប្រែថា ទីមិនមែនជាទីនៅ គឺថា មិនមែនជាទីនៅរបស់ខ្លួន សេចក្ដីងាយយល់ថា វៀរលែងតែទីសាធារណៈទួទៅ ។ ម្យ៉ាងបាលីថា **សវសោ** វិញក៏មាន ដែលមានសេចក្ដីថា ជាទីនៅ (របស់ខ្លួន) ។ បទថា **ទិវា** ប្រែថា ពេលថ្ងៃ ។

៧៥. បទថា **ធញ្ញំ** បានដល់ ធញ្ញជាតិ (ស្រូវ) ៧ ប្រភេទ គឺ ៖

១. **សាលី** ស្រូវសាលី
២. **វីហិ** ស្រូវខ្សាយ
៣. **យវោ** ស្រូវដំណើប
៤. **គោធុមោ** ស្រងែ
៥. **កង្គុ** ថ្កោ ឬប្រយង្គុ
៦. **វរកោ** ស្រូវស្គួយ ឬពោតក៏ប្រែ
៧. **កុទ្រូសកោ** ស្រូវគែលលក ឬស្មៅគែលលក

បទថា **ឥត្ថិរូបំ** បានដល់ រូបស្រីដែលគេធ្វើដោយឈើ ឬស្ពាន់ជាដើម ។ បទថា **រតនំ** បានដល់ រតនៈ ១០ ប្រការ មានកែវមុក្តាជាដើម ។ បទថា **អាវុធំ** បានដល់ គ្រឿងសព្វាវុធ គ្រប់យ៉ាងមានកាំបិត លំពែងជាដើម ។ បទថា **ឥត្ថិបសាធនំ** បានដល់ គ្រឿងលម្អគ្រប់យ៉ាងមានអលង្ការសម្រាប់លម្អក្បាល ជាដើមរបស់មនុស្សស្រី ។ បទថា **តូរិយភណ្ឌំ** បានដល់ គ្រឿងតូរ្យតន្ត្រីគ្រប់យ៉ាងមានខ្លុយ និងស័ង្ខជាដើម ។ បទថា **ផលរុក្ខ** សំដៅដល់ឈើដែលមានផ្លែ ។ បទថា **បុព្វណ្ណាទិកំ** បានដល់ បុព្វណ្ណជាតិមានសណ្តែកខៀវ និងសណ្តែករាជមាសជាដើម ។ គ្រឿងចាប់សត្វទាំងឡាយ មានសំណាញ់ និងលបជាដើម ក៏លោករាប់ចូលដែរដោយ**អាទិ**-សព្ទ ។ រួមសេចក្តីថា ឯតេសុ យំ កិញ្ចិ អាមសេយ្យ តស្ស ទុក្កដំ សិយា ភិក្ខុណាមួយ ប៉ះពាល់នូវបណ្តាវត្ថុទាំងឡាយដូចដែលបានរៀបរាប់មកហើយនុ៎ះ ណាមួយ ត្រូវអាបត្តិទុក្កដ ។[៩៥]

៧៦. បាទគាថាថា **សសិត្ថោទកតេលេហិ** សេចក្តីថា ភិក្ខុណាមួយ សិតសក់ដោយប្រេងស្រគំឬក្រមួនក្តី ដោយប្រេង

[៩៥] សូមអានកាយសំសគ្គសិក្ខាបទ វិ.មហាវិ. ភាគ ២ ទំព័រ ៨២ និងអដ្ឋកថា ចុះ ។ តូរ្យតន្ត្រី វចនានុក្រម ជា តូយ៍តន្ត្រី

លាយទឹកក្ដី ឬដោយគ្រឿងរំអិលណាមួយក្ដី ។ បាទគាថាថា **ផណាហត្ថផលោហិ វា** សេចក្ដីថា ព្រោះភិក្ខុសិតសក់ដោយក្រាសមានក្រាសធ្វើអំពីភ្លុកជាដើមក្ដី ជ្រងសក់ដោយម្រាមដៃឱ្យសក់រៀបស្អាតជំនួសក្រាសក្ដី សិតសក់ដោយស្និតក្ដី ត្រូវអាបត្តិទុក្កដ ។[៩៦]

ឯកស្មឹ ភាជនេ ភោជននិមិត្តេ ទុក្កដំ សិយា ព្រោះតែភិក្ខុឆាន់ក្នុងភាជនៈតែមួយជាមួយគ្នា ត្រូវអាបត្តិទុក្កដ ។

៧៧. គប្បីសម្គន្ធយ៉ាងនេះ៖

ទ្វេ ភិក្ខូ ឯកត្ថរណា សយេយ្យុំ ទ្វេ ភិក្ខូ ឯកបាវុរណា សយេយ្យុំ ទ្វេ ភិក្ខូ ឯកមញ្ចកេ សយេយ្យុំ តេសំ ទុក្កដាតិ ហោន្តិ ភិក្ខុពីរអង្គសិងលើកម្រាលជាមួយគ្នា ភិក្ខុពីរអង្គសិងដណ្ដប់ជាមួយគ្នា ភិក្ខុពីរអង្គសិងលើគ្រែជាមួយគ្នា ភិក្ខុទាំងនោះត្រូវអាបត្តិទុក្កដ ។[៩៧]

បមាណតោ អធិកំ វា ឩនំ វា ទន្តកដ្ឋំ ខាទេយ្យ តស្ស ទុក្កដំ សិយា ភិក្ខុទំពាឈើស្ទន់ដែលលើស ឬខ្វះជាងប្រមាណ ត្រូវអាបត្តិទុក្កដ ។[៩៨]

---

[៩៦] វិ. ចុ.ភាគ ១០ ទំព័រ ១៣១

[៩៧] វិ. ចុ. ភាគ ១០ ទំព័រ ១៨៥ (ឯកភាជនសិក្ខាបទផង)

[៩៨] វិ. ចុ. ភាគ ១០ ទំព័រ ២២៧-៨

បណ្ដាបទទាំងនោះ បទថា **អធិកំ** គឺវែងជាង ៨ធ្នាប់ ។ បទថា **ឱមកំ** គឺខ្លីជាង ៤ធ្នាប់។

៧៨. យោ ភិក្ខុ នច្ចញ្ច គីតញ្ច វាទិតញ្ច យោជេតិ វា យោជាបេតិ វា តស្ស ទុក្កដំ សិយា ភិក្ខុណាមួយ ប្រកបខ្លួនឯងក្ដី ប្រើគេឱ្យប្រកបក្ដី នូវកិរិយារាំ ច្រៀង និងប្រគំ ត្រូវអាបត្តិទុក្កដ ។ អធិប្បាយថា ភិក្ខុកាលមើលនូវការរាំរបស់អ្នករបាំទាំងឡាយនោះ ច្រៀង ឬស្ដាប់នូវចម្រៀងនៃអ្នកចម្រៀងទាំងឡាយនោះ និងស្ដាប់នូវការប្រគំរបស់ពួកតន្ត្រីករ ត្រូវអាបត្តិទុក្កដ ។[៩៩]

៧៩. ពាក្យថា **វីហាទិរោបិមេ** បានដល់ ទីជាទីដុះឡើង នៃធញ្ញជាតិ បុព្វណ្ណជាតិ និងតិណជាតិទាំងឡាយមានស្រូវជាដើម។ ពាក្យថា **ពហិបាការកុដ្ដកេ** គឺខាងក្រៅនៃកំពែងរបង ឬជញ្ជាំង។ ពាក្យថា **វច្ចាទិឆឌ្ឌាទិម្ហិ** សេចក្ដីថា វច្ចបស្សាវសង្ការបលកាទីនំ ឆឌ្ឌនវិស្សជ្ជនបច្ចយា ទុក្កដំ សិយា ព្រោះបច្ច័យគឺការបោះ ឬជះចោលនូវវច្ចះ (លាមក) បស្សាវះ (ទឹកនោម) សម្រាម និងកាកសំណល់ផ្សេង ៗ ជាដើម ត្រូវអាបត្តិទុក្កដ ។[១០០]

[៩៩] វិ. ចុ. ភាគ ១០ ទំព័រ ១៣៤

[១០០] វិ. ចុ. ភាគ ១០ ទំព័រ ២៣៥

ពាក្យថា **ទីឃកេសាទិធារណោ** សេចក្ដីថា ទីឃកេស-ធារណោ ទីឃនខធារណោ ទុក្កដំ សិយា ព្រោះកិរិយាទុកសក់វែង ព្រោះកិរិយាទុកក្រចកវែង ភិក្ខុត្រូវអាបត្តិទុក្កដ ។ [១០១]

៨០. ការលាបថ្នាំក្រចក គឺលោករាប់ចូលហើយដោយ **អាទិ**-សព្ទ ក្នុងពាក្យថា **នខមដ្ឋករណាទិម្ហិ** នេះ ។ ពីរបទថា **សម្ពាធេ លោមហារណោ** បានដល់ ការដករោមក្នុងទីចង្អៀត គឺត្រង់ប្រអប់ក្លៀក និងទីបន្ទោបង់ទឹកមូត្រ ។ [១០២]

សឧបាហនោ ភិក្ខុ បរិកម្មកតំ ភូមឹ អក្កមេយ្យ ភិក្ខុពាក់ស្បែកជើង មិនត្រូវដើរជាន់ទីដីដែលគេធ្វើបរិកម្មទេ ។ [១០៣]

៨១. ពាក្យថា **អធោតអល្លបាទេហិ** សេចក្ដីថា យោ ភិក្ខុ អធោតបាទេហិ វា អល្លបាទេហិ វា សង្ឃិកំ មញ្ចំ វា បីឋំ វា អក្កមេយ្យ បរិកម្មកតំ ភិត្តឹ វា កាយតោ អាមសន្តស្ស ទុក្កដំ សិយា ភិក្ខុណា ដើរជាន់នូវគ្រែក្ដី តាំងក្ដី ដែលជារបស់សង្ឃ

---

[១០១] វិ. ចុ. ភាគ ១០ ទំព័រ ១៣១ (ទុកសក់វែង) វិ.ចុ.ភាគ ១០ ទំព័រ ២១៤-៥ (ទុកក្រចកវែង)

[១០២] វិ. ចុ. ភាគ ១០ ទំព័រ ២១៦

[១០៣] វិ. មហាវគ្គ ភាគ ៧ ទំព័រ ២០៣

ដោយជើងដែលឥតបានលាងក្តី ដោយជើងដែលទទឹកសើមក្តី ឬក៏ផ្អែកជញ្ជាំងដែលគេបរិកម្មហើយក្តី ត្រូវអាបត្តិទុក្កដ ។ [១០៤]

៨២-៨៣. ពីរបទថា **សង្ឃាដិយាបិ បល្លកេ** សេចក្តីថា ភិក្ខុត្របោមក្បាលជង្គង់ក្នុងវិហារ(វត្ត)ក្តី ក្នុងចន្លោះស្រុកក្តី ដោយចីវរដែលបានអធិដ្ឋានហើយ ត្រូវអាបត្តិទុក្កដ ។ បាទគាថាថា **ទុប្បរិភុញ្ជេយ្យ ចីវរំ** សេចក្តីថា ភិក្ខុប្រើប្រាស់នូវបណ្តាចីវរទាំងបីណាមួយ ដោយការប្រើប្រាស់មិនល្អ ។ បទថា **អកាយពន្ធនោ** សេចក្តីថា ភិក្ខុមិនបានក្រវាត់កាយពន្ធ (ខ្សែក្រវាត់ចង្កេះ) ដើរទៅកាន់ភូមិស្រុក ។ [១០៥]

យោ ភិក្ខុ **វច្ចកំ** ឧច្ចារំ កត្វាន ឧទកេ សន្តេ **នាចមេយ្យ** ឧទកសុទ្ធឹ ន ករេយ្យ តស្ស ទុក្កដំ សិយា ភិក្ខុណា បន្ទោបង់ឧច្ចារៈហើយ បើទឹកមានតែមិនលាងជម្រះឱ្យស្អាត ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។ [១០៦]

បាទគាថាថា **សមាទេយ្យ អកប្បិយេ** សេចក្តីថា ភិក្ខុំ វា សាមណេរាទិកេ សេសសហធម្មិកេ វា អកប្បិយេ និយោជេយ្យ តស្ស ទុក្កដំ សិយា ភិក្ខុរាប់អានជាមួយភិក្ខុក្តី

---

[១០៤] វិ. ចុ. ភាគ ១០ ទំព័រ ៣៥៧-៨ (រាប់ភិក្ខុពាក់ស្បែកជើងផង)

[១០៥] វិ. ចុ. ភាគ ១០ ទំព័រ ២២០-១

[១០៦] វិ. ចុ. ភាគ ១១ ទំព័រ ១៣២

សហធម្មិកដ៏សេសមានសាមណេរជាដើមក្តី ដែលជាអកប្បិយ ត្រូវអាបត្តិទុក្កដ ។ [១០៧]

សភាគាបត្តិយា ទេសនាវោបនបច្ចយា ទុក្កដំ សិយា ព្រោះបច្ច័យគឺការសម្តែងប្រាប់នូវអាបត្តិមានភាគស្មើគ្នាភិក្ខុត្រូវអាបត្តិទុក្កដ ។ ក្នុងទីនេះ គឺវត្ថុសភាគៈតែម្យ៉ាងប៉ុណ្ណោះ ដែលលោកបំណងយក ក្នុងពាក្យថា **សភាគា** នុ៎ះ មិនសំដៅយកអាបត្តិសភាគៈទេ ។ [១០៨]

៨៤. ពាក្យថា **ន វសេ វស្សំ** សេចក្តីថា យោ ភិក្ខុ វស្សំ **ន វសេយ្យ** ន ឧបគច្ឆេយ្យ តស្ស ទុក្កដំ សិយា ភិក្ខុណាមិនចូលវស្សា ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ ។ [១០៩]

ក្នុងពីរបទថា **វិសំវាទេ សុទ្ធចិត្តេ** នេះ ជាទុតិយាវិភត្តិចុះក្នុងអត្ថនៃចតុត្ថីវិភត្តិ ត្រូវប្រែថា បដិស្សវំ វិសំវាទេន្តស្ស

---

[១០៧] បានដល់ បុគ្គលដែលសង្ឃលើកវត្តជាដើម

[១០៨] វិ. មហាវគ្គ ភាគ ៦ ទំព័រ ៤០៤ (សូមប្បីការទទួលអាបត្តិនេះ ក៏ដូចគ្នា)

[១០៩] វិ. មហាវគ្គ. ភាគ ៧ ទំព័រ ៤

ចំពោះការទទួលប្តេជ្ញាថា ចូលចាំវស្សាទីហើយ ដើរផ្លូវឃើញវត្តល្អក៏ចាំវស្សាទីនោះទៀតជាដើម អ្នកសិក្សាគប្បីពិនិត្យមើលនៅទំព័រទី ៥២ តទៅ ។ ឯសត្តាហករណីយកិច្ចដែលព្រះមានព្រះភាគទ្រង់អនុញ្ញាតនោះ គប្បីអានពី ទំព័រទី ៧ រៀងទៅចុះ ។

សុទ្ធចិត្តស្ស ទុក្កដំ សិយា អាបត្តិទុក្កដ គប្បីមានដល់ភិក្ខុមានចិត្តបរិសុទ្ធពោលប្តេជ្ញា (ទទួលចាំបុរិមិកាវស្សាហើយ) ។

វស្សំ វសិត្វា **អននុញ្ញាតកិច្ចតោ** អននុញ្ញាតកិច្ចេន ភិក្ខុនោ គមនេ ទុក្កដំ សិយា ព្រោះតែភិក្ខុដែលចូលចាំវស្សាចាកចេញទៅដោយគ្មានកិច្ចដែលព្រះមានព្រះភាគទ្រង់អនុញ្ញាតហើយទេ ត្រូវអាបត្តិទុក្កដ ។

៨៥. អាបទំ វជ្ជេត្វា តរុស្ស ឧទ្ធំ បោរិសម្ហា អភិរុហណោ ទុក្កដំ សិយា ភិក្ខុមិនមានអន្តរាយឡើងដើមឈើខ្ពស់ជាងមួយជួរបុរស ត្រូវអាបត្តិទុក្កដ ។ បទថា **អាបទំ** ប្រែថា អន្តរាយ ។ បទថា **តរុស្ស** ប្រែថា ដើមឈើ ។ បទថា **បោរិសម្ហា** ប្រែថា ប្រមាណមួយជួរបុរស បានដល់ កំពស់ប្រាំហត្ថរបស់មជ្ឈិមបុរស ។ [១១០]

អបរិស្សាវនោ យោ ភិក្ខុ អទ្ធានំ គច្ឆេយ្យ យោ ច ភិក្ខុ តំ បរិស្សាវនំ យាចតោ ន ទទេយ្យ តស្ស ទុក្កដំ សិយា ភិក្ខុណាមួយ មិនមានសំពត់តម្រងទឹកដើរទៅកាន់ផ្លូវឆ្ងាយក្តី បើភិក្ខុផងគ្នាសុំខ្ចីសំពត់តម្រងទឹកមិនឱ្យក្តី ត្រូវអាបត្តិទុក្កដ ។ បទថា

[១១០] វិ. ចុ. ភាគ ១០ ទំព័រ ២២៩

**អទ្ធានំ** បានដល់ ផ្លូវឆ្ងាយមានកំណត់ត្រឹមកន្លះយោជន៍ឡើងទៅមែនពិត ។ [១១១]

៨៦. អត្តនោ ឃាតនេ ទុក្កដំ សិយា ព្រោះកិរិយាសម្លាប់ខ្លួនឯង ភិក្ខុត្រូវអាបត្តិទុក្កដ ។ [១១២]

យោ ភិក្ខុ ឥត្ថិរូបាទិរូបំ ករេយ្យ វា ការាបេយ្យ វា តស្ស ទុក្កដំ សិយា ភិក្ខុណាមួយ គូរដោយខ្លួនឯងក្តី ប្រើគេឱ្យគូរក្តី នូវគំនូរមានរូបគំនូរមនុស្សស្រីជាដើម ត្រូវអាបត្តិទុក្កដ ។ រួមសេចក្តីថា មាលាទិកំ វិចិត្តំ បបេត្វា ជាតកាទិវត្ថុំ សយំ ករេយ្យ ទុក្កដំ សិយា រៀវតែវិចិត្រកម្មមានក្បាច់ផ្កាភ្ញីជាដើម ភិក្ខុគូរដោយខ្លួនឯងនូវរឿងជាតកជាដើម ត្រូវអាបត្តិទុក្កដ ។ [១១៣]

៨៧. ពាក្យថា **ភុញ្ជន្តមុដ្ឋាបេ** សេចក្តីថា យោ ភិក្ខុ ភុញ្ជន្តំ ឧដ្ឋាបេយ្យ តស្ស ទុក្កដំ សិយា ភិក្ខុណាមួយ បណ្តេញភិក្ខុផងគ្នាដែលកំពុងឆាន់នៅឡើយឱ្យក្រោកចេញ ត្រូវអាបត្តិទុក្កដ។ [១១៤]

---

[១១១] វិ. ចុ. ភាគ ១០ ទំព័រ ១៦៨

[១១២] វិ. មហាវិ. ភាគ ១ ទំព័រ ២៦៧-៨

[១១៣] វិ. ចុ. ភាគ ១០ ទំព័រ ២៧៨-៩

[១១៤] វិ. ចុ. ភាគ ១០ ទំព័រ ៣២៤

ភត្តសាលាទីសុ វុឌ្ឍានំ ឱកាសំ អទត្វា និសីទតោ ទុក្កដំ សិយា កាលបើភិក្ខុចាស់ទាំងឡាយមិនទាន់បានឱ្យឱកាសទេ ភិក្ខុអង្គុយក្នុងសាលាឆាន់ជាដើម ត្រូវអាបត្តិទុក្កដ ។

៨៨. បទថា **យានានិ** បានដល់ យានទាំងឡាយ គឺ វ ឬគ្រែស្នែង រថ រទេះ និងរថទ្រង់គ្រឿងជាដើម ។ បទថា **កល្លកោ** ប្រែថា គ្មានជំងឺ ។ អធិប្បាយថា អគិលានោ យោ ភិក្ខុ យានានិ អភិរុហេយ្យ តស្ស ទុក្កដំ សិយា ភិក្ខុណា មិនមានជំងឺ ឡើងជិះនូវយានទាំងឡាយ ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ ។[១១៥]

ពីរបទថា **វទេ ទវំ** សេចក្ដីថា និយាយលេង គឺថា រតនត្តយំ អារព្ភ កេឡី វទេយ្យ តស្ស ទុក្កដំ សិយា និយាយលេងប្រារព្ធព្រះរតនត្រ័យ ត្រូវអាបត្តិទុក្កដ ។

អញ្ញបរិសាយ ឧបលាលនេ ទុក្កដំ ហោតិ ព្រោះតែការប្រលោមយកបរិស័ទអ្នកដទៃ ភិក្ខុត្រូវអាបត្តិទុក្កដ ។[១១៦]

---

[១១៥] វិ. មហាវគ្គ ភាគ ៧ ទំព័រ ១៩៤ យានជំនិះដែលគេប្រក់ដំបូលខាងលើមានសណ្ឋានដូចមណ្ឌប ហៅថា វ ។ ឯរថទ្រង់គ្រឿងនោះ គឺទាំងពីរខាងនៃរថនោះ គេពាក់បង្កង់សុទ្ធសឹងតែធ្វើពីរបស់ល្អ ៗ មានមាសប្រាក់ជាដើម មានទ្រង់ទ្រាយដូចជាស្លាបគ្រុឌ ។ រថទាំង ៦ នោះ មានក្នុង វិ.មហាវិ. ៤ ទំ.៤៨៣

[១១៦] វិ. មហាវគ្គ ភាគ ៦ ទំព័រ ២៨១

៨៩. **អាទិ**-សព្ទ ក្នុងពាក្យថា **កាយាទឹ** នេះ តែងសង្គ្រោះយកភ្លៅ និងនិមិត្តផងដែរ ។ អធិប្បាយថា កាយំ វា ឩរុំ វា និមិត្តំ វា វិវរិត្វា ភិក្ខុនីនំ **ន ទស្សយេ** ន ទស្សេយ្យ ភិក្ខុបើកកាយក្តី ភ្លៅក្តី និមិត្ត គឺអង្គជាតក្តី បង្ហាញដល់ពួកនាងភិក្ខុនី ។[១១៧]

លោកាយតំ តិរច្ឆានវិជ្ជំ ន ប សយំ វាចេយ្យ បរញ្ច ន វាចាបេយ្យ ភិក្ខុមិនត្រូវបង្រៀនគម្ពីរលោកាយតៈ ឬតិរច្ឆានវិជ្ជាជាដើមដោយខ្លួនឯង ទាំងមិនគួរឱ្យអ្នកដទៃបង្រៀនខ្លួនទេ ។[១១៨]

បលិតំ គណ្ហេយ្យ វា គណ្ហាបេយ្យ វា តស្ស ទុក្កដំ សិយា ភិក្ខុដកស្កូវដោយខ្លួនឯង ឬប្រើគេឱ្យដក ត្រូវអាបត្តិទុក្កដ ។[១១៩]

៩០-៩២. យត្ថ កត្ថចិ បេឡាយំ បក្ខិបិត្វា ភត្តំ ភុញ្ជន្តស្ស ទុក្កដំ សិយា ភិក្ខុដាក់ភត្តឆាន់ក្នុងហិបណាមួយ ត្រូវអាបត្តិទុក្កដ ។

បត្តហត្ថកោ យោ ភិក្ខុ វាតបានំ វា កវាដំ វា **បណាមេ** បណាមេយ្យ **សោទកំ** បត្តំ **ឱណ្ហោយ្យ** ឱណ្ហោ ឱតាបេយ្យ វា បដិសាមេយ្យ វា **វាទកំ** បត្តំ **អតិឱណ្ហោយ្យ** អតិបបេយ្យ តស្ស ទុក្កដំ សិយា ភិក្ខុណាមួយ មានបាត្រក្នុងដៃ **បណាមេ** រុញបើក

[១១៧] វិ. ចុ. ភាគ ១១ ទំព័រ ២៨៧

[១១៨] វិ. ចុ. ភាគ ១០ ទំព័រ ២៣១-២

[១១៩] វិ. ចុ. ភាគ ១០ ទំព័រ ២១៨

បង្អួចក្ដី ទ្វារក្ដី **ឱណ្ហោយ្យ** ភិក្ខុហាល ឬសាទុកនូវបាត្រ **សោទកំ** ទាំងទឹកសើមក្ដី **អតិឱណ្ហោយ្យ** ហាលបាត្រឱ្យក្ដៅពេកក្ដី ត្រូវអាបត្តិទុក្កដ ។

យោ ភិក្ខុ បត្តំ ភូមិយំ វា អង្កេ វា មញ្ចេ វា បីឋេ វា មិឌ្ឍន្តេ វា បរិភណ្ឌន្តេ វា បាទេ វា ឆត្តេ វា ឋបេយ្យ តស្ស ទុក្កដំ សិយា ភិក្ខុណាមួយ ដាក់បាត្រផ្ទាល់លើផែនដីក្ដី លើភ្លៅទាំងភ្នែនក្ដី លើគ្រែក្ដី តាំងក្ដី លើទីបំផុតនៃផែនក្ដារតាំងក្ដី លើទីបំផុតនៃថ្នាក់ក្ដី ដាក់លើជើងក្ដី ក្នុងឆ័ត្រក្ដី ត្រូវអាបត្តិទុក្កដ។ បទថា **ភូមិយំ** បានដល់ ផែនដីដែលលាយដោយអាចម៍ដី ក្រួសណាមួយដែលមិនកើតប្រយោជន៍ដល់បាត្រ ។ បទថា **អង្កេ** គឺ ត្រង់កណ្ដាលនៃភ្លៅទាំងពីរ ។ បទថា **មិឌ្ឍន្តេ** ប្រែថា ទីបំផុតខាងចុងផែនក្ដារតាំង ។ បទថា **បរិភណ្ឌន្តេ** គឺ ត្រង់ទីបំផុតថ្នាក់ផែនក្ដារស្ដើងដែលគេធ្វើលយចេញក្រៅ ។

យោ ភិក្ខុ ចលកាទឹ វា បត្តេ ឋបេយ្យ បត្តេ វា ហត្ថធោវនេ ហត្ថស្ស ធោវនប្បច្ចយា តស្ស ទុក្កដំ សិយា ភិក្ខុណាមួយ ដាក់វត្ថុជាដែលមានកាកសំណល់ជាដើម ក្នុងបាត្រក្ដី លាងដៃក្នុងបាត្រក្ដី ត្រូវអាបត្តិទុក្កដ ព្រោះការលាងដៃជាបច្ច័យ។

៩៣. ឧច្ឆិដ្ឋំ មុខធោវនំ ឧទកម្បិ បត្តេន នីហរន្តស្ស ភិក្ខុនោ ទុក្កដំ សិយា ភិក្ខុនាំទៅនូវទឹកជាដែល ឬក៏ទឹកលុបមុខ ដោយបាត្រ ត្រូវអាបត្តិទុក្កដ ។ [១៦០]

យោ ភិក្ខុ អកប្បិយំ បត្តំ បរិភុញ្ជេយ្យ តស្ស ទុក្កដំ សិយា ភិក្ខុណាមួយ ប្រើប្រាស់បាត្រជាអកប្បិយ ត្រូវអាបត្តិទុក្កដ ។ បណ្ដាបទទាំងនោះ បទថា **បត្តំ** បានដល់ បាត្រ ៣ យ៉ាង មាន បាត្រឈើជាដើម ។ [១៦១]

៩៤. យោ ភិក្ខុ ខិបិតេ ជីវាតិ វទេ វទេយ្យ តស្ស ទុក្កដំ សិយា ភិក្ខុណាមួយ កាលដែលព្រះមានព្រះភាគទ្រង់ព្រះកណ្ដាស់ ក៏ពោលថា សូមព្រះមានព្រះភាគទ្រង់គង់ព្រះជន្មនៅ ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ [១៦២]

យោ ភិក្ខុ បរិមណ្ឌលកាទិម្ហិ បញ្ចសត្តតិ **សេខិយេ** អនាទរោ ហុត្វា ន សិក្ខតិ តស្ស ទុក្កដំ សិយា ភិក្ខុណាមួយ

---

[១៦០] វិ. ចុ. ភាគ ១០ ទំព័រ ១៥០ ដល់ ១៥៦ រាប់ពីមានបាត្រក្នុងដៃ រហូតដល់ទឹកជាដែល ។

[១៦១] វិ. ចុ. ភាគ ១០ ទំព័រ ១៤៨ ទ្រង់អនុញ្ញាតបាត្រពីរ គឺបាត្រដី និងបាត្រដែក

[១៦២] វិ. ចុ. ភាគ ១០ ទំព័រ ២៣៣

ជាអ្នកមិនអើពើមិនសិក្សាសេខិយវត្តទាំង ៧៥ មានការស្លៀក ឱ្យជាបរិមណ្ឌលជាដើម ត្រូវអាបត្តិទុក្កដ ។ [១៦៣]

៩៥. យោ ភិក្ខុ ភណ្ឌាគារេ បយុតោ មាតុយា បិតុនោ ប ភណ្ឌកំ គោបេយ្យ **អស្ស** ភិក្ខុនោ បាចិត្តិយំ សិយា ភិក្ខុណាមួយ ជាអ្នកប្រកបក្នុងឃ្លាំង (អ្នករក្សាឃ្លាំង) តែទៅជារក្សាទ្រព្យមាតាបិតាវិញ ត្រូវអាបត្តិបាចិត្តិយ ។ បណ្ដាបទទាំងនោះ បទថា **បយុតោ** សេចក្ដីថា ជាអ្នកខ្វល់ខ្វាយដោយអំណាចការរក្សាទ្រព្យក្នុងឃ្លាំង ។ បទថា **គោបយេ** ប្រែថា គប្បីរក្សា ។

យោ ភិក្ខុ ទវាយ ហីនេន ជាតិអាទិនា ឧត្តមម្បិ វទេយ្យ ទុព្ភាសិតំ សិយា ភិក្ខុណាមួយ ពោលបង្អាប់ភិក្ខុផងគ្នា សូម្បីមានជាតិខ្ពង់ខ្ពស់ដោយអក្កោសវត្ថុ ១០ មានជាតិជាដើមដ៏ថោកទាប ត្រូវអាបត្តិទុព្ភាសិត ។

វិនិច្ឆ័យក្នុងការពោលបង្អាប់នោះ គប្បីជ្រាបដូចនេះ ៖

ភិក្ខុប្រាថ្នានឹងសើចលេងប៉ុណ្ណោះ គ្មានបំណងនឹងជេរទេ ក៏ពោលបង្អាប់ឧបសម្បន្ន ឬក៏អនុបសម្បន្នដែលមានជាតិខ្ពង់ខ្ពស់ ឬជាតិថោកទាបដោយបណ្ដាអក្កោសវត្ថុទាំង ១០ មានជាតិជាដើមដ៏ថោកទាប ឬខ្ពង់ខ្ពស់ក្ដី ពោលតាមត្រង់ដោយន័យ

[១៦៣] វិ.មហាវិ. ភាគ ៤ ទំព័រ ៤៣៥ ដល់ ៤៩៧ ក្នុងសេខិយទាំង ៧៥ សិក្ខាបទសុទ្ធមានពាក្យថា អនាទរិយំ ‹មិនអើពើ› ទាំងអស់ ។

ថា លោកជាមនុស្សចណ្ឌាល ដូច្នេះក្តី និយាយបង្វែរទៅរក គ្រឿងអាងដទៃដោយន័យថា ក្នុងទីនេះមានភិក្ខុពួកខ្លះជាមនុស្ស ចណ្ឌាល អ្នកត្បាញផែង អ្នកនេសាទ ដូច្នេះក្តី ត្រូវអាបត្តិ ទុក្កដាសិត ។[១៤៤]

## បកិណ្ណកនិទ្ទេសវណ្ណនា ចប់

---

[១៤៤] វិ. មហាវិ. ភាគ ៣ ទំព័រ ២៦៧

# វត្តាធិករណនិទ្ទេសវណ្ណនា

៩៦. ឥឡូវនេះ ដើម្បីសម្តែងឡើងនូវវត្ត ១៤ លោកអាចារ្យទើបប្រារព្ធពាក្យថា **ឧបជ្ឈាចរិយវត្តំ** ដូចនេះ ៖ [១២៥]

ក្នុងព្រះគាថានោះ អ្នកសិក្សាគប្បីប្រមូលសេចក្តីថា ៖ ឧបជ្ឈាយវត្តញ្ច អាចរិយវត្តញ្ច គមិកវត្តញ្ច អាគន្តុកវត្តញ្ច សេនាសនាទិវត្តញ្ច បិយសីលេន ភិក្ខុនា កាតព្វំ ភិក្ខុដែលមានសីលជាទីស្រឡាញ់ គប្បីធ្វើឧបជ្ឈាយវត្ត អាចរិយវត្ត គមិកវត្ត អាគន្តុកវត្ត និងសេនាសនវត្តជាដើម ។ បទថា **គមិកាគន្តុកំ** កាត់បទជា គមិកំ អាគន្តុកំ ប្រែសេចក្តីថា គមិកវត្ត ១ អាគន្តុកវត្ត ១ ។

៩៧. វិនិច្ឆ័យក្នុងគាថានេះ គប្បីជ្រាបដូចនេះ៖

ការទទួលប្រគេនមានអង្គ ៥ នេះ គឺ៖

១. ទាតុកាមោ ហត្ថបាសេ បិតោ ទាយកមានបំណងនឹងប្រគេនបិតនៅក្នុងហត្ថបាស

---

[១២៥] ឧបជ្ឈាយវត្ត សទ្ធិវិហារិកវត្ត អាចរិយវត្ត និងអន្តេវាសិកវត្ត មានក្នុងបិដកលេខ ៦ វិ. មហាវគ្គ ភាគ ៦ ទំព័រ ១៧៧ ដល់ ២១១ ឯវត្តក្ខន្ធកៈទាំង ១៤ មានក្នុងបិដកលេខ ១១ វិ. ចុ. ភាគ ១១ ទំព័រ ៩៣ ដល់ ១៦៧

២. ឯកេន បុរិសេន គហិតព្វំ ឧក្ខិបនក្ខមំ វត្ថុំ ទេយ្យវត្ថុដែលបុរសម្នាក់អាចចាប់លើកដាក់រួច (កិញ្ចិ គហិតព្វំ)

៣. តីសុ បការេសុ ឯកេនាការេន ទេយ្យំ បណ្តាបការៈ ៣ យ៉ាង ទាយកប្រគេនដោយអាការណាមួយ (តិធា)។

៤. គហេតុកាមោ ភិក្ខុ ភិក្ខុមានប្រាថ្នានឹងទទួល

៥. ទ្វីសុ ឯកេន គណ្ហេយ្យំ បណ្តាប្រការ ២ យ៉ាង ភិក្ខុទទួលដោយអាការណាមួយ (ទ្វិធា) ។

៩៨-១០០. ចីវរដែលនៅទីឆ្ងាយ ភិក្ខុគប្បីកំណត់ឱកាសដែលទុកដាក់ហើយត្រូវពោលថា ឯតំ ចីវរនុ៎ះ ។ (បើ)ចីវរបិតនៅក្នុងហត្ថបាស ភិក្ខុគប្បីយកដៃស្ទាបអង្អែលហើយ ត្រូវពោលថា ឥមំ ចីវរនេះ ។ អធិប្បាយថា ភិក្ខុគប្បីអធិដ្ឋានត្រៃចីវរ ដោយប្រកបដាក់បញ្ចូលពាក្យមួយៗ បណ្តាត្រៃចីវរមានសង្ឃាដិជាដើម ត្រង់កណ្តាលបទទាំងនេះថា ឯតំ ......អធិដ្ឋាមិ អាត្មាអញអធិដ្ឋាន ...នុ៎ះ ឥមំ.... អធិដ្ឋាមិ អាត្មាអញអធិដ្ឋាន....នេះដូច្នេះ ។

សួរថា ដាក់បញ្ចូលយ៉ាងដូចម្តេច ?

ឆ្លើយថា ភិក្ខុគប្បីអធិដ្ឋានយ៉ាងនេះ៖

ឯតំ សង្ឃាដឹ អធិដ្ឋាមិ អាត្មាអញអធិដ្ឋានសង្ឃាដិនុ៎ះ, ឥមំ សង្ឃាដឹ អធិដ្ឋាមិ អាត្មាអញអធិដ្ឋានសង្ឃាដិនេះ ។ ចំពោះការ

អធិដ្ឋានឬដកចីវរផ្សេងទៀតក៏យ៉ាងនេះដែរ ។ ភិក្ខុគប្បីអធិដ្ឋាន បច្ចុទ្ធរ (ដក) សូម្បីបាត្រទាំងឡាយ តាមវិធីដូចដែលធ្វើចំពោះចីវរដែរ ។

១០១. វៀរតែសញ្ចរិត្តសិក្ខាបទចេញ សង្ឃាទិសេសសិក្ខាបទដ៏សេស និងបារាជិកសិក្ខាបទទាំង ៤ ជាសចិត្តកសិក្ខាបទ ។ បទថា **អដ្ឋិមា** បានដល់ អាបត្តិបារាជិក ។ ពីរបទថា **អប្ចិន្នសិក្ខាបទំ បរិណតសិក្ខាបទញ្ច** សេចក្ដីថា វៀរលែងតែសិក្ខាបទពីរនេះចេញ និស្សគ្គិយសិក្ខាបទដ៏សេស ជាអចិត្តកសិក្ខាបទ ។

១០២-៣. ពាក្យថា **គាមប្បវេសនន្តេតេ** ញែកបទជា គាមប្បវេសនំ ឥតិ ឯតេ ។ ដែលមានសេចក្ដីថា បណ្ដាសិក្ខាបទក្នុងបាចិត្តិយទាំងឡាយនុ៎ះ សិក្ខាបទចំនួន ១៧ មាន បទសោធម្មសិក្ខាបទជាខាងដើម មានគាមប្បវេសនសិក្ខាបទជាខាងចុងជាអចិត្តកៈ ។

១០៤-៥. បណ្ដាសិក្ខាបទទាំងឡាយក្នុងបកិណ្ណកនិទ្ទេស វៀរតែឧទ្ទិស្សកតមំសសិក្ខាបទចេញ មំសសិក្ខាបទដ៏សេស ជាអចិត្តកៈ ។ អធិប្បាយថា សិក្ខាបទចំនួន ១៣ នេះ មានអញ្ញមំសសិក្ខាបទជាដើម មានបត្តហត្ថកវាជកសិក្ខាបទជាខាងចុង ក្នុងបកិណ្ណកនិទ្ទេសទាំងឡាយនុ៎ះជាអចិត្តកៈ រីឯសិក្ខាបទដ៏សេសទាំងអស់ជាសចិត្តកៈ ។

១០៦. អាចារ្យទាំងឡាយពោលថា សចិត្តកៈ អចិត្តកៈ ដោយសំដៅដល់ចិត្តប្រព្រឹត្តកន្លង សេចក្ដីថា អាចារ្យទាំងឡាយពោលថា សចិត្តកៈ អចិត្តកៈ ដូច្នោះ សំដៅយកចិត្តដែលដឹងព្រះបញ្ញត្តិ ។ ពាក្យថា **សចិត្តកំ អចិត្តកំ** នេះ គឺលោកកាន់យកហើយដោយ **ត្វា**-សព្ទ ។

១០៧-៩. **អាទិ**-សព្ទ ក្នុងពាក្យថា **បុព្វករណាទិ** នុ៎ះ តែងសង្គ្រោះយកទាំងបុព្វកិច្ចផង អ្នកសិក្សាគប្បីជ្រាបសេចក្ដីក្នុងគាថានោះដូចនេះៈ [១៦៦]

ភិក្ខុអ្នកមានសីលជាទីស្រឡាញ់គប្បីធ្វើឧបោសថ និងបវារណាទាំងអស់ ដែលទ្រង់ត្រាស់សម្ដែងទុកហើយមានប្រការ ៩ មានបុព្វករណៈជាដើមយ៉ាងនេះគឺ ៖

សម្មជ្ជនី បទីបោ ច ឧទកំ អាសនេន ច

ឧបោសថស្ស ឯតានិ បុព្វករណន្តិ វុច្ចតិ ។

ការបោសរោងឧបោសថ ១ អុជប្រទីប ១ ដម្កល់ទឹកឆាន់ទឹកប្រើប្រាស់ ១ ក្រាលអាសនៈ ១ ទាំង ៤ នេះ ហៅថា បុព្វករណៈ នៃឧបោសថកម្ម ។

---

[១៦៦] អ្នកសិក្សាគប្បីស្រាវជ្រាវមើលទាំងអស់ចុះ វិ. មហាវគ្គ ភាគ ៦ ចាប់ពីទំព័រ ៣៦៥ ដល់ ៣៩៩។ ឧបោសថក្ខន្ធកៈទាំងអស់ ចាប់ពីទំព័រ ៣៣៧ ដល់ ៤៤១

ឆន្ទបារិសុទ្ធិឧតុក្ខានំ ភិក្ខុគណនា ច ឱវាទោ
ឧបោសថស្ស ឯតានិ បុព្វកិច្ចន្តិ វុច្ចតិ ។

ការនាំឆន្ទៈ (របស់ភិក្ខុដែលគួរដល់ឆន្ទៈ) ១ ការនាំបារិសុទ្ធិ ១ ការប្រាប់រដូវ ១ ការរាប់ភិក្ខុ ១ ការឱ្យឱវាទដល់នាងភិក្ខុនី ១ ទាំង ៥ នេះ ហៅថា បុព្វកិច្ចរបស់ឧបោសថកម្ម ។

១១២. អធិប្បាយក្នុងពាក្យថា **យថាកម្មំ** នេះ អ្នកសិក្សាគប្បីជ្រាបដូច្នេះ ៖

១. គណោ បារិសុទ្ធិឧបោសថំ ករេយ្យ គណៈគប្បីធ្វើបារិសុទ្ធិឧបោសថ

២. បុគ្គលោ អធិដ្ឋានឧបោសថំ ករេយ្យ បុគ្គលគប្បីធ្វើអធិដ្ឋានឧបោសថ

៣. សង្ឃោ សុត្តុទ្ទេសឧបោសថំ ករេយ្យ សង្ឃគប្បីធ្វើសុត្តុទ្ទេសឧបោសថ ។

១១៣. កន្លះគាថាថា **ចាតុទ្ទសោ បណ្ណរសោ សាមគ្គីទិនតោ តិធា** សេចក្តីថា ឧបោសថមាន ៣ ព្រោះថ្ងៃគឺ ៖

១. ចាតុទ្ទសោ ឧបោសថោ ឧបោសថថ្ងៃទី ១៤

២. បណ្ណរសោ ឧបោសថោ ឧបោសថថ្ងៃទី ១៥

៣. សាមគ្គីឧបោសថោ ឧបោសថក្នុងថ្ងៃដែលសង្ឃព្រមព្រៀងគ្នា ។

អធិប្បាយថា ឧបោសថមាន ៩ ព្រោះរាប់ឱ្យជាបីៗ គឺ ៖

| | |
|---|---|
| ទិវសតោ | រាប់ដោយថ្ងៃ |
| បុគ្គលតោ | រាប់ដោយបុគ្គលអ្នកធ្វើ |
| កត្តព្វាការតោ | រាប់ដោយកម្មដែលត្រូវធ្វើ ។ |

១១៤. ពីរបទថា **តេវាចី ទ្វេវាចី** សេចក្ដីថា បវារណាមាន ៩ លោកពោលទុក ដូច នេះ គឺ ៖ [១៦៧]

| | |
|---|---|
| តេវាចិកបវារណា | បវារណា ៣ ៗ ដង |
| ទ្វេវាចិកបវារណា | បវារណា ២ ៗ ដង |
| ឯកវាចិកបវារណា | បវារណាម្ដង ៗ ។ |

១១៥. បទថា **តស្ស** បានដល់ ខែផល្គុណ ។ ពីរបទថា **តតោ សេសំ** គឺវស្សានរដូវ បានដល់ រដូវភ្លៀងរាប់ពីបក្ខខាងចុង គឺ ១ រោចខែអាសាឡ្ហ ដល់ពេញបូណ៌មីខែកត្តិក ។ ព្រោះហេតុនោះ ក្នុងអធិការនេះ ឧបោសថមាន ២៤ ថ្ងៃក្នុងមួយឆ្នាំ ។

---

[១៦៧] វិ. មហាវគ្គ ភាគ ៧ ទំព័រ ១១៩ ។ បវារណាខន្ធកៈទាំងមូល រាប់ពីទំព័រ ៦៦ ដល់ ១៥២

១១៦. បទថា **ឯតេសុ** សេចក្ដីថា ក្នុងរយៈ ៤ ៗ ខែ ក្នុងរដូវទាំង ៣ នុ៎ះ ចាតុទ្ទសីឧបោសថមានក្នុងបក្ខទី ៣ បក្ខទី ៧ ក្នុងរដូវមួយៗ ។ បទថា **ចាតុទ្ទសា** សេចក្ដីថា ចាតុទ្ទសីឧបោសថមាន ៦ ។ ពាក្យដ៏សេសជាពាក្យងាយយល់មែនពិត ៕

វត្តាទិកណ្ឌាទិទេសវណ្ណនា ចប់

# និគមនកថា

មូលសិក្ខត្ថវណ្ណនាណា ដែលខ្ញុំរចនាហើយដោយសង្ខេប ប៉ុណ្ណេះ មូលសិក្ខត្ថវណ្ណនានោះ ចប់បរិបូរហើយដោយអំណឹះ ទៅនៃរយៈកាលកន្លះខែប៉ុណ្ណោះ ។ បុណ្យណា ដែលខ្ញុំបានធ្វើ ឱ្យសម្រេចហើយ ព្រោះតែការពណ៌នាអត្ថនេះដោយសង្ខេប ដើម្បីប្រយោជន៍ដល់កុលបុត្រដែលបានឧបសម្បទាថ្មី ។ ដោយ សារបុណ្យនោះ សូមសព្វសត្វបានសម្រេចនូវព្រះនិព្វានមិនមាន ជរាដោយបទដ៏ស្ងប់ ព្រោះការបដិបត្តិដ៏បរិសុទ្ធផូរផង់(របស់ខ្លួន) ភិក្ខុប្រមាណ ១០០ រូប គង់នៅក្នុងព្រះវិហារជាទីរីករាយដ៏ដេរ ដាស់ ដោយពួកឈើផ្សេងៗ ជាអ្នកស្រឡាញ់កុសលធម៌ផ្សេងៗ ជាម្ចាស់នៃចម្ប៉ាំង ។ (ជំនុំព្រះភិក្ខុទាំង ១០០ អង្គនោះ) ភិក្ខុជា បណ្ឌិតដែលបានសម្រេចនូវសិទ្ធិបត្រក្នុងសាសនានៃព្រះជិនស្រី គឺថាសម្រេចដោយញាណបានរចនាហើយនូវមូលសិក្ខត្ថវណ្ណនា ន៉ុះ ។

## មូលសិក្ខា-ដីកា ចប់




ISBN: 978-99963-844-1-7